ព្រះបន្ទូលលើកទឹកចិត្តប្រចាំថ្ងៃ
ពាក្យទំនាយប្រចាំថ្ងៃរបស់អ្នកៗ

ការចេញផ្សាយលេខ 4

តុលា – វិច្ឆិកា – ធ្នូ

2025

ដំណឹងល្អ

ប្រចាំថ្ងៃ

កុមារ



ដោយឥតគិតថ្លៃ
មិនសម្រាប់លក់
ព្រះបន្ទូលលើកទឹកចិត្តនេះត្រូវបានចែងថ្លៃ ដោយដៃគូរបស់យើង រួចហើយដូច្នេះអាចចែកចាយដោយឥតគិតថ្លៃ

ទឹកបានត្រជាក់ដល់ព្រលឹងមនុស្សល្ងីងល្ងើយជាយ៉ាងណា នោះដំណឹងល្អដែលមកពីស្រុកឆ្ងាយក៏យ៉ាងនោះដែរ។ (សុភាសិត ២៥:២៥)

Uebert & BeBe
ANGEL




យូប៊ើត និង ប៊ីប៊ីអេនជល

យូប៊ើត និង ប៊ីប៊ីអេនជលប្តេជ្ញាចែករំលែកសេចក្តីស្រឡាញ់ និងសាររបស់ព្រះជាមួយមនុស្សមកពីជុំវិញពិភពលោក។ ពួកគាត់បានសរសេរសៀវភៅគ្រីស្ទាន ដ៏ពេញនិយមជាច្រើនសម្រាប់ទាំងមនុស្សពេញវ័យ និងកុមារ ដែលបានបំផុសគំនិតមនុស្សជាច្រើននៅទូទាំងពិភពលោក។ ពួកគាត់បានធ្វើដំណើរទៅកាន់ប្រទេសជាច្រើនដើម្បីនិយាយអំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទរបស់យើង ហើយបង្រៀនអំពីសេចក្តីស្រឡាញ់ និងសេចក្តីសប្បុរសរបស់ព្រះ។ ពួកគាត់ត្រូវបានឧទ្ទិសដល់ការផ្សព្វផ្សាយដំណឹងល្អនៃព្រះគុណរបស់ព្រះ និងធ្វើឱ្យមានផលប៉ះពាល់ជាវិជ្ជមានលើជីវិតរាប់លាននាក់នៅជុំវិញពិភពលោក។

អំពីដំណឹងល្អប្រចាំថ្ងៃ

ដំដំណឹងល្អប្រចាំថ្ងៃសម្រាប់កុមារ គឺជាមគ្គុទ្ទេសក៍គ្រីស្ទានដ៏ពិសេសមួយ ដែលបង្កើតឡើងសម្រាប់តែកុមារ
ដោយជួយពួកគេឱ្យរីកចម្រើនក្នុងសេចក្តីជំនឿរបស់ពួកគេ និងឲ្យយល់ពីសេចក្តីស្រឡាញ់របស់ព្រះ។
ដែលចេញផ្សាយជារៀងរាល់បីខែម្តង វាពោរពេញទៅដោយរឿងសប្បាយៗ មេរៀនព្រះគម្ពីរដែលងាយយល់ និងសារដែលលើកទឹកចិត្តកុមារ ឱ្យរស់នៅដូចព្រះយេស៊ូវគ្រីស្ទ ដែលបំផុសគំនិតដោយការបង្រៀនរបស់ហោរា យូប៊ើត អេនជល។ អ្វីដែលធ្វើឱ្យដំណឹងល្អប្រចាំថ្ងៃសម្រាប់កុមារកាន់តែប្រសើរនោះ គឺថាវាមានជាភាសា
ផ្សេងៗ គ្នា ដូច្នេះកុមារនៅគ្រប់ទីកន្លែងអាចរីករាយ និងរៀនពីវា ហើយជាផ្នែកដ៏ល្អបំផុត? ផ្តល់ឲ្យដោយឥត
គិតថ្លៃ ក្នុងការចែករំលែកជាមួយមិត្តភ័ក្តិ ដូច្នេះអ្នករាល់គ្នាអាចទទួលបានសារដ៏អស្ចារ្យ
និងផ្តាស់ប្តូរជីវិត!



ថ្ងៃពុធ ទី1 ខែតុលា

ផលផ្លែនៃព្រះវិញ្ញាណ

កាឡាទី 5:22 (ពគប)
តែឯផលផ្លែនៃព្រះវិញ្ញាណវិញ នោះគឺសេចក្តីស្រឡាញ់ អំណរអរ មេត្រីភាព អត់ធ្មត់ សុភាព សប្បុរស ស្មោះត្រង់ ។

តើអ្នកដឹងទេថា ព្រះវិញ្ញាណបរិសុទ្ធ ប្រទានអំណោយដ៏អស្ចារ្យ មួយចំនួនដល់យើង ដើម្បីជួយយើងឲ្យរស់នៅដូចជាព្រះយេស៊ូវ ? អំណោយទានទាំងនេះ ត្រូវបានគេហៅថា «ផលផ្លែនៃព្រះវិញ្ញាណ» ហើយពួកគេធ្វើឱ្យយើង កាន់តែដូចជាព្រះ នៅក្នុងអ្វីគ្រប់យ៉ាងដែលយើងធ្វើ!

នេះគឺជាអំណោយទានមួយចំនួន ដែលព្រះវិញ្ញាណបរិសុទ្ធ ប្រទានដល់យើង ៖
•សេចក្តីស្រឡាញ់ - ស្រឡាញ់អ្នកដទៃ ដូចព្រះយេស៊ូវស្រឡាញ់យើង ។
•អំណរអរ - មានអារម្មណ៍សប្បាយរីករាយ និងអរព្រះគុណ ចំពោះព្រះពរទាំងអស់របស់ព្រះ ។
•មេត្រីភាព - ភាពស្ងប់ស្ងាត់នៅខាងក្នុង សូម្បីតែពេលមានរឿងលំបាកក៏ដោយ ។
•អត់ធ្មត់ - រង់ចាំដោយមិន តូចចិត្ត ឬខឹងសម្បាឡើយ ។
•សុភាព - មានភាពរុះរាយរាក់ទាក់ និងយកចិត្តទុកដាក់ ចំពោះអ្នកដទៃ ។
•សប្បុរស - ធ្វើអ្វីដែលត្រូវ និងល្អ ។
•ស្មោះត្រង់ - មានភាពស្មោះត្រង់ និងប្រកាន់ខ្ជាប់ចំពោះព្រះ មិនថាមានអ្វីកើតឡើងក៏ដោយ ។

អំណោយទានពិសេសទាំងនេះ តែងតែនៅជាមួយអ្នក នៅពេលដែលអ្នក មានព្រះវិញ្ញាណបរិសុទ្ធ នៅក្នុងចិត្តរបស់អ្នក ។ អ្នកអាចបង្ហាញពួកគេ ដល់អ្នកដទៃដោយសុភាព អត់ធ្មត់ សេចក្តីស្រឡាញ់ និងអំណរអរ!

សេចក្តីប្រកាសពីបទទំនាយ
ព្រះវិញ្ញាណបរិសុទ្ធ គង់នៅក្នុងខ្លួនខ្ញុំ ខ្ញុំពោរពេញដោយសេចក្តីសប្បុរស! ខ្ញុំនឹងបញ្ចឹកឆ្លងណាដែលខ្ញុំទៅ! ហាលេលូយ៉ា ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ សូមទ្រង់ជួយទូលបង្គំឲ្យមានសេចក្តីស្រឡាញ់ អំណរអរ មេត្រីភាព អត់ធ្មត់ សុភាព សប្បុរស ស្មោះត្រង់ ស្លូតបូត ហើយដឹងខ្នាត ដូចទ្រង់ចង់ឱ្យទូលបង្គំក្លាយជា ។ អាម៉ែន ។

ការសិក្សាបន្ថែម
កិច្ចការ 2:42-47



ថ្ងៃព្រហស្បតិ៍ ទី2 ខែតុលា

ពេត្រុសចាប់ផ្តើមលិច

ម៉ាថាយ 14:30 (ពគប)
តែកាលគាត់ឃើញខ្យល់បក់ជាខ្លាំង នោះគាត់មានចិត្តភ័យ ហើយដោយព្រោះចាប់តាំងលិចទៅ បានជាគាត់ស្រែកឡើងថា ព្រះអម្ចាស់អើយ សូមជួយសង្គ្រោះទូលបង្គំផង ។

កូនៗ តើអ្នកធ្លាប់លឺរឿងរបស់ ពេត្រុស ដើរលើទឹកទេ?


នេះជាអ្វីដែលបានកើតឡើង នៅក្នុងព្រះគម្ពីរ៖ ពេត្រុសបានឃើញព្រះយេស៊ូវកំពុងដើរលើទឹក ហើយគាត់បានសួរព្រះយេស៊ូវថា តើគាត់អាចមករកទ្រង់បានឬអត់ ។ ព្រះយេស៊ូវប្រាប់គាត់ឲ្យដើរមក ហើយពេត្រុស ពិតជាបានដើរលើទឹក! ប៉ុន្តែ ពេលពេត្រុសឃើញខ្យល់ ហើយភ័យខ្លាច គាត់ចាប់ផ្តើមលិច ។ គាត់បានស្រែកឡើងថា «ព្រះអម្ចាស់អើយ សូមសង្គ្រោះទូលបង្គំផង!» ព្រះយេស៊ូវក៏លូកដៃចាប់គាត់ ហើយមានព្រះបន្ទូលថា៖ «ហេតុអ្វីបានជាអ្នកសង្ស័យ? ឱអ្នកមានជំនឿតិចអើយ» ។

យើងអាចរៀនអ្វីដែលសំខាន់ ពីរឿងរបស់ពេត្រុស ។ នៅពេលដែលអ្វីៗមិនដំណើរការដូចដែលអ្នកចង់បាន ដូចជានៅសាលារៀន ឬនៅផ្ទះ អ្នកត្រូវបន្តទុកចិត្តលើព្រះ ។ កុំឱ្យអ្វីដែលអ្នកឃើញ ឬមានអារម្មណ៍ ធ្វើឱ្យអ្នកឈប់ជឿ ។ ចូររក្សាសេចក្តីជំនឿរបស់អ្នកឲ្យរឹងមាំ ហើយជឿជាក់ថា ព្រះគង់នៅជាមួយអ្នក ដូចជាទ្រង់នៅជាមួយពេត្រុសដែរ!

សេចក្តីប្រកាសពីបទទំនាយ
ឱព្រះអម្ចាស់អើយ សូមទ្រង់ជួយទូលបង្គំ ឲ្យជឿលើទ្រង់ទាំងស្រុង ហើយកុំសង្ស័យព្រះបន្ទូលទ្រង់ ដើម្បីឱ្យទូលបង្គំ អាចដើរលើទឹកបាន ដូចពេត្រុស ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់យេស៊ូវអើយ សូមទ្រង់ជួយទូលបង្គំទុកចិត្តលើទ្រង់ ហើយរក្សាសេចក្តីជំនឿទូលបង្គំទៅលើទ្រង់ ក្នុងគ្រប់ព្យុះទាំងឡាយ ។ អាម៉ែន ។

ការសិក្សាបន្ថែម
ម៉ាថាយ 14:22-33



ថ្ងៃសុក្រ ទី3 ខែតុលា

យ៉ូសែប និងសុបិនរបស់គាត់

2 កូរិនថូស 5:7 (ពគប)
ដ្បិតយើងខ្ញុំដើរដោយជំនឿ មិនមែនដោយមើលឃើញទេ ។

ថ្ងៃមួយ យ៉ូសែបបានចែករំលែកសុបិនមួយ ដែលគាត់មាននៅកន្លែង ដែលបងប្អូនគាត់ទាំងអស់គ្នា នឹងក្រាបថ្វាយបង្គំគាត់ ។ នេះធ្វើឲ្យបងប្អូនគាត់ខឹង! ថ្ងៃមួយ បងប្អូនបានសម្រេចចិត្ត កម្ចាត់យ៉ូសែប ។ គេបោះគាត់ទៅក្នុងរណ្តៅ ហើយលក់ទៅឲ្យឈ្មួញខ្លះ ។ យ៉ូសែបន្តៅឆ្ងាយ ពីក្រុមគ្រួសាររបស់គាត់ ប៉ុន្តែគាត់មិនចុះចាញ់ឡើយ"។ ទោះបីជាមានរឿងលំបាកក៏ដោយ យ៉ូសែបបានរក្សាទុកចិត្តលើព្រះ ។

ក្រោយមក យ៉ូសែបបានឆ្លងកាត់ គ្រាលំបាកជាច្រើន ប៉ុន្តែព្រះនៅជាមួយគាត់ជានិច្ច ។ នៅទីបំផុត យ៉ូសែបបានក្លាយជា អ្នកគ្រប់គ្រងដ៏សំខាន់ម្នាក់ ក្នុងប្រទេសអេស៊ីប្ទ ។ ជាច្រើនឆ្នាំក្រោយមក នៅពេលដែលមានទុរ្ភិក្ស បងប្អូនរបស់គាត់ បានមកប្រទេសអេស៊ីប្ទ ដើម្បីទិញអាហារ ហើយពួកគេមិនបានស្គាល់យ៉ូសែបទេ ។ ប៉ុន្តែ យ៉ូសែបបានអភ័យទោសដល់ពួកគេ ហើយបានជួយពួកគេ ទោះជាពួកគេធ្លាប់ធ្វើបាបគាត់ពីមុនក៏ដោយ ។

យ៉ូសែបមិនដែលឈប់ជឿ លើអ្វីដែលព្រះបានបង្ហាញគាត់ ក្នុងសុបិននោះទេ ។ ជាច្រើនឆ្នាំក្រោយមក សុបិនរបស់យ៉ូសែប បានក្លាយជាការពិត ដូចព្រះបន្ទូលបានសន្យា ។ គាត់បានក្លាយជាមនុស្សសំខាន់ម្នាក់នៅស្រុកអេស៊ីប្ទ ។ ចូរជឿលើព្រះបន្ទូលរបស់ព្រះ និងការសន្យារបស់ទ្រង់ អ្នកប្រាកដជានឹងត្រលប់មកវិញជាមួយនឹងទីបន្ទាល់!

សេចក្តីប្រកាសពីបទទំនាយ
ខ្ញុំជឿលើសេចក្តីសន្យារបស់ព្រះអម្ចាស់ ។ ខ្ញុំជឿតែអ្វីដែលទ្រង់មានបន្ទូលប៉ុណ្ណោះ ។ សូមអរព្រះគុណព្រះអម្ចាស់ ដែលខ្ញុំនឹងត្រឡប់មកវិញ ដោយមានទីបន្ទាល់ ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ សូមជួយទូលបង្គំឲ្យជឿលើផែនការរបស់ទ្រង់ សម្រាប់ជីវិតទូលបង្គំ ដូចជាយ៉ូសែបបានទុកចិត្តលើទ្រង់ដែរ ។ អាម៉ែន ។

ការសិក្សាបន្ថែម ៖
លោកុប្បត្តិ 39:20 – 41:43



ថ្ងៃសៅរ៍ ទី4 ខែតុលា

អណ្តាតនៃអំណាច

1 កូរិនថូស 14:4 (ពគប)
អ្នកណាដែលនិយាយភាសាដទៃ នោះស្អាងតែចិត្តខ្លួនឯងទេ តែអ្នកណាដែលអធិប្បាយ នោះទើបស្អាងចិត្តចំពោះពួកជំនុំទាំងអស់គ្នាវិញ ។


ហេកូនៗ តើអ្នកធ្លាប់ឮនរណាម្នាក់ និយាយតាមរបៀប ដែលអ្នកមិនយល់ដូចជាភាសាដទៃទេ? នៅក្នុងព្រះគម្ពីរ ស្មារកប៉ុលនិយាយ អំពីអ្វីដែលហៅថា និយាយភាសាដទៃ ។ នេះជាអំណោយទានដ៏ពិសេស ពីព្រះតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។ ពេលនរណាម្នាក់និយាយភាសាដទៃ ពួកគេកំពុងតែនិយាយភាសាស្ថានសួគ៌ ជាភាសាដែលមកពីព្រះវិញ្ញាណផ្ទាល់!

ប៉ុលចូលចិត្តអំណោយទាននេះ! គាត់បាននិយាយថា ៖ «ខ្ញុំអរគុណដល់ព្រះដែលខ្ញុំនិយាយភាសាដទៃច្រើនជាងអ្នករាល់គ្នា» ។ នោះគឺដោយសារតែប៉ុលបានអធិស្ឋានជាភាសាដទៃ គាត់មានអារម្មណ៍ជិតស្និទ្ធនឹងព្រះ ។ វាបានជួយគាត់ឲ្យរឹងមាំក្នុងវិញ្ញាណ ហើយជួយគាត់អធិស្ឋានបានត្រឹមត្រូវ សូម្បីតែគាត់មិនដឹងថា ត្រូវនិយាយអ្វីក៏ដោយ ។ កូនៗអើយ នៅពេលអ្នកអធិស្ឋាន ជាភាសាដទៃ អ្នកនឹងរឹងមាំខាងវិញ្ញាណ ។ សាកខ្លួនអ្នក ដោយការអធិស្ឋាន ជាភាសាដទៃនៅថ្ងៃនេះ!

សេចក្តីប្រកាសពីបទទំនាយ
សូមអរព្រះគុណព្រះយេស៊ូវ សម្រាប់ព្រះដ៏ជាជំនួយរបស់ទ្រង់ គឺព្រះវិញ្ញាណបរិសុទ្ធ ។ សូមបង្រៀនខ្ញុំពីព្រះវិញ្ញាណបរិសុទ្ធ ឲ្យអធិស្ឋានជាភាសាដទៃ ដូចជាសាវកប៉ុល នៅគ្រប់ស្ថានភាព ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ សូមអរព្រះគុណទ្រង់ សូម្រាប់ព្រះវិញ្ញាណបរិសុទ្ធ ជួយទូលបង្គំឱ្យប្រើអំណោយទាន ពិសេសរបស់ទ្រង់ ដើម្បីឱពកាន់តែជិតទ្រង់ ។ អាម៉ែន ។

ការសិក្សាបន្ថែម
កិច្ចការ 2:4



ថ្ងៃអាទិត្យ ទី5 ខែតុលា

គំរូរបស់ព្រះយេស៊ូវ

ភីលីព 2:2 (ពគប)
នោះចូរបំពេញសេចក្តីអំណររបស់ខ្ញុំ ដោយអ្នករាល់គ្នាមានគំនិត មានសេចក្តីស្រឡាញ់តែ១ ទាំងរួបរួមចិត្តគ្នា ហើយគិតតែផ្លូវ១ដូចគ្នាចុះ ។

កូនៗ ព្រះយេស៊ូវគ្រីស្ទ គឺជាគំរូដ៏ល្អបំផុតរបស់យើង នៃសេចក្តីស្រឡាញ់នៅក្នុងសកម្មភាព។ នៅពេលដែលទ្រង់ បានយាងមកលើផែនដី កាលពីជាង 2,000ឆ្នាំមុន ទ្រង់បានរស់នៅក្នុងជីវិតដ៏ល្អឥតខ្ចោះ ដោយសេចក្តីស្រឡាញ់ និងការបន្ទាបខ្លួន ។


នៅក្នុងគម្ពីរ ភីលីព 2:2 សាវ័កប៉ុលប្រាប់យើង ឲ្យមានចិត្តសប្បុរស មានសេចក្តីស្រឡាញ់ និងរួបរួមជាក្រុមគ្រួសារនៃអ្នកជឿ ។ ទ្រង់លើកទឹកចិត្តយើង ឱ្យធ្វើការរួមគ្នាដោយមានចិត្ត និងគោលបំណងដូចគ្នា ដោយយកចិត្តទុកដាក់ ចំពោះតម្រូវការ របស់គ្នាទៅវិញទៅមក ។ ប៉ុលនិយាយថា យើងមិនគួរគិតតែពីខ្លួនឯងទេ ។ ផ្ទុយទៅវិញ យើងគួរបន្ទាបខ្លួន ហើយគិតដល់អ្នកដទៃជាមុនសិន ។

ពេលយើងធ្វើបែបនេះ វាធ្វើឲ្យព្រះសប្បាយចិត្ត ហើយជួយយើងឲ្យរស់នៅដោយសុខសាន្តជាមួយមនុស្សគ្រប់គ្នា ។ ប៉ុលរំឭកយើងថា នេះជារបៀបដែលយើង បង្ហាញសេចក្តីស្រឡាញ់ ចំពោះព្រះយេស៊ូវ និងចំពោះគ្នាទៅវិញទៅមក។ ដោយមានចិត្តសប្បុរស ដូចជាព្រះយេស៊ូវ ធ្វើការជាមួយគ្នា ហើយដាក់អ្នកដទៃនៅចំពោះមុខខ្លួនយើង នោះយើងអាចនាំឲ្យមានអំណរ ដល់ព្រះហឫទ័យរបស់ព្រះ ហើយធ្វើជាគំរូល្អ ដល់អ្នកឯទៀត ។

សេចក្តីប្រកាសពីបទទំនាយ
ឱព្រះអម្ចាស់អើយ សូមអរព្រះគុណ ចំពោះព្រះរាជបុត្រារបស់ទ្រង់ គឺជាព្រះយេស៊ូវ ដែលជាគំរូដ៏ល្អឥតខ្ចោះ នៃសេចក្តីស្រឡាញ់ និងការបន្ទាបខ្លួន ។ សូមជួយខ្ញុំឲ្យក្លាយដូចជាទ្រង់ ក្នុងព្រះនាមព្រះយេស៊ូវ ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
សូមអរព្រះគុណចំពោះព្រះរាជបុត្រាគឺជាព្រះយេស៊ូវ ដែលជាគំរូដ៏ល្អឥតខ្ចោះ នៃសេចក្តីស្រឡាញ់ និងការបន្ទាបខ្លួន ។ ជួយទូលបង្គំឱ្យដូចជាទ្រង់ នៅក្នុងព្រះនាមព្រះយេស៊ូវ ។ អាម៉ែន ។

ការសិក្សាបន្ថែម
ភីលីព 2:1-4



ថ្ងៃចន្ទ ទី6 ខែតុលា

ព្រះបន្ទូល

យ៉ូហាន 1:1-3 (ពគប)
[1]កាលដើមដំបូងមានព្រះបន្ទូល ព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះ ហើយព្រះបន្ទូលនោះដឹងជាព្រះ [2]ក៏ទ្រង់គង់នៅជាមួយនឹងព្រះ តាំងអំពីដើមដំបូងមក [3]ត្រប់រឿងសឹងទាំងអស់បានកើតមកដោយសារទ្រង់ ហើយក្នុងបណ្តាលរបស់ដែលបានបង្កើតមកទាំងប៉ុន្មាន នោះគ្មានអ្វីណាមួយកើតមកក្រៅពីទ្រង់ឡើយ ។


តើអ្នកដឹងទេថា ព្រះយេស៊ូវតែងតែនៅទីនេះ សូម្បីតែមុនពេល ពិភពលោកចាប់ផ្តើម? ត្រូវហើយ! ព្រះគម្ពីរប្រាប់យើងថា ព្រះយេស៊ូវជាព្រះបន្ទូល ហើយទ្រង់គង់នៅជាមួយព្រះ តាំងពីដើមដំបូងមក ។ តាមពិតទ្រង់ជាព្រះ! អ្វីគ្រប់យ៉ាងដែលអ្នកឃើញដើមឈើ ផ្កាយ សត្វ និងសូម្បីតែអ្នកត្រូវបានបង្កើតឡើង តាមរយៈព្រះយេស៊ូវគ្រីស្ទ ។ គ្មានអ្វីត្រូវបានបង្កើតឡើង ដោយគ្មានទ្រង់ទេ ។ តើវាមិនអស្ចារ្យទេ?

ព្រះយេស៊ូវមិនគ្រាន់តែជាផ្នែក នៃរឿងបុណ្យណូអែល ឬជាបុគ្គលម្នាក់ដែលរស់នៅ ជាយូរមកហើយ ។ ទ្រង់ជាអ្នកបង្កើតអ្វីៗទាំងអស់ ហើយទ្រង់ស្រឡាញ់អ្នកខ្លាំងណាស់! មុនពេលអ្នកកើត ទ្រង់បានស្គាល់អ្នករួចហើយ ហើយមានផែនការពិសេស សម្រាប់ជីវិតរបស់អ្នក ។ បទគម្ពីរនេះជួយយើង ចុងចាំរឿងនោះ ។ ព្រះយេស៊ូវមានអំណាច ហើយតែងតែនៅជាមួយព្រះ ។ ទ្រង់មិនគ្រាន់តែបង្ហាញខ្លួន នៅពេលដែលទ្រង់ប្រសូត នៅបេថ្លេហិមប៉ុណ្ណោះទេ ទ្រង់តែងតែនៅទីនេះ បង្កើតស្រឡាញ់ និងយកចិត្តទុកដាក់ចំពោះយើង ។ ហើយស្មានថាម៉េចដែរ? ទ្រង់ចង់ធ្វើជាមិត្តល្អបំផុតរបស់អ្នក!

សេចក្តីប្រកាសពីបទនំនាយ
ឱព្រះអម្ចាស់យេស៊ូវអើយ សូមអរព្រះគុណទ្រង់ សម្រាប់ការធ្វើអ្វីគ្រប់យ៉ាង រួមទាំងខ្ញុំផង! ខ្ញុំរីករាយណាស់ ដោយដឹងថាទ្រង់ស្រឡាញ់ខ្ញុំ ហើយមានផែនការ សម្រាប់ជីវិតរបស់ខ្ញុំ ។ ជួយខ្ញុំឱ្យចងចាំជានិច្ចថា តើទ្រង់ធំ និងអស្ចារ្យប៉ុណ្ណា ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់យេស៊ូវអើយ សូមអរព្រះគុណទ្រង់ សម្រាប់ការធ្វើអ្វីគ្រប់យ៉ាង រួមទាំងទូលបង្គំផង! ខ្ញុំមានក្តីរីករាយ ណាស់ដែលដឹងថា ទ្រង់ស្រឡាញ់ទូលបង្គំ ហើយមានផែនការសម្រាប់ជីវិតរបស់ទូលបង្គំ ។ ជួយទូលបង្គំឱ្យចងចាំជានិច្ចថា តើទ្រង់ធំនិងអស្ចារ្យប៉ុណ្ណា ។ អាម៉ែន ។

ការសិក្សាបន្ថែម
ទំនុកដំកើង 33:6



ថ្ងៃអង្គារ ទី7 ខែតុលា

ព្រះយេស៊ូវគឺជាពន្លឺ

យ៉ូហាន 1:4-5 (ពគប)
[4]នៅក្នុងទ្រង់មានជីវិត ហើយជីវិតនោះជាពន្លឺនៃមនុស្សលោក [5]ពន្លឺនោះក៏ភ្លឺមកក្នុងសេចក្តីងងឹត តែសេចក្តីងងឹតយល់មិនដល់ពន្លឺទេ ។


ចូរស្រមៃមើលថា អ្នកស្ថិតនៅក្នុងបន្ទប់ងងឹត ។ អ្នកមិនអាចមើលឃើញអ្វីឡើយ ហើយវាពិបាកក្នុងការដឹងថាត្រូវទៅណា ។ ប៉ុន្តែបន្ទាប់មក មាននរណាម្នាក់បើកភ្លើង ហើយមួយរំពេចនោះ អ្នកអាចមើលឃើញទាំងអស់យ៉ាងច្បាស់! នោះជាអ្វីដែលព្រះយេស៊ូវ ធ្វើសម្រាប់យើង ។ ព្រះយេស៊ូវគឺជាពន្លឺ ដែលភ្លឺនៅក្នុងភាពងងឹត ។

តាំងពីយូរយារណាស់មកឲ្លើយ ពិភពលោកពោរពេញ ដោយភាពងងឹត ប៉ុន្តែព្រះយេស៊ូវបានយាងមកដើម្បីនាំពន្លឺដ៏ភ្លឺរបស់ទ្រង់ ។ ពន្លឺរបស់ទ្រង់គឺខ្លាំងជាងភ្នាពងងឹតណាមួយ ។ គាត់ផ្តល់ឱ្យយើង សេចក្តីអំណរ សេចក្តីស្រឡាញ់ និងជីវិតជារៀងរាល់ថ្ងៃ ។ ហើយស្មានថាម៉េច? ពន្លឺរបស់ព្រះយេស៊ូវអាចភ្លឺអ្នកផងដែរ! ពេលអ្នកមានចិត្តសប្បុរស សេចក្តីស្រឡាញ់ និងជួយអ្នក ក៏ពុងបង្ហាញពន្លឺរបស់ទ្រង់ដល់អ្នកដទៃ ។ ដូច្នេះសូមចងចាំជានិច្ច ៖ ព្រះយេស៊ូវគឺជាពន្លឺ ដែលរស់នៅក្នុងអ្នក ហើយជួយអ្នកឱ្យភ្លឺក្នុងពិភពលោកនេះ!

សេចក្តីប្រកាសពីបទទំនាយ
ពន្លឺនៃព្រះយេស៊ូវភ្លឺនៅក្នុងខ្ញុំ និងតាមរយៈខ្ញុំ ។ ភាពងងឹតមិនអាច យកឈ្នះខ្ញុំបានទេ ពីព្រោះខ្ញុំជារបស់ព្រះយេស៊ូវ ជាពន្លឺនៃពិភពលោកនេះ ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់យេស៊ូវអើយ សូមអរព្រះគុណទ្រង់ សម្រាប់ការធ្វើជាពន្លឺនៅក្នុងពិភពលោកនេះ ។ ជួយទ្រង់បង្កើនភ្លឺពន្លឺរបស់ទ្រង់ ដោយសេចក្តីសប្បុរសនិងសេចក្តីស្រឡាញ់ជារៀងរាល់ថ្ងៃ ។

ការសិក្សាបន្ថែម
ម៉ាថាយ 5:14-16



ថ្ងៃពុធ ទី៨ ខែតុលា

ខ្ញុំនឹងចែករំលែកសារ

យ៉ូហាន 1:6-7 (ពគប)
[6]មានម្នាក់ឈ្មោះយ៉ូហាន ដែលព្រះទ្រង់ចាត់ឲ្យមក [7]អ្នកនោះបានមកសំរាប់ជាទីបន្ទាល់ ដើម្បីនឹងធ្វើបន្ទាល់ពីពន្លឺ ប្រយោជន៍ឲ្យមនុស្សទាំងអស់បានជឿ ដោយសារគាត់ ។

គាំងពីយូរយារណាស់មកហើយ មានបុរសម្នាក់ឈ្មោះយ៉ូហានបាទីស្ទ ។ គាត់គឺជាអ្នកនាំសារ ។ សម្លៀកបំពាក់របស់គាត់ ធ្វើពីរោមអូដ្ឋ ហើយគាត់បានទទួលទានកណ្ដូប និងទឹកឃ្មុំព្រៃ ។ ការងាររបស់គាត់គឺប្រាប់មនុស្សគ្រប់គ្នា អំពីព្រះយេស៊ូវ ។ ស្តាប់ទៅចម្លែកបន្តិចមែនទេ? ប៉ុន្តែយ៉ូហានមិនខ្វល់ពីម៉ូដ និងអាហារទេ ។ បេសកកម្មរបស់គាត់ នៅលើផែនដីនេះគឺធំដុំាង ។ គាត់បានមកដើម្បីរៀបចំ មនុស្សគ្រប់គ្នាសម្រាប់ព្រះយេស៊ូវ ដែលជាពន្លឺនៃពិភពលោកនេះ ។

យ៉ូហានមានចិត្តក្លាហាន និងមិនភ័យខ្លាចឡើយ ។ គាត់បានប្រាប់មនុស្ស ឱ្យជឿលើព្រះយេស៊ូវ ហើយងាកមករកព្រះវិញ ។ មនុស្សជាច្រើនបានស្តាប់ ហើយប្រែមករកព្រះវិញ ។ ជីវិតរបស់គាត់បានបង្ហាញយើងថា យើងអាចជាអ្នកនាំសារ ដ៏ក្លាហានសម្រាប់ព្រះផងដែរ ។ អ្នកគឺជាអ្នកនាំសាររបស់ព្រះ ជាអ្នកបំភ្លឺពន្លឺរបស់ទ្រង់ ហើយប្រាប់អ្នកដទៃ អំពីសេចក្តីស្រឡាញ់របស់ទ្រង់ គ្រប់ទីកន្លែងដែលអ្នកទៅ!

សេចក្តីប្រកាសពីបទទំនាយ
ខ្ញុំជាអ្នកនាំសារ ដែលមិនខ្លាចចំពោះព្រះយេស៊ូវ ។ ពន្លឺរបស់ទ្រង់បំភ្លឺតាមរយៈខ្ញុំ ហើយខ្ញុំនឹងប្រាប់អ្នកផ្សេងទៀត អំពីសេចក្តីស្រឡាញ់របស់ទ្រង់ ។ ហាលេលូយ៉ា! អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ សូមទ្រង់ជួយទូលបង្គំ ឱ្យធ្វើដូចជាយ៉ូហាន ហើយប្រាប់អ្នកដទៃ រួមទាំងមិត្តភក្តិ និងក្រុមគ្រួសាររបស់ទូលបង្គំ អំពីព្រះយេស៊ូវគ្រីស្ទដែលជាពន្លឺដ៏ពិត ។

ការសិក្សាបន្ថែម
ម៉ាកុស 1:6



ថ្ងៃព្រហស្បតិ៍ ទី9 ខែតុលា

ដំណើរផ្សងព្រេងដ៏អស្ចារ្យបំផុតរបស់នាងរស់

នាងរស់ 1:16 (ពគប)
តែនាងឆ្លើយថា សូមកុំទទូចឲ្យខ្ញុំទៅចោលអ្នកម្តាយ នឹងវិលទៅវិញ លែងតាមអ្នកម្តាយនោះឡើយ ដ្បិតកន្លែងណាដែលអ្នកម្តាយអញ្ជើញទៅ នោះខ្ញុំនឹងទៅតាម ហើយកន្លែងដែលអ្នកម្តាយស្នាក់នៅ នោះខ្ញុំក៏នឹងនៅដែរ សាសន៍របស់អ្នកម្តាយ នឹងបានជាសាសន៍របស់ខ្ញុំ ហើយព្រះរបស់អ្នកម្តាយនឹងបានជាព្រះរបស់ខ្ញុំដែរ។

តើអ្នកធ្លាប់មានមិត្តភ័ក្តិ ដែលនៅជាមួយអ្នកដែរឬទេ? នេះជាអ្វីដែលនាងរស់បានធ្វើ! នាងរស់ជាស្ត្រីម្នាក់ ដែលស្រឡាញ់និងយកចិត្តទុកដាក់ ចំពោះម្តាយក្មេករបស់នាង ឈ្មោះថាណាអូមី។ ពេលណាអូមីសោកសៅ ហើយចង់ត្រឡប់ទៅផ្ទះវិញ នាងរស់មានជម្រើសមួយគឺ ស្នាក់នៅកន្លែងណាស្រួល ឬទៅជាមួយណាអូមី ហើយទុកចិត្តលើព្រះ។

នាងបាននិយាយថា «កន្លែងដែលអ្នកទៅ ខ្ញុំនឹងទៅ... ហើយព្រះរបស់អ្នក នឹងក្លាយជាព្រះរបស់ខ្ញុំ»។ នោះជាជម្រើសដ៏ធំ! នាងរស់បានបង្ហាញ សេចក្តីស្រឡាញ់ភ្លាមៗស្មោះត្រង់ និងសេចក្តីជំនឿ។ នាងមិនដឹងថា នឹងមានអ្វីកើតឡើងបន្ទាប់ទេ ប៉ុន្តែនាងជ្រើសថាថា ព្រះនឹងមើលថែពួកគេ ហើយទាយមើលថាមានអ្វីកើតឡើង? ទ្រង់បានធ្វើអ្វី! ដោយសារនាងរស់នៅតែស្មោះត្រង់ ព្រះបានប្រទានពរដល់នាងតាមរបៀបដ៏អស្ចារ្យ។ នាងបានក្លាយជាសមាជិក នៃគ្រួសាររបស់ព្រះយេស៊ូវ!

នាងរស់ឯងទុកចិត្តព្រះ ហើយបានដឹងថា មានរឿងដ៏អស្ចារ្យនៅខាងមុខ។ ព្រះបានដឹកនាំពួកគេ ទៅកាន់ដំណើរផ្សងព្រេងដ៏អស្ចារ្យ ហើយជីវិតរបស់ពួកគេពោរពេញទៅដោយព្រះពរជាច្រើន។ អ្នកក៏មានព្រះនៅក្នុងអ្នកដែរ ដូច្នេះហើយអ្នកនឹងមិនប្រឈមមុខ នឹងការធ្វើដំណើរបស់អ្នកតែម្នាក់ឯងឡើយ។

សេចក្តីប្រកាសពីបទទំនាយ
ឱព្រះអម្ចាស់អើយ ទូលបង្គំជឿជាក់លើទ្រង់ ដើម្បីដឹកនាំទូលបង្គំ ទៅភ្នាន់ដំណើរផ្សងព្រេង ដ៏គួរឱ្យរំភើបបំផុត ហើយទូលបង្គំត្រៀមខ្លួនជាស្រេច ដើម្បីដើរតាមទ្រង់គ្រប់ទីកន្លែង។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ សូមទ្រង់ជួយទូលបង្គំឱ្យស្រឡាញ់ និងនៅជាប់នឹងអ្នកដទៃដូចជានាងរស់បានធ្វើ ហើយតែងតែដើរតាមទ្រង់គ្រប់កន្លែង ដែលទ្រង់ដឹកនាំទូលបង្គំ។ អាម៉ែន។

ការសិក្សាបន្ថែម
នាងរស់ 2:12



ថ្ងៃសុក្រ ទី10 ខែតុលា

ការបដិសេធដោយខ្លួនឯង

យ៉ូហាន 1:10-11 (ពគប)
[10]ទ្រង់បានគង់ក្នុងលោកីយ ហើយលោកីយក៏កើតឆ្អែកដោយសារទ្រង់ តែមិនស្គាល់ទ្រង់ទេ [11]ទ្រង់បានយាងមកគង់នៅផែនដីរបស់ទ្រង់ តែរាស្ត្រទ្រង់មិនបានទទួលទ្រង់សោះ ។

កូនៗអើយ ស្តាប់តាមនេះ ព្រះគម្ពីរប្រាប់យើងថា ទោះជាព្រះយេស៊ូវ បានបង្កើតពិភពលោក ក៏មនុស្សជាច្រើនមិនទទួលស្គាល់ទ្រង់ នៅពេលទ្រង់យាងមក! ទ្រង់បានយាងមកឯរាស្ត្ររបស់ទ្រង់ គឺសាសន៍អ៊ីស្រាអែល ប៉ុន្តែគេមិនទទួលទ្រង់ទេ ។ ព្រះយេស៊ូវដែលបានបង្កើតអ្វីគ្រប់យ៉ាង ទ្រង់យាងមកដើម្បីបង្ហាញសេចក្តីស្រឡាញ់របស់ទ្រង់ ហើយសង្គ្រោះមនុស្សគ្រប់គ្នា ប៉ុន្តែមិនមែនពួកគេទាំងអស់យល់ថាទ្រង់ជានរណានោះទេ ។

ទោះជាមនុស្សមួយចំនួន មិនបានស្វាគមន៍ព្រះយេស៊ូវក៏ដោយ ទ្រង់នៅតែស្រឡាញ់ពួកគេ ។ រឿងនេះរំឭកយើងថា ព្រះយេស៊ូវជាអ្នកបង្កើតគ្រប់យ៉ាង ហើយទ្រង់ចង់ធ្វើជាមិត្តរបស់យើង ។ សូម្បីតែនៅពេលដែលមនុស្សមិនស្គាល់ទ្រង់ ទ្រង់តែងតែត្រៀមខ្លួន ជាស្រេចដើម្បីស្រឡាញ់ និងជួយយើង ប្រសិនបើយើងបើកចិត្តរបស់យើងចំពោះទ្រង់ ។ យើងអាចជ្រើសរើស ដើម្បីស្វាគមន៍ព្រះយេស៊ូវចូលមកក្នុងជីវិតរបស់យើង ហើយចែកចាយ សេចក្តីស្រឡាញ់របស់ទ្រង់ជាមួយអ្នកដទៃ!

សេចក្តីប្រកាសពីបទទំនាយ

ឱព្រះអម្ចាស់អើយ សូមអរព្រះគុណចំពោះព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់ និងជាព្រះអង្គសង្គ្រោះរបស់ខ្ញុំ! ពន្លឺរបស់ទ្រង់បំពេញចិត្តខ្ញុំ ហើយខ្ញុំនឹងដើរតាមទ្រង់អស់ពីចិត្ត ។ ហាលេលូយ៉ា ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ សូមអរព្រះគុណចំពោះ ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់ និងជាព្រះអង្គសង្គ្រោះរបស់ទូលបង្គំ! ពន្លឺរបស់ទ្រង់បំពេញចិត្តទូលបង្គំ ហើយទូលបង្គំនឹងដើរតាមទ្រង់អស់ពីចិត្ត ។ ហាលេលូយ៉ា ។ អាម៉ែន ។

ភារសិក្សាបន្ថែម
វិវរណៈ 3:20



ថ្ងៃសៅរ៍ ទី11 ខែតុលា

ខ្ញុំជាកូនរបស់ព្រះ

យ៉ូហាន 1:12 (ពគប)
ប៉ុន្តែអស់អ្នកណាដែលទទួលទ្រង់ គឺអស់អ្នកដែលជឿដល់ព្រះនាមទ្រង់ នោះទ្រង់បានប្រទានអំណាចឲ្យបានត្រឡប់ជាកូនព្រះ ។

តើអ្នកធ្លាប់ត្រូវបានគេជ្រើសរើស ឱ្យចូលរួមក្នុងក្រុមពិសេស ក្រុម ឬក្លឹបដែរឬទេ? វាពិតជាមាន អារម្មណ៍ល្អណាស់ ដែលត្រូវបានជ្រើសរើសមែនទេ?

កូនៗសូមឡាយមើលថាមានអ្វី? នៅពេលអ្នកជឿលើព្រះយេស៊ូវ អ្នកមិនត្រឹមតែត្រូវបានជ្រើសរើសសម្រាប់ក្រុមមួយប៉ុណ្ណោះទេ អ្នកក្លាយជាផ្នែកនៃគ្រួសារព្រះ ! ព្រះគម្ពីរចែងថា ពេលយើងទទួលយកព្រះយេស៊ូវ ហើយជឿលើទ្រង់ ទ្រង់ប្រទានឲ្យយើង មានសិទ្ធិធ្វើជាកូនរបស់ព្រះ ។ នោះមានន័យថាអ្នកត្រូវបានស្រឡាញ់ទទួលយក និងជាកម្មសិទ្ធិរបស់គ្រួសារ ដ៏អស្ចារ្យបំផុតដែលមិនធ្លាប់មាន!

អ្នកមិនចាំបាច់រករវាទេ ។ អ្នកមិនចាំបាច់ល្អឥតខ្ចោះទេ ។ អ្នកគ្រាន់តែត្រូវជឿលើព្រះយេស៊ូវ ហើយព្រះមានបន្ទូលថា «អ្នកជារបស់ខ្ញុំ!» ក្នុងនាមជាកូនរបស់ព្រះ អ្នកអាចនិយាយជាមួយទ្រង់គ្រប់ពេល ។ ទ្រង់ចូលចិត្តស្តាប់សំលេងរបស់អ្នក ។ ទ្រង់នឹងណែនាំអ្នក ការពារអ្នក និងជួយអ្នកឱ្យរីកចម្រើន ។ អ្នកគឺជាមនុស្សពិសេស និងជាទីស្រឡាញ់យ៉ាងខ្លាំង ដោយព្រះវរបិតាសួគ៌របស់អ្នក ។

សេចក្តីប្រកាសពីបទទំនាយ
ខ្ញុំជាកូនរបស់ព្រះ! ទ្រង់ស្គាល់ខ្ញុំតាមឈ្មោះ ស្រឡាញ់ខ្ញុំ ហើយខ្ញុំជាកម្មសិទ្ធិ របស់គ្រួសារទ្រង់ជារៀងរហូត ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះយេស៊ូវអើយ សូមអរព្រះគុណទ្រង់ ដែលអនុញ្ញាតឱ្យទូលបង្គំ ធ្វើជាកូនរបស់ទ្រង់ នៅពេលដែលទូលបង្គំជឿលើទ្រង់ ហើយធ្វើតាមទ្រង់ ។

ការសិក្សាបន្ថែម
រ៉ូម 8:16



ថ្ងៃអាទិត្យ ទី12 ខែតុលា

អ្នកដែលធំជាងខ្ញុំ

យ៉ូហាន 1:15 (ពគប)
ដ៏យ៉ូហានបានធ្វើបន្ទាល់ពីទ្រង់ ដោយបន្លឺឧទានឡើងថា គឺពីព្រះអង្គនេះហើយ ដែលខ្ញុំប្រាប់ថា ព្រះអង្គដែលយាងមកក្រោយខ្ញុំ ទ្រង់បានត្រឡប់ជាមុនខ្ញុំវិញ ដ្បិតទ្រង់គង់នៅមុនខ្ញុំ ។

តើអ្នកនៅចាំយ៉ូហានបាទីស្ទ ក្នុងព្រះគម្ពីរជាបុរស ដែលទទួលទានកណ្តូប និងទឹកឃ្មុំ ហើយពាក់អាវរោមអូដ្ឋទេ ។ គាត់មិនល្បីខាងអាហារ ដែលគាត់បានញ៉ាំទេ ។ គាត់ត្រូវបានគេស្គាល់ថាបានប្រាប់មនុស្សអំពីព្រះយេស៊ូវ! យ៉ូហានមានហ្វូងមនុស្សយ៉ាងច្រើន ដើរតាមគាត់នៅទីរហោស្ថាន ប៉ុន្តែគាត់មិនបាននិយាយថា «មើលមកខ្ញុំ ខ្ញុំពូកែបំផុត!»នោះទេ។ ផ្ទុយទៅវិញ គាត់បាននិយាយថា៖ «មានអ្នកខ្លាំងជាងកំពុងយាងមក!» ។ ថ្ងៃមួយ ព្រះយេស៊ូវយាងមក! យ៉ូហានរំភើបចិត្តខ្លាំងណាស់ ។ គាត់ប្រហែលជាចង់ស្រែកថា «គឺទ្រង់នេះហើយ! ព្រះអង្គដែលខ្ញុំកំពុងតែនិយាយ!» ។ យ៉ូហានបានដឹងថា ព្រះយេស៊ូវគឺជាមនុស្សសំខាន់បំផុតនៃអ្វីទាំងអស់ ។

តើអ្នកនឹងអនុញ្ញាត ឱ្យព្រះយេស៊ូវជំនួសកន្លែងរបស់គាត់ ឬតើអ្នកនឹងព្យាយាមធ្វើជាតារាដែរទេ? ចូរធ្វើដូចលោកយ៉ូហាន ហើយដឹងថា មានព្រះអង្គដែលធំជាងអ្នកហើយនឹងខ្ញុំ ហើយនេះគឺជាព្រះគ្រីស្ទយេស៊ូវ ។

សេចក្តីប្រកាសពីបទទំនាយ
ឱព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទគឺជាកំពូលតារា ។ ខ្ញុំជ្រើសរើសតម្រង់ទៅទ្រង់ ក្នុងគ្រប់អ្វីដែលខ្ញុំនិយាយ និងធ្វើ ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ សូមអរព្រះគុណទ្រង់ សម្រាប់ការបញ្ជូនព្រះយេស៊ូវ ដែលធំជាងអ្នកណាទាំងអស់ មកបង្ហាញឲ្យពួកយើងនូវសេចក្តីពិត និងសេចក្តីស្រឡាញ់របស់ទ្រង់ ។

ការសិក្សាបន្ថែម
ភីលីព 2:9-10



ថ្ងៃចន្ទ ទី13 ខែតុលា

ក្លាហានដូចនាងអេសធើរ

អេសធើរ 4:14 (ពគប)
ដ្បិតបើព្រះនាងនឹងស្ងៀមនៅក្នុងវេលានេះ នោះនឹងកើតមានសេចក្ដីសង្គ្រោះ នឹងសេចក្ដីប្រោសឲ្យរួច ដល់ពួកយូដាពីកន្លែងផ្សេងទៀត តែព្រះនាង និងញាតិវង្សរបស់បិតានៃព្រះនាង នឹងត្រូវវិនាសវិញ ហើយប្រហែលជាព្រះនាងបានតាំងឡើងក្នុងរាជ្យ សំរាប់ពេលនេះឯងទេដឹង ។


ក្នុងគម្ពីរ នារីក្លាហានម្នាក់ឈ្មោះ នាងអេសធើរ ត្រូវបានជ្រើសរើសឱ្យធ្វើជា អគ្គមហេសី។ ថ្ងៃមួយ បុរសម្នាក់ឈ្មោះ ហាម៉ាន បានរៀបចំផែនការដើម្បីធ្វើបាបរាស្ត្ររបស់ព្រះ ដែលជាជនជាតិយូដា ។ នាងអេសធើរគឺជាម្នាក់ក្នុងចំណោមពួកគេ ។ បងប្អូនជូនមួយរបស់នាង ម៉ាដេកាយ បានប្រាប់នាងថា ប្រហែលជាព្រះបានបង្កើត មហាក្សត្រីរបស់នាង «សម្រាប់ពេលវេលាបែបនេះ» ដើម្បីជួយសង្គ្រោះប្រជាជនរបស់នាង!

នាងអេសធើរខ្លាច ប៉ុន្តែនាងជឿលើព្រះ ។ នាងបាននិយាយទៅកាន់ស្តេច ហើយព្រះបានប្រើនាង ដើម្បីសង្គ្រោះប្រជាជនរបស់នាង ។ អើយ៉ា! តើនាងបានធ្វើអ្វីបែក! ដូចនាងអេសធើរ អ្នកត្រូវបានបង្កើតឡើងសម្រាប់ គោលបំណងពិសេសមួយ ។ អ្នកមិនក្មេងពេក ក្នុងការធ្វើកិច្ចការធំៗថ្វាយព្រះទេ! ប្រហែលជាព្រះដាក់អ្នក នៅក្នុងគ្រួសាររបស់អ្នក សាលារៀនរបស់អ្នក ឬព្រះវិហាររបស់អ្នក ដើម្បីបំភ្លឺពន្លឺរបស់ទ្រង់ និងជួយអ្នកដទៃ ។ នៅពេលអ្នកឃើញអ្វីមួយខុស ឬនរណាម្នាក់ដែលត្រូវការជំនួយ ចូរកុំនៅស្ងៀម ។ ចូរអធិដ្ឋាន ហើយសុំព្រះឲ្យមានចិត្តក្លាហាន ដូចនាងអេសធើរដែរ!

សេចក្តីប្រកាសពីបទទំនាយ
ខ្ញុំនឹងរឹងមាំដូចនាងអេសធើរ ។ ទោះបីជាខ្ញុំមានអារម្មណ៍ភ័យខ្លាចក៏ដោយ ខ្ញុំនឹងជ្រើសរើសធ្វើអ្វី ដែលត្រឹមត្រូវ ព្រោះព្រះគង់នៅជាមួយខ្ញុំ ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ សូមជួយទូលបង្គំឱ្យក្លាហានដូចនាងអេសធើរ ហើយធ្វើនូវអ្វីដែលត្រឹមត្រូវ ដោយដឹងថាទ្រង់បានបង្កើតទូលបង្គំ ក្នុងគោលបំណងដ៏ពិសេសមួយ ។

ការសិក្សាបន្ថែម
អេសាយ 41:10



ថ្ងៃអង្គារ ទី14 ខែតុលា

ព្រះគង់នៅជាមួយខ្ញុំ

1 សាំយូអែល 17:34-35 (ពគប)
[34]នោះដាវីឌជំរាបលោលួងទូលសួលថា ពីដើមដែលទូលបង្គំ ជាបាវបំរើទ្រង់ ធ្លាប់ឃ្វាលចៀមរបស់ឪពុក នោះបើណាដែលមានសឹង្ហ ឬខ្លាឃ្មុំ មកចាប់យកកូនចៀមពីហ្វូងទៅ [35]ទូលបង្គំក៏ដេញតាមប្រហារវា ដោះចៀមនោះឲ្យរួចចេញពីមាត់វាមក បើកាលណាវាស៊ុះមកលើទូលបង្គំ នោះទូលបង្គំបានចាប់វាត្រង់ពុកចង្កាវាយសំឡាប់ទៅ ។

តើអ្នកធ្លាប់ធ្វើអ្វីមួយ ដែលមានអារម្មណ៍គួរឱ្យខ្លាច ដូចជានិយាយ នៅមុខថ្នាក់របស់អ្នក ឬឈរចាំនំណាម្នាក់ទេ? នោះហើយជារឿង ដែលមនុស្សភាគច្រើន នឹងមានអារម្មណ៍ ប្រសិនបើ តោ ឬ ខ្លាឃ្មុំ មកជិតពួកគេ! ប៉ុន្តែមិនមែនទេ។ ដាវីឌ ។


ដាវីឌជាក្មេងគង្វាល ដែលធ្វើលថៃចៀមរបស់ឪពុកគាត់ ។ គាត់មិនមែនជាអ្នកចម្បាំង ឬជាទាហានទេ ។ ប៉ុន្តែនៅពេលដែលគ្រោះថ្នាក់មកដល់ គាត់ដូច្នោតោ ឬខ្លាឃ្មុំ ដាវីឌមិនបានរត់ទៅណាទេ ។ គាត់បានឈរឆ្ពោះទៅរក គ្រោះថ្នាក់ដើម្បីការពារចៀម ។ ហេតុអ្វី? ដោយសារតែដាវីឌ ក្លាហាន ហើយគាត់បានទុកចិត្តព្រះដើម្បីជួយគាត់ ។ ក្រោយមក ពេលដាវីឌ ប្រឈមមុខនឹងកូលីយ៉ាតយក្ស គាត់នឹកឃើញពីរឿងដែលព្រះ បានជួយគាត់ប្រយុទ្ធនឹងតោ និងខ្លាឃ្មុំ។ នោះក៏ធ្វើឲ្យគាត់មានភាពក្លាហានប្រឈមមុខនឹងយក្សដែរ!

ដាវីឌបង្រៀនយើងថា ភាពក្លាហានមិនមែនមានន័យថា អ្នកមិនខ្លាចទេ វាមានន័យថាអ្នកទុកចិត្តព្រះសូម្បីតែនៅពេលដែលអ្នកខ្លាច! មិនថាអ្នកតូច ឬបញ្ហាធំប៉ុណ្ណាទេ ព្រះអាចជួយអ្នកឲ្យក្លាហាន ។ មិនថាការគ្រោកឈរ សម្រាប់អ្នកណាម្នាក់ អង្វរស្មានខ្លាំងៗ ឬធ្វើអ្វីដែលត្រឹមត្រូវទេ អ្នកអាចធ្វើដូចដាវីឌ ហើយប្រឈមមុខ នឹងវាដោយចិត្តក្លាហាន!

សេចក្តីប្រកាសពីបទទំនាយ
ឱព្រះអម្ចាស់អើយ សូមអរព្រះគុណទ្រង់ ដែលបានជួយដាវីឌឲ្យក្លាហាន ។ សូមជួយខ្ញុំឲ្យក្លាហានផងដែរ ទោះបីជាមានអារម្មណ៍គួរឲ្យខ្លាចក៏ដោយ ។ ខ្ញុំដឹងថាទ្រង់គង់នៅជាមួយខ្ញុំ ហើយខ្ញុំអាចទុកចិត្តទ្រង់ជានិច្ច ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ សូមជួយទូលបង្គំ ឱ្យក្លាហានដូចជាដាវីឌ ហើយជឿទុកចិត្តទ្រង់ ដើម្បីជួយទូលបង្គំ ក្នុងគ្រប់ស្ថានការណ៍ដ៏លំបាក ។

ការសិក្សាបន្ថែម
សុភាសិត 3:5-6



ថ្ងៃពុធ ទី15 ខែតុលា

សំណួរដ៏ធំរបស់ស្តេចសាឡូម៉ូន

1 ពង្សាវតារក្សត្រ 3:9 (ពគប)
ដូច្នេះ សូមទ្រង់ប្រទានឲ្យទូលបង្គំ ជាបាវបំរើទ្រង់ មានចិត្តប្រកបដោយប្រាជ្ញា ដើម្បីនឹងគ្រប់គ្រងលើរាស្ត្រទ្រង់ ប្រយោជន៍ឲ្យទូលបង្គំបានពិចារណាដឹងខុសត្រូវ ដ្បិតតើមានអ្នកណាអាចនឹងគ្រប់គ្រងលើរាស្ត្រទ្រង់ ដែលមានគ្នាច្រើនទាំងនេះបាន ។


ស្តេចសាឡូម៉ូនមានសុបិនមួយ ប៉ុន្តែនេះមិនមែន គ្រាន់តែជាសុបិននោះទេ ។ វាជាសុបិនដែលមាន ទំហំប៉ុនព្រះ ។ ព្រះទ្រង់មានព្រះបន្ទូលសួរថា៖ «សាឡូម៉ូន តើអ្នកចង់បានអ្វី? ប្រសិនបើព្រះអម្ចាស់សួរអ្នកនោះ តើអ្នកនឹងសុំអ្វី?

សាឡូម៉ូនទូលថា៖ «ព្រះអម្ចាស់អើយ សូមប្រទានប្រាជ្ញាដល់ទូលបង្គំ ដើម្បីឲ្យទូលបង្គំអាចដឹកនាំរាស្ត្រទ្រង់បានល្អ» ។ អីយ៉ា! ព្រះសព្វព្រះហឫទ័យ និងចម្លើយរបស់សាឡូម៉ូន ដែលទ្រង់ប្រទានប្រាជ្ញា ទ្រព្យសម្បត្តិ កិត្តិយស និងភាពជោគជ័យដល់គាត់! សាឡូម៉ូនបានក្លាយជាស្តេច ដែលមានប្រាជ្ញាបំផុតមិនធ្លាប់មាន ដោយបានជួយមនុស្ស ឲ្យដោះស្រាយបញ្ហា ដែលពិបាក និងធ្វើការសម្រេចចិត្តដ៏អស្ចារ្យ ។ ពេលអ្នកមិនដឹងថា ត្រូវធ្វើអ្វី អ្នកអាចសុំព្រះប្រាជ្ញាដូចសាឡូម៉ូន ។ ព្រះចូលចិត្តជួយកូនចៅរបស់ទ្រង់ ធ្វើការជ្រើសរើសដ៏ល្អ ។

សេចក្តីប្រកាសពីបទទំនាយ
ឱព្រះវរបិតា សូមអរព្រះគុណទ្រង់ ដែលទ្រង់ប្រទានព្រះវិញ្ញាណនៃប្រាជ្ញា និងការយល់ដឹងដល់ទូលបង្គំ ដោយព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ ទូលបង្គំមិនអាចមានគុណវិបត្តិឡើយ ។ ហាលេលូយ៉ា ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ សូមទ្រង់ប្រទាននូវចិត្តប្រកបដោយប្រាជ្ញា ដើម្បីដឹងនូវអ្វីដែលត្រូវ និងធ្វើការជ្រើសរើសល្អជារៀងរាល់ថ្ងៃ ។

ការសិក្សាបន្ថែម
យ៉ាកុប 1:5



ថ្ងៃព្រហស្បតិ៍ ទី16 ខែតុលា

ព្រះយេស៊ូវនៅក្នុងព្រះវិហារ

លូកា 2:49 (ពគប)
ទ្រង់មានបន្ទូលតបថា អ្នកម្តាយអើយ ខ្ញុំធ្វើអី តើមិនជ្រាបថា គួរឲ្យខ្ញុំនៅក្នុងព្រះវិហាររបស់ព្រះវរបិតានៃខ្ញុំទេឬអី ។

តើអ្នកធ្លាប់ផ្តោតខ្លាំងលើអ្វី ដែលអ្នកស្រឡាញ់ ដូចជាការគូររូប ការអាន ឬការសាងសង់ដោយបួក ដែលអ្នកមិនបានកត្តិសម្គាល់ថា ពេលវេលាកន្លងផុតទៅនោះទេ? នោះជាប្រភេទនៃអ្វី ដែលបានកើតឡើង ជាមួយព្រះយេស៊ូវនៅក្មេង! ពេលព្រះយេស៊ូវមានព្រះជន្ម១២ឆ្នាំ គ្រួសារទ្រង់បានធ្វើដំណើរទៅក្រុងយេរូសាឡិម ។ បន្ទាប់ពីការធ្វើដំណើរ ឪពុកម្តាយរបស់ទ្រង់ ចាប់ផ្តើមធ្វើដំណើរទៅផ្ទះ... ប៉ុន្តែព្រះយេស៊ូវ ទ្រង់គង់នៅខាងក្រោយ! តើទ្រង់នៅឯណា? នៅក្នុងព្រះវិហារ នីយាយជាមួយគ្រូអំពីព្រះ ។


ពេលឪពុកម្តាយរបស់ទ្រង់ បានរកឃើញទ្រង់ ទ្រង់បានមានបន្ទូលអ្វីមួយដ៏អស្ចារ្យថា ៖ «អ្នកម្តាយរកខ្ញុំធ្វើអ្វី តើមិនជ្រាបថា គួរឲ្យខ្ញុំនៅក្នុងព្រះវិហាររបស់ព្រះវរបិតានៃខ្ញុំទេឬអី?» សូម្បីតែទ្រង់នៅក្មេង ព្រះយេស៊ូវទ្រង់ជ្រាបថា ទ្រង់នៅទីនេះសម្រាប់គោលបំណងដ៏ពិសេសមួយ ដើម្បីធ្វើអ្វីដែលព្រះអម្ចាស់ ដែលជាព្រះវរបិតាចង់បាន ។

ដូចព្រះយេស៊ូវដែរ អ្នកក៏រស់នៅទីនេះ ក្នុងគោលបំណងដែរ! ទោះបីជាអ្នកនៅក្មេងក៏ដោយ អ្នកអាចធ្វើកិច្ចការរបស់ព្រះ ដូចជាមានចិត្តសប្បុរស ប្រាប់អ្នកដទៃអំពីព្រះយេស៊ូវ អធិស្ឋាន និងជួយមនុស្សដែលត្រូវការជំនួយ ។ ព្រះមិនរង់ចាំរហូតដល់អ្នកធំពេញវ័យដើម្បីប្រើអ្នកនោះទេ ។ ទ្រង់ចង់ប្រើអ្នកឥឡូវនេះ ! ដូច្នេះ ជារឿងរាល់ថ្ងៃ សូមសួរខ្លួនអ្នកថា «តើថ្ងៃនេះខ្ញុំអាចធ្វើអ្វី ដើម្បីឲ្យព្រះញញឹម?»

សេចក្តីប្រកាសពីបទទំនាយ
ខ្ញុំចូលចិត្តចំណាយពេលជាមួយព្រះអម្ចាស់ ហើយនៅក្នុងដំណាក់របស់ទ្រង់ ។ វាជាសេចក្តីរីករាយក្នុងការបម្រើព្រះអម្ចាស់ ហើយខ្ញុំនឹងបំពេញកិច្ចការរបស់ព្រះនៅក្នុងជីវិតរបស់ខ្ញុំ ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះយេស៊ូវអើយ សូមជួយទូលបង្គំចាំថា ការនៅជិតទ្រង់ ហើយធ្វើអ្វីដែលទ្រង់ចង់បាន គឺជារឿងសំខាន់បំផុត ។

ការស៊ើកឃ្សាបន្ថែម
1 ធីម៉ូថេ 4:12



ថ្ងៃសុក្រ ទី17 ខែតុលា

ពិភពលោកទាំងមូលកំពុងរង់ចាំ

រ៉ូម 8:19 (ពគប)
ដ្បិតសេចក្តីទន្ទឹងរបស់ជីវិតទាំងឡាយ នោះរង់ចាំតែពួកកូនរបស់ព្រះលេចមក ឲ្យឃើញប៉ុណ្ណោះទេ ។

កូនៗតើអ្នកធ្លាប់រំភើបចិត្ត នៅពេលរង់ចាំអ្វី ដែលធំនឹងកើតឡើង ដូចជាថ្ងៃខួបកំណើត ការធ្វើដំណើរទៅសាលា ឬព្រឹកថ្ងៃបុណ្យណូអែលដែរឬទេ? អ្នកមានអារម្មណ៍ដូចជា មិនអាចរង់ចាំបានដែរទេ?

តើអ្នកដឹងទេថា ពិភពលោកទាំងមូល សូម្បីតែដើមឈើ សត្វ សមុទ្រ និងមេឃ កំពុងរង់ចាំ ដោយក្តីរំភើបផងដែរ? តើពួកគេកំពុងរង់ចាំអ្វី? ពួកគេកំពុងរង់ចាំអ្នក ជាកូនរបស់ព្រះ ដើម្បីបង្ហាញ និងបំភ្លឺសម្រាប់ទ្រង់!

នៅពេលដែលអ្នកស្រឡាញ់ព្រះយេស៊ូវ ហើយរស់នៅសម្រាប់ទ្រង់ នោះអ្នកជួយពិភពលោកឱ្យឃើញ នូវអ្វីដែលព្រះទ្រង់មាន ។ នោះជារឿងធំ! ផែនដីកំពុងលើកទឹកចិត្តអ្នក ដោយសង្ឃឹមថា អ្នកនឹងក្លាហាន ចិត្តល្អ មានសេចក្តីស្រឡាញ់ និងពេញដោយសេចក្តីជំនឿ ដូចជាព្រះយេស៊ូវ ។ អ្នកមិនមែនគ្រាន់តែជាក្មេងទេ ។ អ្នកគឺជាកូនរបស់ព្រះ ហើយការបង្កើតទាំងអស់ មានការរំភើបចិត្តដែលឃើញព្រះធ្វើការនៅក្នុងអ្នក និងតាមរយៈអ្នក ។ អ្នកអាចធ្វើឱ្យមាន ភាពខុសប្លែកគ្នានៅក្នុងផ្ទះ សាលារៀន និងសូម្បីតែនៅក្នុងពិភពលោកឥឡូវនេះ!

សេចក្តីប្រកាសពីបទទំនាយ
ខ្ញុំជាកូនរបស់ព្រះ ហើយខ្ញុំនឹងបង្ហាញសេចក្តីស្រឡាញ់ និងសេចក្តីអំណាររបស់ទ្រង់ដល់ពិភពលោក! ហាលេលូយ៉ា ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ ជួយទូលបង្គំឱ្យរស់នៅតាមរបៀបដែលបង្ហាញថា ទូលបង្គំជាកម្មសិទ្ធិរបស់ទ្រង់ ហើយជួយពិភពលោកឱ្យឃើញ សេចក្តីស្រឡាញ់របស់ទ្រង់តាមរយៈទូលបង្គំ ។ អាម៉ែន ។

ការសិក្សាបន្ថែម
រ៉ូម 8:21



ថ្ងៃសៅរ៍ ទី18 ខែតុលា

ខ្ញុំនឹងសរសើរតម្កើងព្រះអម្ចាស់

ទំនុកដំកើង 34:1 (ពគប)
ខ្ញុំនឹងលើកសរសើរដល់ព្រះយេហូវ៉ាគ្រប់ ពេលវេលា សេចក្តីសរសើរពីទ្រង់នឹងនៅក្នុងមាត់ខ្ញុំជានិច្ច ។


នៅក្នុងបទគម្ពីរសព្វថ្ងៃនេះ ដាវីឌមានប្រសាសន៍ថា «ខ្ញុំនឹងលើកសរសើរដល់ព្រះយេហូវ៉ាគ្រប់ ពេលវេលា សេចក្តីសរសើរពីទ្រង់នឹងនៅក្នុងមាត់ខ្ញុំជានិច្ច» ។ នេះមានន័យថា ដាវីឌបានសន្យាថា នឹងអរព្រះគុណនិងសរសើរព្រះអម្ចាស់ ទោះជាមានអ្វីកើតឡើងក៏ដោយ ។ សូម្បីតែពេលមានការលំបាកក៏ដោយ ដាវីឌបានឮដំសេចចាំថា តើព្រះទ្រង់ល្អប៉ុណ្ណា ហើយអរព្រះគុណទ្រង់ ។ ដាវីឌបានដឹងថា ព្រះទ្រង់តែងតែគង់នៅជាមួយគាត់ ដោយជួយគាត់ឆ្លងកាត់គ្រាលំបាក ។

បទគម្ពីរនេះបង្រៀនយើងថា យើងអាចសរសើរតម្កើងព្រះជារៀងរាល់ថ្ងៃ ក្នុងពេលសប្បាយ និងពេលលំបាក ។ ពេលយើងចង់ចាំថា ព្រះទ្រង់ស្រឡាញ់យើងប៉ុណ្ណា នោះយើងអាចដឹងគុណ ហើយទុកចិត្តទ្រង់ ។ ដូចដាវីឌដែរ យើងអាចនិយាយថា «សូមអរព្រះគុណ» ចំពោះព្រះអម្ចាស់ ហើយបន្តសរសើរទ្រង់ដោយសេចក្តីអំណរ មិនថាមានអ្វីកើតឡើង ក្នុងជីវិតរបស់យើងឡើយ!

សេចក្តីប្រកាសពីបទទំនាយ
ខ្ញុំគ្រប់គ្រងលើគំនិត និងអារម្មណ៍របស់ខ្ញុំ ហើយខ្ញុំជ្រើសរើស យកសេចក្តីអំណរអរ! ខ្ញុំនឹងសរសើរព្រះអម្ចាស់ជានិច្ច ចំពោះអ្វីដែលទ្រង់បានធ្វើសម្រាប់ខ្ញុំ ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ ទូលបង្គំនឹងសរសើរតម្កើងព្រះអង្គជានិច្ច ហើយរីករាយ ព្រោះព្រះអង្គមើលថែទូលបង្គំជារៀងរាល់ថ្ងៃ ។ អាម៉ែន ។

ការសិក្សាបន្ថែម
ទំនុកដំកើង 118:24



ថ្ងៃអាទិត្យ ទី19 ខែតុលា

ព្រះយេស៊ូវនៅរកការសង្គ្រោះ

លូកា 19:10 (ពគប)
ដ្បិតកូនមនុស្សបានមក ដើម្បីនឹងរក ហើយជួយសង្គ្រោះ ដល់មនុស្សបាត់បង់ ។

នៅក្នុងព្រះគម្ពីរ ព្រះយេស៊ូវត្រូវបានគេហៅថា ជាកូនមនុស្ស ហើយទ្រង់បានយាងមកផែនដីសម្រាប់ហេតុផលពិសេសមួយ ដើម្បីស្វែងរកមនុស្ស ដែលមានអារម្មណ៍ថា បាត់បង់ ហើយនាំពួកគេត្រឡប់ទៅរកព្រះវិញ ។ មានន័យថា អ្នកណា ដែលមិនស្គាល់សេចក្តីស្រឡាញ់របស់ព្រះ ឬមានអារម្មណ៍ថា នៅឆ្ងាយពីទ្រង់ គឺជាអ្នកដែលព្រះយេស៊ូវបានមកសង្គ្រោះ ។

ហើយស្មានថាដូចម្តេច? ពេលមនុស្សម្នាក់និយាយថា «បាទ/ចាស!» ដល់ព្រះយេស៊ូវ នៅអស់ទាំងស្មានសួគ៌ប្រារព្ធពិធី ដូចជាអ្នកអបអរ ការស្វែងរករបស់លេង ដែលបាត់របស់អ្នក!

ព្រះយេស៊ូវបានយាងមកដើម្បីស្វែងរក និងជួយសង្គ្រោះមនុស្សគ្រប់គ្នា ហើយនោះរួមមានអ្នកផងដែរ ។ ប្រសិនបើអ្នកធ្លាប់មានអារម្មណ៍ដកោ ច្របូកច្របល់ ឬដូចជាអ្នកបានរញ្ជ្បរញ៉ៃ ព្រះយេស៊ូវទ្រង់គង់នៅទីនោះ ស្វែងរកអ្នក ត្រៀមខ្លួនដើម្បីនាំអ្នក មកវិញដោយសេចក្តីស្រឡាញ់ ។

ក្នុងនាមជាកូនរបស់ព្រះ អ្នកក៏អាចជួយបានដែរ! នៅពេលដែលអ្នកមានចិត្តល្អ នៅពេលអ្នកនិយាយអំពីព្រះយេស៊ូវ ឬនៅពេលអ្នកអធិស្ឋាន សម្រាប់អ្នកដទៃ អ្នកកំពុងជួយបង្ហាញ មនុស្សវង្វេងផ្លូវទៅផ្ទះវិញ ។

សេចក្តីប្រកាសពីបទទំនាយ
ឱព្រះអម្ចាស់ សូមអរព្រះគុណព្រះអង្គ ដែលបានយាងមក ដើម្បីស្វែងរក និងជួយសង្គ្រោះមនុស្សបាត់បង់ដូចខ្ញុំ ។ សូមជួយខ្ញុំឱ្យធ្វើតាមទ្រង់ ជារៀងរាល់ថ្ងៃ ហើយចែករំលែកក្តីស្រឡាញ់របស់ទ្រង់ទៅកាន់អ្នកដទៃ ។ ខ្ញុំចង់ជួយមនុស្ស ឱ្យស្គាល់ទ្រង់ដែរ! អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះយេស៊ូវអើយ សូមអរព្រះគុណទ្រង់ ដែលបានមករកទូលបង្គំ ហើយជួយទូលបង្គំ ពីព្រោះទ្រង់ស្រឡាញ់មនុស្សគ្រប់រូបខ្លាំងណាស់ ។

ការសិក្សាបន្ថែម
លូកា 19:1-10



ថ្ងៃចន្ទ ទី20 ខែតុលា

ដំណឹងល្អ

ម៉ាកុស 16:15 (ពគប)
ទ្រង់ផ្តាំគេថា ចូរអ្នករាល់គ្នាទៅពេញសព្វក្នុងលោកីយទាំងមូល ហើយ ផ្សាយដំណឹងល្អទូទៅដល់គ្រប់មនុស្សទាំងអស់ចុះ ។

ត្បើអ្នកធ្លាប់មានដំណឹង ដែលពិតជាគួរឱ្យរំភើបចិត្តថា អ្នកគ្រាន់តែមិនអាចរង់ចាំ ដើម្បីប្រាប់នរណាម្នាក់ដែរទេ? ប្រហែលជាអ្នកទទួលបាន សត្វចិញ្ចឹមថ្មី ឈ្នះរង្វាន់ ឬដុំណើរផ្សងព្រេងដ៏រីករាយ ។ តើវាជារឿងគួរអោយរីករាយ ក្នុងការចែករំលែកពត៌មានល្អមែនទេ?

វាជាការប្រសើរណាស់ ព្រះយេស៊ូវបានប្រទានមិត្តភក្តិរបស់ទ្រង់ ហើយនោះរួមបញ្ចូលអ្នកនិងខ្ញុំផងដែរ នៅការងារពិសេសមួយ៖ ប្រាប់ដំណឹងល្អអំពីទ្រង់ដល់អស់អ្នកគ្រប់គ្នា! តើមានដំណឹងល្អអ្វី? ថាព្រះយេស៊ូវស្រឡាញ់ មនុស្សគ្រប់គ្នា ទ្រង់បានសុគតសម្រាប់ អំពើបាបរបស់យើង ហើយទ្រង់មានព្រះជន្មរស់ឡើងវិញ ដើម្បីយើងអាចនៅជិតព្រះ ហើយមានជីវិតអស់កល្បជានិច្ច ។ ព្រះយេស៊ូវមិនបាន មានបន្ទូលប្រាប់តែម្នាក់ ឬពីរនាក់នោះទេ ទ្រង់មានបន្ទូលទៅគ្រប់ទីកន្លែង ហើយប្រាប់ទាំងអស់គ្នា !

សេចក្តីប្រកាសពីបទទំនាយ
នៅថ្ងៃនេះខ្ញុំនឹងចែកចាយដំណឹងល្អ ជាមួយនរណាម្នាក់ ពីព្រោះសេចក្តីស្រឡាញ់របស់ព្រះគ្រីស្ទ ដែលមានតម្លៃគួរចែករំលែក ។ សូមថ្វាយសិរីល្អដល់ព្រះអម្ចាស់ ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះយេស៊ូវអើយ សូមទ្រង់ជួយទូលបង្គំ ប្រាប់អ្នកដ៏ទៃអំពីទ្រង់ ដើម្បីឱ្យគេអាចដឹង ពីសេចក្តីស្រឡាញ់របស់ទ្រង់ ហើយរីករាយផងដែរ ។ អាម៉ែន ។

ការសិក្សាបន្ថែម
ម៉ាថាយ 28:19-20





ថ្ងៃអង្គារ ទី21 ខែតុលា

ចិត្តដែលពេញដោយអំណរគុណ

ភីលីព 2:14 (ពគប)
ចូរធ្វើគ្រប់ការទាំងអស់ដោយឥតត្អូញត្អែរ ឥតប្រកែក ។

តើអ្នកធ្លាប់ត្រូវបានគេ សុំឱ្យសម្អាតបន្ទប់របស់អ្នក ឬជួយកិច្ចការផ្ទះ ហើយឃើញថាខ្លួនឯងរអ៊ូរទាំ ឬនិយាយថា «តែខ្ញុំមិនចង់ធ្វើដែរទេ!»? អ្នកមិននៅម្នាក់ឯងទេ ។ ពេលខ្លះយើងទាំងអស់គ្នា មានអារម្មណ៍ថាចង់ត្អូញត្អែរ ពេលយើងមិនមានអារម្មណ៍ ចង់ធ្វើអ្វីមួយ ។ ប៉ុន្តែតើអ្នកដឹងទេថា ព្រះសុំឲ្យយើងធ្វើអ្វីៗ ដោយចិត្តរីករាយ?

ព្រះគម្ពីរចែងថា យើងគួរធ្វើគ្រប់យ៉ាង ដោយឥតត្អូញត្អែរ ឬឥតប្រកែកឡើយ ។ នោះមានន័យថា នៅពេលដែលម៉ាក់ ឬប៉ា សុំឱ្យអ្នកជួយ អ្នកធ្វើវាដោយស្មាមញ្ញឹម ជំនួសឱ្យការរងក់ក្បាល ។ នៅពេលយើងជ្រើសរើសភាពរីករាយ និងសន្តិភាព សូម្បីតែពេលខ្លះវាពិបាកក៏ដោយ យើងបំភ្លឺពន្លឺ របស់ព្រះអម្ចាស់សម្រាប់អ្នកដទៃបានឃើញ ។ មនុស្សកត់សម្គាល់នៅពេលអ្នក ធ្វើសកម្មភាពខុសពីហួងមនុស្ស ហើយវាផ្តល់ឱ្យអ្នកនូវឱកាស ដើម្បីបង្ហាញពួកគេ នូវសេចក្តីស្រឡាញ់របស់ព្រះ ។

ចូរយើងចងចាំថា ៖ ចិត្តដែលដឹងគុណ នាំមកនូវសេចក្តីអំណរ ហើយសេចក្តីអំណរគឺជាអ្វី ដែលព្រះ ចូលចិត្តឃើញមាននៅក្នុងអ្នក!

សេចក្តីប្រកាសពីបទទំនាយ
ខ្ញុំនឹងទទួលខុសត្រូវចំពោះទង្វើរបស់ខ្ញុំ ហើយធ្វើគ្រប់យ៉ាងដោយឥតត្អូញត្អែរ ឬឥតប្រកែកឡើយ ប៉ុន្តែជំនួសមកវិញ ធ្វើដោយចិត្តដឹងគុណ ។ ហាលេលូយ៉ា ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ ជួយទូលបង្គំធ្វើអ្វីគ្រប់យ៉ាង ដោយមិនត្អូញត្អែរ ហើយរីករាយនឹងអ្វីដែលទ្រង់ប្រទានឱ្យទូលបង្គំ ។

ការសិក្សាបន្ថែម
ម៉ាថាយ 7:3-5



ថ្ងៃពុធ ទី22 ខែតុលា

ចូរឱ្យពន្លឺរបស់ខ្ញុំបំភ្លឺ

ម៉ាថាយ 5:16 (ពគប)
ដូច្នេះ ចូរឲ្យពន្លឺរបស់អ្នករាល់គ្នា បានភ្លឺនៅមុខមនុស្សលោកយ៉ាងនោះដែរ ដើម្បីឲ្យគេឃើញការល្អ ដែលអ្នករាល់គ្នាប្រព្រឹត្ត រួចសរសើរដំកើង ដល់ព្រះវរបិតានៃអ្នករាល់គ្នា ដែលគង់នៅស្ថានសួគ៌ ។

តើអ្នកធ្លាប់ប្រើពិលក្នុងទីងងឹតដែរទេ? វាជួយអ្នកឱ្យឃើញកន្លែងដែលអ្នកទៅ និងរក្សាអ្នកឱ្យមាន សុវត្ថិភាព ។ បើគ្មានពន្លឺទេ វាពិបាកមើលអ្វីទាំងអស់ ។ នោះហើយជាអ្វីដែលព្រះយេស៊ូវ ចង់ឱ្យយើងធ្វើ ជាពន្លឺនៅក្នុងពិភពលោក ។

នៅពេលអ្នកជ្រើសរើសធ្វើរឿងល្អដូចជា ចិត្តសប្បុរស ជួយអ្នកដទៃ និងនិយាយសេចក្តីពិត នោះអ្នកកំពុងបញ្ចេញពន្លឺរបស់អ្នក ។ មនុស្សនឹងកត់សម្គាល់ និងឆ្ងល់ថា តើអ្វីដែលធ្វើឱ្យអ្នកខុសគ្នា ។ នោះគឺជាឱកាសរបស់អ្នក ដើម្បីចង្អុលបង្ហាញពួកគេ ទៅកាន់ព្រះយេស៊ូវគ្រីស្ទ ។

ព្រះយេស៊ូវគឺជាពន្លឺដ៏ធំបំផុត នៃអ្វីៗទាំងអស់ ហើយនៅពេលទ្រង់ គង់នៅក្នុងចិត្តអ្នក ពន្លឺរបស់ទ្រង់នឹងភ្លឺតាមរយៈអ្នក ។ ដូច្នេះ នៅពេលដែលអ្នកញញឹម ជាកនរណាម្នាក់ ដែលសោកសៅ ចែករំលែកជាមួយមិត្តភក្តិ ឬនិយាយពាក្យល្អ នោះអ្នកពិតជាបំភ្លឺសម្រាប់ព្រះ ។

សេចក្តីប្រកាសពីបទទំនាយ
ខ្ញុំនឹងទុកឲ្យពន្លឺរបស់ខ្ញុំភ្លឺ ដើម្បីឲ្យអ្នកឯទៀត បានឃើញអំពើល្អដែលខ្ញុំធ្វើ ហើយសរសើរតម្កើងព្រះអម្ចាស់ ។ ហាលេលូយ៉ា ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះយេស៊ូវអើយ ជួយទូលបង្គំបញ្ចេញពន្លឺរបស់ទ្រង់ ដោយធ្វើអំពើល្អ ដើម្បីអោយអ្នកដទៃបានឃើញសេចក្តីស្រឡាញ់របស់ទ្រង់តាមរយៈទូលបង្គំ ។ អាម៉ែន ។

ការសិក្សាបន្ថែម
ម៉ាថាយ 5:14-16, ភីលីព 4:13



ថ្ងៃព្រហស្បតិ៍ ទី23 ខែតុលា

ព្រះយេស៊ូវទ្រង់ជាសិរសា

កូល៉ុស 1:18 (ពគប)
ទ្រង់ជាសិរសារបស់រូបកាយ គឺជាពួកជំនុំ ទ្រង់ជាដើម ក៏បានរស់ពីស្លាប់ឡើងវិញមុនគេបង្អស់ ដើម្បីឲ្យទ្រង់បានជាប្រធានក្នុងគ្រប់ទាំងអស់ ។

តើអ្នកធ្លាប់ឃើញពីរបៀប ដែលរាងកាយរបស់អ្នក ធ្វើការជាមួយគ្នាទេ? ដៃរបស់អ្នកជួយអ្នកឱ្យញ៉ាំ ជើងរបស់អ្នកជួយអ្នកឱ្យដើរ ហើយក្បាលរបស់អ្នក ជួយឱ្យអ្នកគិត និងមើលឃើញ ។ ក្បាលរបស់អ្នកប្រាប់អ្នកពីអ្វី ដែលនៅសល់ក្នុងខ្លួនអ្នកត្រូវធ្វើ ។ បើគ្មានក្បាលទេ រាងកាយរបស់អ្នកមិនអាច ដំណើរការបានត្រឹមត្រូវទេ ។


ព្រះគម្ពីរចែងថា ព្រះយេស៊ូវជាសិរសា ហើយរូបកាយដែលជាពួកជំនុំ ។ នោះមានន័យថា មនុស្សទាំង អស់ ដែលដើរតាមព្រះយេស៊ូវ គឺដូចជាផ្នែកនៃរូបកាយ ហើយព្រះយេស៊ូវ គឺជាអ្នកដែលដឹកនាំ និងណែនាំយើង ។

ព្រះយេស៊ូវក៏ជាអ្នកមុនគេបង្អស់ ដែលបានរស់ពីស្លាប់ឡើងវិញ ហើយរស់នៅជារៀងរហូត ។ នោះហើយជាមូលហេតុដែលទ្រង់ គឺជាមនុស្សសំខាន់បំផុត ក្នុងចំណោមមនុស្សទាំងអស់ ។ ទ្រង់ផ្តល់ឱ្យយើងនូវជីវិត សេចក្តីស្រឡាញ់ និងហេតុផលដើម្បីរស់នៅ ។ ពេលយើងដើរតាមព្រះយេស៊ូវ ហើយអនុញ្ញាតឱ្យទ្រង់ដឹកនាំយើង នោះយើងអាចរឹងមាំ សប្បុរស និងពោរពេញដោយអំណររបស់ទ្រង់ ។

សេចក្តីប្រកាសពីបទទំនាយ
ឱព្រះអម្ចាស់យេស៊ូវ សូមអរព្រះគុណទ្រង់ សម្រាប់ការធ្វើជាសិរសានៃពួកជំនុំ ។ សូមជួយទូលបង្គំ ឲ្យដើរតាមទ្រង់ជារៀងរាល់ថ្ងៃ ហើយចងចាំថា ទ្រង់គឺជាមនុស្សសំខាន់បំផុត ក្នុងជីវិតរបស់ខ្ញុំ ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះយេស៊ូវអើយ សូមជួយទូលបង្គំចងចាំថា ទ្រង់គឺជាអ្នកដឹកនាំនៃអ្វីៗទាំងអស់ ហើយឲ្យទូលបង្គំដើរតាមទ្រង់ជារៀងរាល់ថ្ងៃ ។ អាម៉ែន ។

ការសិក្សាបន្ថែម
អេភេសូរ 1:23



ថ្ងៃសុក្រ ទី24 ខែតុលា

ផែនការរបស់ព្រះគឺល្អបំផុត

យ៉ូណាស 1:2 (ពគប)
ចូរក្រោកឡើងទៅឯនីនីវេ ជាទីក្រុងធំ ហើយស្រែកប្រកាសទាស់នឹងក្រុងនោះ ពីព្រោះអំពើអាក្រក់របស់គេបានសាយឡើង នៅចំពោះមុខអញហើយ ។

ព្រះបានប្រទានការងារធំដល់យ៉ូណាស ។ ទ្រង់ប្រាប់លោកយ៉ូណាស ឲ្យទៅក្រុងនីនីវេ ហើយប្រាប់ប្រជាជនឲ្យឈប់ប្រព្រឹត្តខុស ។ ព្រះបានទតឃើញ ពីអំពើអាក្រក់នៅក្នុងទីក្រុងនោះ ប៉ុន្តែទ្រង់នៅតែយកចិត្តទុកដាក់ចំពោះប្រជាជន ហើយចង់ឲ្យពួកគេមានឱកាសផ្លាស់ប្តូរ ។

ដំបូង យ៉ូណាសមិនចង់ទៅទេ ។ គាត់ខ្លាចហើយមិនគិតថា ប្រជាជននឹងស្តាប់ទេ ។ ប៉ុន្តែព្រះទ្រង់មានផែនការ ហើយទ្រង់ចង់ឲ្យយ៉ូណាសជាផ្នែកនៃវា ។ ទោះជាយ៉ូណាសរត់ចេញក៏ដោយ ព្រះនៅតែជួយគាត់ឲ្យបញ្ចប់ការងារនៅពេលក្រោយ ។

ជួនកាលព្រះសុំឱ្យយើងធ្វើរឿងដែលពិបាក ដូចជានិយាយសេចក្តីពិត ធ្វើជាអ្នកមានចិត្តសប្បុរស នៅពេលដែលអ្នកដទៃមិនមាន ឬក្រោកឈរឡើងសម្រាប់អ្វីដែលត្រឹមត្រូវ ។ ប៉ុន្តែ ដូចយ៉ូណាសដែរ យើងអាចទុកចិត្តថា ព្រះគង់នៅជាមួយយើង ហើយនឹងជួយយើងធ្វើអ្វីដែលទ្រង់សុំ ។

កូនៗអើយ ផែនការរបស់ព្រះអម្ចាស់ គឺជាផែនការដ៏ល្អបំផុត ។ ចូរជឿលើផែនការរបស់ទ្រង់ សម្រាប់ជីវិតរបស់អ្នក!

សេចក្តីប្រកាសពីបទពិសោធន៍
ខ្ញុំនឹងមិនរត់ចេញ ពីផែនការរបស់ព្រះទេ! ខ្ញុំទុកចិត្តថាផ្លូវរបស់ទ្រង់ ជាផ្លូវដ៏ល្អបំផុត ហើយខ្ញុំជ្រើសរើសដើរតាមទ្រង់ ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ សូមជួយទូលបង្គំឱ្យក្លាហាន ហើយធ្វើតាមផែនការរបស់ទ្រង់ ដោយសេចក្តីរីករាយ ដោយដឹងថាទ្រង់នៅជាមួយទូលបង្គំជានិច្ច ។ អាម៉ែន ។

ការសិក្សាបន្ថែម
ទំនុកដំកើង 139:7-10



ថ្ងៃសៅរ៍ ទី25 ខែតុលា

ចូរមានសេចក្តីជំនឿលើព្រះ

ដានីយ៉ែល 3:17 (ពគប)
បើដូច្នោះមែន នោះព្រះនៃយើងខ្ញុំ ដែលយើងខ្ញុំគោរពប្រតិបត្តិតាម ទ្រង់អាចនឹងជួយឲ្យខ្ញុំរួចពីគុកភ្លើង ឆ្ងេះឆេះយ៉ាងសន្ធៅបានហើយ ពិតព្រះករុណា ព្រះអង្គនោះក៏នឹងជួយឲ្យយើងរួចពីព្រះហស្តទ្រង់ដែរ ។

សាដ្រាក់ មែសាក់ និងអ័បេឌនេកោ ជាយុវជនបីនាក់ដែលស្រឡាញ់ព្រះ ។ ថ្ងៃមួយ ស្តេចមួយអង្គបានប្រាប់គេឱ្យក្រាបថ្វាយបង្គំ រូបសំណាកមាសមួយ ប៉ុន្តែ គេឆ្លើយថា ទេ ។ ពួកគេនឹងថ្វាយបង្គំព្រះពីតែមួយប៉ុណ្ណោះ ។

ស្តេចខឹងជាខ្លាំងក៏ម្ចាន់បន្ទរថា នឹងបោះពួកគេចូលទៅក្នុងភ្លើង ដែលឆេះយ៉ាងក្តៅ ។ ប៉ុន្តែមិត្តភក្តិទាំងបីនាក់នោះ មិនខ្លាចអ្វីឡើយ ។ ពួកគេបានប្រាប់ស្តេចថា ព្រះអាចសង្គ្រោះពួកគេបាន ហើយទោះបីជាទ្រង់មិនធ្វើក៏ដោយ ក៏ពួកគេនៅតែទុកចិត្តលើទ្រង់ ។

នោះជាសេចក្តីជំនឿពិត ។ មានន័យថា ការជឿលើព្រះគឺល្អជានិច្ច ទោះជាអ្វីៗមិនទៅតាមការចង់បានក៏ដោយ ។ ព្រះបានជួយមិត្តទាំងបីនាក់ឲ្យរួចពីភ្លើង ហើយពួកគេបានចេញមកដោយគ្មានក្លិនផ្សែង ។

ពេលអ្នកជួបនឹងអ្វីដែលពិបាក ឬគួរឲ្យខ្លាច សូមចាំថា ព្រះទ្រង់គង់នៅជាមួយអ្នក ដូច្នេះទ្រង់គង់នៅជាមួយពួកគេដែរ ។ អ្នកអាចទុកចិត្តទ្រង់ មិនថាមានអ្វីកើតឡើងក៏ដោយ ។

សេចក្តីប្រកាសពីបទទំនាយ
ខ្ញុំមិនខ្លាចទេ! មិនថាមានរឿងអ្វីកើតឡើងនោះទេ ខ្ញុំដឹងថាព្រះអម្ចាស់ នៅជាមួយខ្ញុំជានិច្ច ហើយទ្រង់នឹងក៏ារពារខ្ញុំ ហើយខ្ញុំនឹងមានសេចក្តីជំនឿលើទ្រង់ជានិច្ច ។ ហាលេលូយ៉ា ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អ្ហើយ សូមទ្រង់ជួយទូលបង្គំឲ្យរឹងមាំ ហើយជឿជាក់ថា ទ្រង់នឹងការពារទូលបង្គំជានិច្ច ទោះមានរឿងអ្វីក៏ដោយ ។ អាម៉ែន ។

ការសិក្សាបន្ថែម
អេសាយ 41:10



ថ្ងៃអាទិត្យ ទី26 ខែតុលា

ជាពន្លឺដ៏ពិត

យ៉ូហាន 1:8-9 (ពគប)
[8]គាត់មិនមែនជាពន្លឺនោះទេ គឺមកគ្រាន់តែនឹងធ្វើបន្ទាល់ពីពន្លឺតែប៉ុណ្ណោះ [9]ឯពន្លឺដ៏ពិត នោះគឺជាពន្លឺដែលចំភ្លឺដល់មនុស្សទាំងអស់ ដែលកើតមកក្នុងលោកីយ ។

នៅក្នុងបទគម្ពីរថ្ងៃនេះ យើងរៀនអំពីយ៉ូហានបាទីស្ទ ដែលបានមកប្រាប់មនុស្សអំពីព្រះយេស៊ូវ ។ យ៉ូហានមិនមែនជាពន្លឺទេ ប៉ុន្តែគាត់ត្រូវបានចាត់ឲ្យទៅ រៀបចំមនុស្សគ្រប់គ្នា សម្រាប់ពន្លឺពិត ដែលគឺជាព្រះយេស៊ូវ ។ ព្រះយេស៊ូវបានយាងមក ក្នុងពិភពលោកដើម្បីនាំពន្លឺ និងបង្ហាញផ្លូវទៅដល់ព្រះ ។ យ៉ូហានចង់ឲ្យមនុស្សយល់ថា ព្រះយេស៊ូវគឺជាអង្គពិសេស ដែលបានបញ្ជូនមក ដើម្បីសង្គ្រោះមនុស្សគ្រប់គ្នា ។ គាត់បានជួយពួកគេឲ្យត្រៀមខ្លួន ដើម្បីដើរតាមព្រះយេស៊ូវ ហើយយល់ពីសេចក្តីស្រឡាញ់របស់ទ្រង់ ចំពោះមនុស្សជាតិ ។

ព្រះយេស៊ូវគឺដូចជាពន្លឺ ភ្លឺចែងចាំងក្នុងចិត្តយើង ដែលបង្ហាញយើងពីរបៀបរស់នៅ នឹងស្រឡាញ់អ្នកដទៃ ។ ដូចយ៉ូហានដែរ យើងអាចចែកចាយសេចក្តីស្រឡាញ់ របស់ព្រះយេស៊ូវដល់អ្នកដទៃ ហើយជួយពួកគេឲ្យស្គាល់ពន្លឺពិត ដែលនាំមកនូវសេចក្តីសង្ឃឹម និងសេចក្តីអំណរ ។

សេចក្តីប្រកាសពីបទទំនាយ
ព្រះយេស៊ូវជាពន្លឺរបស់ខ្ញុំ! ខ្ញុំបញ្ចេញពន្លឺ ហើយជួយអ្នកដទៃ ឱ្យឃើញទ្រង់ផងដែរ! ខ្ញុំនឹងចែកចាយដំណឹងល្អ របស់ព្រះយេស៊ូវគ្រីស្ទដល់អ្នកដទៃ ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះយេស៊ូវអើយ សូមអរព្រះគុណទ្រង់ សម្រាប់ជាពន្លឺដ៏ពិត ដែលជួយទូលបង្គំឃើញ និងដើរតាមផ្លូវរបស់ទ្រង់ជារៀងរាល់ថ្ងៃ ។

ការសិក្សាបន្ថែម
ម៉ាថាយ 4:16



ថ្ងៃចន្ទ ទី27 ខែតុលា

ខ្ញុំមានរូបស្រស់ល្អ

លោកុប្បត្តិ 12:11 (ពគប)
កាលគាត់ជិតចូលទៅក្នុងស្រុកអេស៊ីព្ទហើយ នោះគាត់និយាយទៅសារ៉ាយជាប្រពន្ធថា មើល អញដឹងថាឯងជាស្ត្រីមានរូបស្រស់ល្អ ។

សារ៉ាមិនត្រឹមតែស្អាតទេ នាងស្អាតខ្លាំងណាស់! មនុស្សនឹងឈប់ ហើយសម្លឹងមើល នៅពេលដែលនាង ដើរមក ។ សូម្បីតែអាប្រាហាំ ជាប្តីរបស់នាងក៏និយាយថា ៖ «សារ៉ា អ្នកពិតជាស្រស់ស្អាតណាស់!»

ថ្ងៃមួយ អ័ប្រាហាំនិងសារ៉ា កំពុងធ្វើដំណើរ ទៅកន្លែងមួយឈ្មោះអេស៊ីព្ទ ។ មុនពេលពួកគេទៅដល់ទីនោះ អ័ប្រាហាំបាននិយាយថា ៖ «សារ៉ា ពេលមនុស្សឃើញអ្នក នឹងភ្ញាក់ផ្អើលយ៉ាងខ្លាំង ចំពោះការបង្ហាញ ភាពស្រស់ស្អាតណាស់របស់អ្នក! ហើយនោះជាអ្វីដែលបានកើតឡើង ។ ពេលទៅដល់ស្រុកអេស៊ីព្ទ អ្នកជួយរបស់ស្តេចខ្លះ ឃើញសារ៉ាក៏រត់ទៅទូលស្តេចថា ៖ «អ្នកត្រូវមកជួបស្ត្រីនេះ!» ។ សូម្បីតែស្តេចក៏ងឿងឆ្ងល់ថា នាងស្រស់ស្អាតប៉ុណ្ណា ។

ប៉ុន្តែសម្រស់របស់សារ៉ា មិនមែនត្រឹមតែរូបរាងរបស់នាងប៉ុណ្ណោះទេ ។ នាងក៏មានចិត្តសប្បុរស ស្លូតបូត និងទុកចិត្តព្រះ ។ នោះធ្វើឱ្យនាងកាន់តែពិសេស ។ ដូចជាសារ៉ា អ្នកក៏ពិសេសដែរ ។ ព្រះបានបង្កើតអ្នក ហើយទ្រង់មានបន្ទូលថា អ្នកត្រូវបានបង្កើតឡើង យ៉ាងអស្ចារ្យទាំងខាងក្នុង និងខាងក្រៅ!

សេចក្តីប្រកាសពីបទទំនាយ
ខ្ញុំស្អាតដូចសារ៉ា! ព្រះបានធ្វើឲ្យខ្ញុំពិសេស ដោយសារខ្ញុំត្រូវបានបង្កើតឡើងក្នុងរូបភាពដ៏អស្ចារ្យរបស់ព្រះ ។ ហាលេលូយ៉ា ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ សូមជួយទូលបង្គំឱ្យក្លាហាន និងជឿជាក់លើទ្រង់គ្រប់ពេលវេលា ដូចដែលទូលបង្គំដឹងថា ទ្រង់នឹងមិនចាកចេញពីទូលបង្គំឡើយ ។ អាម៉ែន ។

ការសិក្សាបន្ថែម
1 ពេត្រុស 3:3-4



ថ្ងៃអង្គារ ទី28 ខែតុលា

ពាក្យសំដីរបស់អ្នកផ្គុំដោយអំណាច

យ៉ូអែល 3:10 (ពគប)
ចូរដំដែកផាឈរបស់ឯងរាល់គ្នាធ្វើជាដាវ ហើយដង្ហាវរបស់ឯងធ្វើជាលំពែងទៅ ត្រូវឲ្យអ្នកខ្សោយពោលថា ខ្ញុំមានកំឡាំងដែរ ។

គាំងពីយូរយារណាស់មកហើយ មានយុវជនម្នាក់ឈ្មោះយ៉ូស្វេ ។ គាត់ត្រូវបានចាត់ឲ្យទៅ ពិនិត្យមើលដីមួយដើម្បីមើលថា តើជនជាតិអ៊ីស្រាអែល អាចយកវាបានដែរឬទេ ដូចព្រះបានសន្យា ។ យ៉ូស្វេ និងមិត្តរបស់គាត់កាលែប ជាមនុស្សតែពីរនាក់ប៉ុណ្ណោះ ដែលបានជឿព្រះ ហើយនិយាយថា ៖ «បាទ យើងអាចយកដីនោះបាន!» ។ ពួកគេនិយាយដូចជាព្រះ ហើយជឿទុកចិត្ត លើពាក្យរបស់ទ្រង់ ។

កូនៗអើយ ពាក្យដែលឯងនិយាយ គឺមានកម្លាំងខ្លាំងណាស់! អ្វីដែលអ្នកនិយាយអាចផ្លាស់ប្តូរអនាគតរបស់អ្នកបាន ។ ប្រសិនបើព្រះមានបន្ទូលថា អ្នកអាចធ្វើអ្វីមួយបាន អ្នកពិតជាអាចធ្វើបាន! ប្រសិនបើទ្រង់មានបន្ទូលថា អ្នកអាចមានអ្វីមួយ អ្នកពិតជាអាចមានអ្វីមួយមែន! ចូរនិយាយដូចព្រះ ហើយមើលពីអ្វីៗដែលជុំវិញអ្នកមានការផ្លាស់ប្តូរ!

សេចក្តីប្រកាសពីបទទំនាយ
ខ្ញុំអាចធ្វើគ្រប់យ៉ាងបាន តាមរយៈព្រះគ្រីស្ទ ដែលផ្តល់កម្លាំងដល់ខ្ញុំ ។ ខ្ញុំយល់ស្របនឹងព្រះបន្ទូលរបស់ព្រះ ហើយខ្ញុំនិយាយពាក្យវិជ្ជមាន ក្នុងជីវិតរបស់ខ្ញុំ ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ សូមជួយខ្ញុំឲ្យនៃប្រែក្លាយឧបករណ៍របស់ខ្ញុំ ទៅជារបស់ដែលប្រកបដោយសេចក្តីសុខសាន្ត ហើយរស់នៅដោយសេចក្តីសប្បុរស ជារៀងរាល់ថ្ងៃ ។ អាម៉ែន ។

ការសិក្សាបន្ថែម
សុភាសិត 18:21



ថ្ងៃពុធ ទី29 ខែតុលា

ទ្រង់គង់នៅជាមួយខ្ញុំជានិច្ច

ទំនុកតម្កើង 139:7 (ពគប)
តើទូលបង្គំនឹងទៅឯណា ឲ្យរួចពីព្រះវិញ្ញាណទ្រង់ តើនឹងរត់ទៅឯណា ឲ្យរួចពីព្រះភក្ត្រទ្រង់?

តាំងពីយូរយារណាស់មកហើយ ម៉ូសេត្រូវដើរកាត់វាលរហោស្ថាន ដើម្បីសង្គ្រោះប្រជាជនអ៊ីស្រាអែល។ គាត់បានឃើញភ្លើងឆេះចេញពីគុម្ពបន្លា ហើយបានឮសំឡេងរបស់ព្រះ! លោកម៉ូសេមិនដឹងថា ត្រូវធ្វើយ៉ាងណាទេ ប៉ុន្តែព្រះមានបន្ទូលទៅគាត់ថា៖ «ខ្ញុំនៅជាមួយអ្នកគ្រប់ទីកន្លែងដែលអ្នកទៅ!»។ ម៉ូសេមានព្រះនៅក្បែរគាត់។ ឥឡូវនេះ ព្រះវិញ្ញាណបរិសុទ្ធ គង់នៅខាងក្នុងយើង។ លែងរង់ចាំទ្រង់ងមកក្បែរយើងទៀតហើយ។ នោះជាការត្រឹមត្រូវ៖ ព្រះគង់នៅខាងក្នុងយើង!

គ្រប់ទីកន្លែងដែលអ្នកដើរ ព្រះទ្រង់ដើរ។ កន្លែងណាដែលអ្នកអង្គុយ ព្រះអម្ចាស់អង្គុយ។ កូនៗអើយ អ្នកយកព្រះមកដាក់ក្នុងខ្លួន ដើម្បីកុំឱ្យឯងនៅម្នាក់ឯងតើអស្ចារ្យប៉ុណ្ណាទៅ? ព្រះវិញ្ញាណបរិសុទ្ធគឺជាមិត្តរបស់អ្នកអស់មួយជីវិត។ អ្នកមិនអាចមានគុណវិបត្តិទេ។ ហាលេលូយ៉ា!

សេចក្តីប្រកាសពីបទទំនាយ
ឱព្រះអម្ចាស់អើយ សូមអរព្រះគុណព្រះអង្គ ដែលតែងតែនៅជាមួយទូលបង្គំតាមរយៈព្រះវិញ្ញាណបរិសុទ្ធ។ ខ្ញុំដឹងថា ខ្ញុំមានគោលបំណង និងការត្រាស់ហៅរបស់ទ្រង់ នៅក្នុងជីវិតរបស់ខ្ញុំ ហើយខ្ញុំនឹងតែងតែជឿជាក់លើទ្រង់ ដើម្បីដឹកនាំជំហានរបស់ខ្ញុំ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ សូមអរព្រះគុណទ្រង់ ដែលទូលបង្គំមិនអាចនៅឆ្ងាយ ពីទ្រង់បានឡើយ ព្រោះទ្រង់គង់នៅ ជាមួយទូលបង្គំជានិច្ច គ្រប់ទីកន្លែងដែលទូលបង្គំទៅ។

ការសិក្សាបន្ថែម
យ៉ូហាន 14:17



ថ្ងៃព្រហស្បតិ៍ ទី30 ខែតុលា

ចូរគិតដូចទ្រង់គិត

ភីលីព 4:8 (ពគប)
មួយទៀត បងប្អូនអើយ ឯសេចក្ដីណាដែលពិត សេចក្ដីណាដែលគួររាប់អាន សេចក្ដីណាដែលសុចរិត សេចក្ដីណាដែលបរិសុទ្ធ សេចក្ដីណាដែលគួរស្រឡាញ់ សេចក្ដីណាដែលមានឈ្មោះល្អ បើមានសគុណណា ឬជាសេចក្ដីសរសើរណា នោះចូរពិចារណាពីសេចក្ដីទាំងនោះចុះ ។

យើងមានសំណួរមួយ សម្រាប់អ្នករាល់ថ្ងៃនេះ ៖ ពេលមនុស្សម្នាក់ ទទួលជីវិតរបស់ព្រះគ្រីស្ទ តើផ្នែកមួយណា ដែលត្រូវបានបង្កើតថ្មី? វិញ្ញាណ ព្រលឹង ឬរូបកាយ? ល្អណាស់ចុំពោះអ្នក ដែលនិយាយថា «វិញ្ញាណ» ។ វាគឺជាវិញ្ញាណរបស់ពួកគេ ដែលថ្មីថ្នាំងស្រស់ ហើយរបស់ចាស់កន្លងផុតទៅ ។ នេះគឺចិត្តរបស់មនុស្សត្រូវបង្កើតថ្មី (ធ្វើជាថ្មីឡើងវិញ) ។ ដំណើរការនេះកើតឡើងនៅពេលដែលយើងអានព្រះគម្ពីរ និងស្តាប់សារនៅព្រះវិហារ ហើយតែងតែអធិស្ឋាន ។

ក្នុងនាមជាកូនរបស់ព្រះ វាជាការសំខាន់ក្នុងការគិត ដូចដែលព្រះយេស៊ូវបានគិត ។ អ្នកមានគំនិតរបស់ព្រះគ្រីស្ទ ប៉ុន្តែអ្នកត្រូវតែអានព្រះគម្ពីរ ជារៀងរាល់ថ្ងៃដើម្បីដឹង និងយល់ពីរបៀបគិតរបស់ព្រះ ។ កូនៗរៀនព្រះបន្ទូលរបស់ព្រះដូចជាអ្នករៀននៅសាលា ។ កុំទុកពេលមួយថ្ងៃកន្លងផុតទៅ ដោយមិនបានអានព្រះគម្ពីររបស់អ្នក ហើយត្រូវចាំថាត្រូវអធិស្ឋាន ហើយអាន ដំណឹងល្អរបស់អ្នករាល់ព្រឹកមុនពេលអ្នកចាប់ផ្តើមថ្ងៃរបស់អ្នក ។

សេចក្តីប្រកាសពីបទទំនាយ
ខ្ញុំមានគំនិតរបស់ព្រះគ្រីស្ទ ហើយខ្ញុំគិតដូចព្រះយេស៊ូវគ្រីស្ទ ។ ខ្ញុំជ្រើសរើសគិតអំពីរឿងល្អ ដែលនឹងនាំមកនូវសិរីល្អដល់ព្រះអម្ចាស់ ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ សូមជួយទូលបង្គំអំពីរឿងល្អៗ និងរីករាយ ហើយធ្វើអ្វីដែលត្រឹមត្រូវជារៀងរាល់ថ្ងៃ ។ អាម៉ែន ។

ការសិក្សាបន្ថែម
រ៉ូម 12:1-2



ថ្ងៃសុក្រ ទី31 ខែតុលា

ព្រះគុណរបស់ព្រះអម្ចាស់

អេភេសូរ 2:8 (ពគប)
ដ្បិតគឺដោយព្រះគុណ ដែលអ្នករាល់គ្នាបានសង្គ្រោះ ដោយសារសេចក្តីជំនឿ ហើយសេចក្តីនោះក៏មិនមែនកើតពីអ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ ។

ស្នេចក្តីស្រឡាញ់របស់ព្រះ ពិតជាអស្ចារ្យណាស់! តើអ្នកដឹងទេថា អ្នកមិនត្រូវធ្វើអ្វីដើម្បីទទួលបានស្នេចក្តីស្រឡាញ់ពីព្រះទេ? វាជាអំណោយទានមួយ! វាត្រឹមត្រូវហើយ នៅពេលដែលអ្នកជឿលើព្រះយេស៊ូវ ហើយជឿលើទ្រង់ នោះព្រះទ្រង់ប្រទានសេចក្តីស្រឡាញ់ និងព្រះគុណរបស់ទ្រង់ដល់អ្នក ។ ព្រះគុណគឺនៅពេលដែលព្រះប្រទានឱ្យយើង នូវអ្វីដែលល្អដែលយើងមិនសមនឹងទទួលបាន ។

អ្នកមិនអាចរកអំណោយទានបានទេមែនទេ? ដូចគ្នានឹងថ្ងៃកំណើតរបស់អ្នកដែរ នៅពេលដែលនរណាម្នាក់ផ្តល់អំណោយដល់អ្នក អ្នកមិនចាំបាច់ធ្វើអ្វី ដើម្បីទទួលបានវាទេ ដោយគ្រាន់តែទទួលវាប៉ុណ្ណោះ ។ សេចក្តីស្រឡាញ់របស់ព្រះក៏ដូចគ្នាដែរ ។ អ្នកមិនចាំបាច់ព្យាយាមធ្វើឱ្យល្អឥតខ្ចោះ ដើម្បីទទួលបានព្រះគុណរបស់ទ្រង់នោះទេ ។ គឺគ្រាន់តែជឿលើព្រះយេស៊ូវ នោះព្រះនឹងផ្តល់ឱ្យអ្នក នូវអំណោយទានដ៏ល្អបំផុត ដែលមិនធ្លាប់មាន ជាសេចក្តីស្រឡាញ់របស់ទ្រង់!

សូមឆ្លាំថា អំណោយទាននៃព្រះគុណ របស់ព្រះគឺឥតគិតថ្លៃ ។ អ្វីដែលអ្នកត្រូវធ្វើគឺជឿលើព្រះយេស៊ូវ ហើយទទួលយកវាដោយចិត្តដឹងគុណ ។ អរព្រះគុណព្រះនៅថ្ងៃនេះ សម្រាប់អំណោយទានដ៏អស្ចារ្យ ចំពោះព្រះគុណរបស់ទ្រង់!

សេចក្តីប្រកាសពីបទពិសោធន៍
ព្រះគុណរបស់ព្រះ ជាអំណោយទានដ៏ពិសេសសម្រាប់ខ្ញុំ! ខ្ញុំមិនបានទទួលការសង្គ្រោះរបស់ខ្ញុំទេ ដូច្នេះខ្ញុំមិនអាចអួតអំពីវាបានទេ ។ ខ្ញុំបានសង្គ្រោះដោយសារ សេចក្តីស្រឡាញ់ និងព្រះគុណរបស់ព្រះអម្ចាស់ ។ សូមអរព្រះគុណព្រះអម្ចាស់យេស៊ូវ! អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះយេស៊ូវអើយ សូមអរព្រះគុណទ្រង់ សម្រាប់ការស្រឡាញ់ទូលបង្គំជាខ្លាំង ហើយទ្រង់ប្រទានអំណោយទានដល់ទូលបង្គំ ពីសេចក្តីសង្គ្រោះ ដោយព្រះគុណរបស់ទ្រង់ ។ អាម៉ែន ។

ការសិក្សាបន្ថែម
លោកុប្បត្តិ 6:8



ថ្ងៃសៅរ៍ ទី1 ខែវិច្ឆិកា

ទេវតាសម្រាប់ជួយកិច្ចការ

ហេព្រើរ 1:14 (ពគប)
តើពួកទេវតាទាំងនោះមិនមែនជាវិញ្ញាណបំរើ ដែលទ្រង់បានចាត់មក សំរាប់ការងារជួយ ដល់ពួកដែលត្រូវទទួលសេចក្តីសង្គ្រោះជាមរដកទេឬអី ។

តើអ្នកដឹងទេថា ទេវតាគឺជាអ្នកនាំសាររបស់ព្រះ? ពួកគេគឺជាជំនួយការពិសេសដែលព្រះបញ្ជូនមកដើម្បីការពារ និងណែនាំយើង។ ពួកគេត្រូវបានបញ្ជូនមកជួយយើងធ្វើអ្វីដែលព្រះ ចង់ឱ្យយើងធ្វើ ផ្តល់កម្លាំងក្នុងពេលលំបាក ការពារយើងពីគ្រោះថ្នាក់ និងដើម្បីរក្សាឱ្យយើងនៅជាមួយ!


ក្នុងព្រះគម្ពីរ ទេវតាមួយរូប បានបង្ហាញខ្លួនដល់ម៉ារា ដើម្បីប្រាប់នាងថា នាងនឹងធ្វើជាម្តាយរបស់ព្រះយេស៊ូវ។ ទេវតាមួយទៀតបានជួយ ដានីយ៉ែលដោយរក្សាគាត់ ឱ្យមានសុវត្ថិភាពនៅក្នុងរូងសត្វតោ។ ពេលដែលអ្នកបានក្លាយជាកូនរបស់ព្រះ ភ្លាមៗនោះព្រះបានចាត់ទេវតា ឱ្យនៅជាមួយអ្នកជាប្រៀងរហូត!

ទោះបីជាអ្នកមើលមិនឃើញក៏ដោយ ក៏ពួកគេតែងតែនៅជាមួយអ្នក ដើម្បីណែនាំនិងជួយអ្នកនៅពេលដែលអ្នកត្រូវការពួកគេ។ កូនៗ អ្នកមិននៅម្នាក់ឯងទេ ហើយអ្នកអាចទុកចិត្តបានថា ព្រះតែងតែមើលថែទាំអ្នក ដោយបញ្ជូនទេវតារបស់ទ្រង់ មកជួយក្នុងគ្រាខ្វះខាត ។

សេចក្តីប្រកាសពីបទទំនាយ
ឱព្រះអម្ចាស់ឆើយ សូមអរព្រះគុណព្រះអង្គ ដែលបានបញ្ជូនទេវតាមកជួយ និងការពារទូលបង្គំ ។ ខ្ញុំដឹងថាទ្រង់តែងតែនៅជាមួយខ្ញុំ ណែនាំខ្ញុំ និងការពារខ្ញុំ ។ ខ្ញុំដឹងថាថ្ងៃនេះ ខ្ញុំមិនមែនតែម្នាក់ឯងទេ ហើយខ្ញុំមានពួកទេវតាដើរជាមួយខ្ញុំ ។ ថ្ងៃរបស់ខ្ញុំនឹងល្អឥតខ្ចោះ ហើយពោរពេញដោយអច្ឆរិយៈ! អាម៉ែន ។

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់ឆើយ សូមអរព្រះគុណព្រះអង្គ ដែលបានបញ្ជូនទេវតាមកជួយ និងការពារទូលបង្គំ ។ ទូលបង្គំដឹងថាទ្រង់តែងតែនៅជាមួយទូលបង្គំ ណែនាំទូលបង្គំ និងការពារទូលបង្គំជានិច្ច ។ អាម៉ែន ។

ការសិក្សាបន្ថែម
លូកា 1:26-38



ថ្ងៃអាទិត្យ ទី2 ខែវិច្ឆិកា

អ្នកការពារបស់ស្តេច

1 ពង្សាវតារក្សត្រ 22:19 (ពគប)
នោះមីកាយ៉ាទូលថា ដូច្នេះ សូមស្តាប់ព្រះបន្ទូលនៃព្រះយេហូវ៉ាសិន ទូលបង្គំ បានឃើញព្រះយេហូវ៉ា ទ្រង់គង់លើបល្ល័ង្ក មានទាំងពួកពលបរិវារនៃស្ថានសួគ៌ ទាំងអស់ ឈរអមអង្គ ទាំងខាងស្តាំ និងខាងឆ្វេង ។

នៅពេលអ្នកឃើញស្តេចគង់លើបល្ល័ង្ក អ្នកនឹងឃើញអ្នកយាម ដ៏រឹងមាំឈរនៅក្បែរនោះ ។ ឆ្មាំទាំងនេះគឺជាជនួយការ ពិសេសដែលការពារស្តេច និងធ្វើតាមបញ្ជារបស់គាត់ ។ កាលពីយូរយ៉ារណាស់មកហើយ ស្តេចមានអ្នកយាមកាន់តែច្រើន នោះអ្នកដែលមានអំណាច កាន់តែច្រើនពិតថា ទ្រង់មានអំណាច ។ ឆ្មាំនីមួយៗមានការងារខុសៗគ្នា ខ្លះជាអ្នកនាំសារ ខ្លះជាអ្នកបើកបរ និងខ្លះទៀតជាអ្នកប្រយុទ្ធ ប៉ុន្តែពួកគេសុទ្ធតែធ្វើការឱ្យស្តេច ។

ដូចជាស្តេចមានអ្នកយាម ព្រះអម្ចាស់មានទ័ពទេវតា នៅជាមួយព្រះអង្គ ។ ពួកទេវតាខ្លះជាអ្នកនាំសារដូចជាកាព្រីយ៉ែល ហើយខ្លះទៀតជាអ្នកចម្បាំង ដូចជាមីកែល ។ ព្រះចាត់ទេវតារបស់ទ្រង់ ឲ្យធ្វើការងារពិសេស ដូចជាអ្នកជួយអ្នកការពារ ឬអ្នកនាំសារ ។

ឱព្រះអម្ចាស់អើយ សូមអរព្រះគុណព្រះអង្គ ដែលបានប្រទានអាវុធសម្ងាត់ ដល់ទូលបង្គំ ដើម្បីកែប្រែជីវិតទូលបង្គំ ។ ទូលបង្គំជ្រើសរើស ប្រើអណ្តាតរបស់ទូលបង្គំដើម្បី យល់ស្របនឹងអ្វីដែលទ្រង់មានបន្ទូលអំពីទូលបង្គំ ។ ជីវិតរបស់ទូលបង្គំគឺជាទីបន្ទាល់ ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ សូមអរព្រះគុណព្រះអង្គ ដែលបានប្រទានអាវុធសម្ងាត់ ដល់ទូលបង្គំ ដើម្បីកែប្រែជីវិតទូលបង្គំ ។ ទូលបង្គំជ្រើសរើសប្រើអណ្តាតរបស់ទូលបង្គំដើម្បីយល់ស្របនឹងអ្វី ដែលព្រះមានបន្ទូលអំពីទូលបង្គំ ។ ជីវិតរបស់ទូលបង្គំគឺជាទីបន្ទាល់ ។ អាម៉ែន ។

ការសិក្សាបន្ថែម
យ៉ាកុប 3:2-5



ថ្ងៃសៅរ៍ ទី6 ខែធ្នូ

ដែលដឹកនាំព្រះវិញ្ញាណ

រ៉ូម 8:14 (ពគប)
ហើយអស់អ្នកណាដែលព្រះវិញ្ញាណនៃព្រះទ្រង់នាំ អ្នកទាំងនោះហើយជាពួកកូនរបស់ព្រះ ។


សាវ័កប៉ុលជាគំរូដ៏អស្ចារ្យមួយ នៃមនុស្សម្នាក់ដែលបានរស់នៅ ក្នុងជីវិតខុសគ្នាមុនពេលជួបនឹងព្រះអម្ចាស់យេស៊ូវគ្រីស្ទ ។ គាត់ជាមនុស្សអាក្រក់ ចំពោះពួកគ្រីស្ទាន ហើយថែមទាំងធ្វើឱ្យ ពួកគេឈឺចាប់ទៀតផង ។ ប៉ុន្តែ ថ្ងៃមួយ នៅតាមផ្លូវទៅកាន់កន្លែងមួយ ឈ្មោះដាម៉ាស សាវ័កប៉ុលបានជួបជាមួយ ព្រះយេស៊ូវគ្រីស្ទ ហើយចាប់ពីពេលនោះមក អ្វីៗបានផ្លាស់ប្តូរ ។

ក្រោយមក ប៉ុលមិនបានធ្វើអ្វី ដែលគាត់ចង់បានទៀតទេ ។ គាត់បានចាប់ផ្តើមដើរ តាមព្រះវិញ្ញាណបរិសុទ្ធ ហើយធ្វើអ្វីដែលព្រះចង់ជំនួសវិញ ។ កូនៗអើយ ព្រះវិញ្ញាណបរិសុទ្ធក៏គង់នៅក្នុងអ្នកដែរ! ទ្រង់ជួយ និងណែនាំកូនៗរបស់ព្រះ ។ ដូច្នេះថ្ងៃនេះ សូមជ្រើសរើសធ្វើតាមព្រះវិញ្ញាណបរិសុទ្ធ មិនមែនគ្រាន់តែជាគំនិតផ្ទាល់ខ្លួនរបស់អ្នកប៉ុណ្ណោះទេ ។ នោះហើយជាអត្ថន័យនៃការរស់នៅ ជាកូនរបស់ព្រះ!

សេចក្តីប្រកាសពីបទទំនាយ
ឱព្រះអម្ចាស់អើយ សូមអរព្រះគុណទ្រង់ សម្រាប់ការដឹកនាំទូលបង្គំ ដោយព្រះវិញ្ញាណរបស់ទ្រង់ ក្នុងគ្រប់កិច្ចការដែលទូលបង្គំធ្វើ ។ ទូលបង្គំជាកូនរបស់ទ្រង់ ព្រោះទូលបង្គំត្រូវបានដឹកនាំដោយព្រះវិញ្ញាណនៃព្រះ ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ សូមអរព្រះគុណទ្រង់ សម្រាប់ការដឹកនាំទូលបង្គំ ដោយព្រះវិញ្ញាណរបស់ទ្រង់ ក្នុងគ្រប់កិច្ចការដែលទូលបង្គំធ្វើ ។ ទូលបង្គំជាកូនរបស់ទ្រង់ ព្រោះទូលបង្គំត្រូវបានដឹកនាំ ដោយព្រះវិញ្ញាណនៃព្រះ ។ អាម៉ែន ។

ការសិក្សាបន្ថែម
រ៉ូម 16–១៧



ថ្ងៃអាទិត្យ ទី7 ខែធ្នូ

អំណាចនៃការសរសើរ

កិច្ចការ 16:25 (ពគប)
លុះពេលប្រហែលជាកណ្ដាលអធ្រាត្រ ប៉ុល នឹងស៊ីឡាស កំពុងតែអធិស្ឋាន ហើយច្រៀងសរសើរដល់ព្រះ ឯពួកអ្នកទោសក៏ស្តាប់ដែរ ។


រឿងថ្ងៃនេះគឺអំពីប៉ុល និងស៊ីឡាស បុរសពីរនាក់នេះ ដែលស្រឡាញ់ព្រះយេស៊ូវ ហើយបានចែកចាយសាររបស់ទ្រង់ ។ ពួកគេត្រូវបានចាប់ខ្លួន ដោយសារតែផ្សាយអំពីព្រះ ហើយត្រូវបានដាក់គុក ។ ប៉ុន្តែជំនួសឱ្យអារម្មណ៍សោកសៅ ឬខឹង ពួកគេបានជ្រើសរើសអធិស្ឋាន និងច្រៀងចម្រៀងសរសើរតម្កើងព្រះ សូម្បីតែកណ្ដាលអធ្រាត្រក៏ដោយ!

ខណៈដែលពួកគេកំពុងតែសរសើរ មានអ្វីអស្ចារ្យបានកើតឡើង ។ ព្រះគម្ពីរប្រាប់យើងថា ការរញ្ជួយដីដ៏ធំមួយបានអង្រួនគុក ហើយទ្វារបានរបើក! ច្រវាក់ដែលដាក់អ្នកទោសត្រូវបានធ្លាក់ចេញ ។ ព្រះបានឆ្លើយតប នឹងការសរសើររបស់ពួកគេយ៉ាងខ្លាំង! រឿងនេះរំឭកយើងថា ទោះយើងជួបរឿងអ្វីក៏ដោយ យើងអាចសរសើរព្រះជានិច្ច ។ ការសរសើរមានអំណាច ហើយវាអាចជួយយើង ឲ្យឆ្លងកាត់គ្រាលំបាក ។ កុំឈប់សរសើរព្រះអម្ចាស់!

សេចក្តីប្រកាសពីបទទំនាយ
ឱព្រះអម្ចាស់អើយ សូមអរព្រះគុណព្រះអង្គ ដែលការសរសើររបស់ទូលបង្គំមានអំណាច ។ ខ្មាំងសត្រូវទាំងអស់នឹងជួបគ្រោះថ្នាក់ ពេលទូលបង្គំសរសើរតម្កើងព្រះអម្ចាស់ ។ ទូលបង្គំបដិសេធមិនឱ្យបាក់ទឹកចិត្ត; នៅក្នុងព្រះគ្រីស្ទ ទូលបង្គំមានជ័យជំនះ! អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ សូមអរព្រះគុណព្រះអង្គ ដែលការសរសើររបស់ទូលបង្គំមានអំណាច ។ ខ្មាំងសត្រូវទាំងអស់ស្ថិតក្នុងគ្រោះថ្នាក់ ពេលទូលបង្គំសរសើរតម្កើងព្រះអម្ចាស់ ។ ទូលបង្គំបដិសេធមិនឱ្យធ្លាក់ទឹកចិត្ត នៅក្នុងព្រះគ្រីស្ទ ទូលបង្គំមានជ័យជំនះ! អាម៉ែន ។

ការសិក្សាបន្ថែម
កិច្ចការ 16:25-26



ថ្ងៃចន្ទ ទី៖ ខែធ្នូ

សេចក្តីជំនឿដែលរឹងរូស

ដានីយ៉ែល 3:16 (ពគប)
តែសាដ្រាក់ មែសាក់ នឹងអ័បេឌ-នេកោទូលឆ្លើយដល់ស្តេចថា បពិត្រព្រះរាជា នេប៊ូក្នេសា យើងខ្ញុំមិនចាំបាច់ទូលឆ្លើយដល់ទ្រង់ពីដំណើរនេះទេ ។

កាលពីយូរយារណាស់មកហើយ ស្តេចនៃនគរពើស៊ី (ប្រទេសអ៊ីរ៉ង់សម័យបច្ចុប្បន្ន) ស្តេចនេប៊ូក្នេសាបានធ្វើរូបសំណាកមាសយ៉ាងធំ ហើយប្រាប់អ្នករាល់គ្នា ឲ្យក្រាបថ្វាយបង្គំ។ សាដ្រាក់ មែសាក់ និងអបេឌនេកោ ជាមិត្តភក្តិបីនាក់ ដែលស្រឡាញ់ព្រះ បានបដិសេធមិនថ្វាយបង្គំ រូបសំណាកនោះទេ។ ពួកគេបានដឹងថា មានតែព្រះពិតតែមួយគត់ ដែលគួរត្រូវបានគេគោរពប្រណិប័តន៍ ។

ស្តេចខឹងជាខ្លាំង ហើយគំរាមបោះគេចូលក្នុងគុកភ្លើង ។ ប៉ុន្តែសាដ្រាក់ មែសាក់ និងអ័បេឌនេកោមិនបានភ័យខ្លាចឡើយ ។ ពួកគេទូលស្តេចថា «ព្រះនៃយើងខ្ញុំអាចសង្គ្រោះយើងពីភ្លើងបាន ប៉ុន្តែទោះជាទ្រង់មិនធ្វើក៏ដោយ យើងនឹងមិនថ្វាយបង្គំ រូបសំណាករបស់ទ្រង់ឡើយ» ។ ស្តេចឲ្យគេបោះចូលក្នុងឡតែរឿងអស្ចារ្យបានកើតឡើង! ព្រះបានការពារពួកគេ ហើយពួកគេមិនរងគ្រោះដោយភ្លើងទេ ។ ស្តេចឃើញដូច្នេះ ក៏សរសើរតម្កើងព្រះ ។ ដូចជាមិត្តដ៏ក្លាហានទាំងនេះ ចូរក្រោកឈរឡើង ហើយរក្សាសេចក្តីជំនឿរបស់អ្នកទៅលើព្រះ ទោះជាមានអ្វីក៏ដោយ ។

សេចក្តីប្រកាសពីបទទំនាយ
ឱព្រះអម្ចាស់អើយ សូមអរព្រះគុណទ្រង់ ដែលបានប្រទានឱ្យទូលបង្គំ មានសេចក្តីក្លាហាន ដើម្បីឈរចំពោះសេចក្តីពិត ។ ទូលបង្គំនឹងមិនភ័យខ្លាចទេ ព្រោះទូលបង្គំដឹងថា ទ្រង់នៅជាមួយទូលបង្គំ ។ ហាលេលូយ៉ា ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ សូមអរព្រះគុណទ្រង់ ដែលបានប្រទានឱ្យទូលបង្គំ មានសេចក្តីក្លាហាន ដើម្បីឈរចំពោះសេចក្តីពិត ។ ទូលបង្គំនឹងមិនភ័យខ្លាចទេ ព្រោះទូលបង្គំដឹងថា ទ្រង់គង់នៅជាមួយទូលបង្គំ ។ ហាលេលូយ៉ា ។ អាម៉ែន ។

ការសិក្សាបន្ថែម
ដានីយ៉ែល 3:16-18



ថ្ងៃអង្គារ ទី9 ខែធ្នូ

ព្រះវិញ្ញាណនៃសេចក្តីពិត

យ៉ូហាន 14:17 (ពគប)
គឺជាព្រះវិញ្ញាណនៃសេចក្តីពិត ដែលលោកីយទទួលពុំបាន ព្រោះមិនឃើញ ហើយមិនស្គាល់ទ្រង់សោះ តែអ្នករាល់គ្នាស្គាល់ទ្រង់ ដ្បិតទ្រង់គង់ជាមួយ ក៏នឹងសណ្ឋិតនៅក្នុងអ្នករាល់គ្នាដែរ ។

នៅថ្ងៃមួយ ព្រះយេស៊ូវ កំពុងមានបន្ទូលទៅកាន់ ពួកសិស្សរបស់ទ្រង់ ។ ទ្រង់បានប្រាប់ពួកគេថា ព្រះដ៏ជាជំនួយនឹងយាងមក បន្ទាប់ពីទ្រង់បានទៅស្ថានសួគ៌ ។ ព្រះដ៏ជាជំនួយនោះគឺជាព្រះវិញ្ញាណបរិសុទ្ធ!


ព្រះយេស៊ូវទ្រង់មានបន្ទូលថា ព្រះវិញ្ញាណបរិសុទ្ធ គឺជាព្រះវិញ្ញាណនៃសេចក្តីពិត ។ ពួកសិស្សនឹងស្គាល់ទ្រង់ ដោយសារទ្រង់នឹងរស់នៅជាមួយពួកគេ ។ ព្រះយេស៊ូវជាផ្លូវ ជាសេចក្តីពិត ហើយជាជីវិត និងព្រះវិញ្ញាណបរិសុទ្ធ ជួយយើងឲ្យស្គាល់សេចក្តីពិត ហើយរស់នៅតាមផ្លូវដ៏ត្រឹមត្រូវ ។ ពួកសិស្សតែងតែស្វែងរកជំនួយពីព្រះយេស៊ូវ ប៉ុន្តែព្រះយេស៊ូវបានប្រាប់ពួកគេ កុំឲ្យបារម្ភពីព្រោះព្រះវិញ្ញាណបរិសុទ្ធនឹងគង់នៅជាមួយពួកគេជានិច្ច ។

អ្វីដែលអស្ចារ្យនោះគឺអ្នកដូចគ្នា! អ្នកមិនដែលនៅម្នាក់ឯងទេ ។ ព្រះវិញ្ញាណបរិសុទ្ធគង់នៅក្នុងអ្នក ដើម្បីជួយអ្នករាល់ថ្ងៃ!

សេចក្តីប្រកាសពីបទទំនាយ
ឱព្រះអម្ចាស់អើយ សូមអរព្រះគុណទ្រង់ ចំពោះព្រះវិញ្ញាណនៃសេចក្តីពិត ជាព្រះវិញ្ញាណបរិសុទ្ធ ដែលដឹកនាំទូលបង្គំ ចូលទៅក្នុងសេចក្តីពិតទាំងអស់ ។ ទូលបង្គំមិនដែលនៅម្នាក់ឯងទេ ព្រះវិញ្ញាណបរិសុទ្ធគង់នៅខាងក្នុងទូលបង្គំ ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ សូមអរព្រះគុណទ្រង់ ចំពោះព្រះវិញ្ញាណនៃសេចក្តីពិត ជាព្រះវិញ្ញាណបរិសុទ្ធ ដែលដឹកនាំទូលបង្គំចូលទៅក្នុងសេចក្តីពិតទាំងអស់ ។ ទូលបង្គំមិនដែលនៅម្នាក់ឯងទេ ព្រះវិញ្ញាណបរិសុទ្ធគង់នៅខាងក្នុងទូលបង្គំ ។ អាម៉ែន ។

ការសិក្សាបន្ថែម
យ៉ូហាន 14:15-18



ថ្ងៃពុធ ទី10 ខែធ្នូ

ចូរអរសប្បាយក្នុងព្រះអម្ចាស់

ភីលីព 4:4 (ពគប)
ចូរអរសប្បាយ ក្នុងព្រះអម្ចាស់ជានិច្ច ខ្ញុំប្រាប់ម្តងទៀតថា ចូរអរសប្បាយឡើង ។

ការអរសប្បាយក្នុងព្រះអម្ចាស់ មានន័យយ៉ាងណាទេ ? មានន័យថាពោរពេញដោយអំណរដោយសារព្រះ មិនថាមានអ្វីកើតឡើង នៅជុំវិញអ្នកឡើយ ។ សាវ័ក ប៉ុលបានប្រាប់ពួកជំនុំ នៅកន្លែងមួយឈ្មោះភីលីពថា ចូរមានអំណរជានិច្ចក្នុងព្រះអម្ចាស់ ។ គាត់ថែមទាំងនិយាយពីរដង ដើម្បីបង្ហាញថាវាសំខាន់ ប៉ុណ្ណា!


ការអរសប្បាយក្នុងព្រះអម្ចាស់ មានន័យថា ការសរសើរទ្រង់ និងអរព្រះគុណទ្រង់ ទោះជាមានការលំបាកយ៉ាងណាក៏ដោយ ។ ប៉ុលមានពេលលំបាក ជាច្រើនក្នុងជីវិតរបស់គាត់ ប៉ុន្តែគាត់នៅតែមានសេចក្តីអំណរ ។ ហេតុអ្វី? ដោយសារដូចជាវិឌ ក្នុងព្រះគម្ពីរ គាត់ដឹងថាវាសំខាន់ ប៉ុណ្ណាក្នុងការនិយាយរឿងល្អអំពីព្រះ ហើយបង្ហាញសេចក្តីស្រឡាញ់ចំពោះទ្រង់ ជាមួយនឹងទង្វើរបស់គាត់ ។

ដូច្នេះ ថ្ងៃនេះ សូមចំណាយពេលបន្តិច ដើម្បីប្រាប់ព្រះថា ទ្រង់អស្ចារ្យប៉ុណ្ណា ។ ចូរញញឹម ច្រៀងសរសើរ ហើយអរសប្បាយ ក្នុងព្រះអម្ចាស់ជានិច្ច!

សេចក្តីប្រកាសពីបទទំនាយ
ថ្ងៃនេះ ទូលបង្គំអរសប្បាយនឹងព្រះអម្ចាស់ ហើយខ្ញុំនឹងបន្តសរសើរតម្កើងទ្រង់ ក្នុងជីវិតរបស់ទូលបង្គំ ។ ទ្រង់តែមួយគត់គឺជាព្រះ ហើយទូលបង្គំទទួលស្គាល់ ភាពអស្ចារ្យរបស់ទ្រង់ ក្នុងជីវិតរបស់ទូលបង្គំ! អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ សូមអរព្រះគុណទ្រង់ ដែលតែងតែនៅជាមួយទូលបង្គំ ។ សូមជួយទូលបង្គំឲ្យមានភាពរីករាយ និងរីករាយជារឿងរាល់ថ្ងៃ ដោយទុកចិត្តលើទ្រង់ ទោះមានអ្វីកើតឡើង ។ សូមជួយទូលបង្គំចែករំលែក ភាពរីករាយរបស់ទូលបង្គំ ទៅកាន់អ្នកដទៃផងដែរ ។ អាម៉ែន ។

ការសិក្សាបន្ថែម
ភីលីព 4:4, 8-9



ថ្ងៃព្រហស្បតិ៍ ទី11 ខែធ្នូ

ដោយគ្រាន់តែជឿប៉ុណ្ណោះ

លោកុប្បត្តិ 15:5 (ពគប)
រួចទ្រង់នាំគាត់ចេញទៅក្រៅប្រាប់ថា ចូរមើលទៅលើមេឃឥឡូវ ហើយរាប់ផ្កាយចុះ បើឯងអាចនឹងរាប់ទាំងអស់បាន រួចទ្រង់មានបន្ទូលប្រាប់ថា ពូជឯងនឹងបានដូច្នោះដែរ ។

តើអ្នកឆ្ងើយតបយ៉ាងណា ពេលមានអ្វីមួយ ហាក់ដូចជាមិនអាចទៅរួច ប៉ុន្តែព្រះបន្ទូលរបស់ព្រះមានបន្ទូលថា វាអាចទៅរួចជាមួយទ្រង់? កាលពីយូរយារណាស់មកហើយ មានបុរសម្នាក់ឈ្មោះអាប់រ៉ាម (ក្រោយមកហៅថា អ័ប្រាហាំ) ។ គាត់ចាស់ណាស់នៅពេលដែលព្រះ បានប្រាប់គាត់នូវអ្វីដែលអស្ចារ្យៈ ថាគាត់នឹងមានកូនរបស់គាត់ ។ ប៉ុន្តែតាមធម្មជាតិ វាមើលទៅមិនអាច កើតឡើងបានឡើយ ។


គាត់និងប្រពន្ធគាត់ចាស់ពេក មិនអាចមានកូនបានទេ ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ លោកតាអ័ប្រាហាំបានជ្រះស្រឡះជឿលើព្រះ ។ គាត់មានសេចក្តីជំនឿដ៏អស្ចារ្យ ។ គាត់បានសួរព្រះថា ៖ «តើខ្ញុំអាចដឹងថាការនេះ នឹងកើតឡើងដោយរបៀបណា? ហើយព្រះអម្ចាស់បានប្រាប់គាត់ ឱ្យថ្វាយដង្វាយពិសេសមួយ ។ អ័ប្រាហាំបានស្តាប់ ហើយធ្វើតាម គាត់បានធ្វើតាមអ្វី ដែលព្រះមានបន្ទូល ។

កូនៗ ទោះបីជារឿងពិបាក ឬមិនអាចទៅរួចក៏ដោយ ចូរចាំចំណុចនេះ ៖ បើព្រះមានបន្ទូលថា អ្នកអាចជឿបាន! ដូចលោកតាអ័ប្រាហាំដែរ ចូរទុកចិត្តព្រះហើយស្តាប់បង្គាប់ទ្រង់ ។

សេចក្តីប្រកាសពីបទទំនាយ
ឱព្រះអម្ចាស់អើយ សូមអរព្រះគុណទ្រង់ សម្រាប់ព្រះបន្ទូលនៃទ្រង់ ដែលជាសិទ្ធិអំណាចចុងក្រោយរបស់ខ្ញុំទូលបង្គំ ។ បើទ្រង់និយាយមែននោះ ទូលបង្គំនឹងឃើញផ្កាល់ភ្នែក ។ ទូលបង្គំយល់ស្របនឹងទ្រង់ ព្រោះព្រះបន្ទូលទ្រង់ពិត! សូមថ្វាយសិរីរុងរឿងដល់ព្រះអម្ចាស់!

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ សូមអរព្រះគុណទ្រង់សម្រាប់ព្រះបន្ទូលទ្រង់ ដែលជាសិទ្ធិអំណាចចុងក្រោយរបស់ទូលបង្គំ ។ បើទ្រង់មានបន្ទូលមែននោះ ទូលបង្គំនឹងឃើញផ្កាល់ភ្នែក ។ ទូលបង្គំយល់ស្របនឹងទ្រង់ ព្រោះព្រះបន្ទូលទ្រង់ពិត! សូមថ្វាយសិរីល្អដល់ព្រះអម្ចាស់!

ការសិក្សាបន្ថែម
លោកុប្បត្តិ 15:1-6



ថ្ងៃសុក្រ ទី12 ខែធ្នូ

ការសរសើរដ៏អស្ចារ្យ

ទំនុកដំកើង 46:1 (ពគប)
ព្រះទ្រង់ជាទីពឹងជ្រក ក៏ជាកំឡាំងនៃយើងខ្ញុំ ជាជំនួយដែលនៅជាប់ជាមួយក្នុងគ្រាអាសន្ន ។

កូនៗអើយ វាមិនងាយស្រួលទេ ក្នុងការសរសើរតម្កើងព្រះ នៅពេលអ្នកឆ្លងកាត់គ្រាលំបាក ។ ប៉ុន្តែនេះជាជំណឹងល្អ អ្នកមិនមែនត្រឹមតែ ជាមនុស្សសាមញ្ញទេ! អ្នកគឺជាអ្នកបង្កើតថ្មី ជាមនុស្សពិសេស ដែលមិនធ្លាប់មានពីមុនមក ។


ប្រសិនបើជាវីឌនៅក្នុងព្រះគម្ពីរ អាចសរសើរតម្កើងព្រះ ក្នុងអំឡុងពេលដ៏លំបាករបស់គាត់ នោះអ្នកក៏អាចធ្វើបានដែរ ពីព្រោះអ្នកមានព្រះវិញ្ញាណបរិសុទ្ធ ដែលគង់នៅក្នុងខ្លួនអ្នក!

ការសរសើររបស់អ្នក គឺខ្លាំងក្លាដោយសារតែ ព្រះដ៏មានគ្រប់ព្រះចេស្តា ទ្រង់រស់នៅក្នុងអ្នក! ដូចព្រះយេស៊ូវដែរ អ្នកពេញដោយវិញ្ញាណរបស់ព្រះ នៅក្នុងពិភពលោកនេះ ។ ដូច្នេះ ចូរនាំគ្នាសរសើរព្រះយេស៊ូវ! ស្រែកទៅកាន់ព្រះដោយអំណរនិងជ័យជំនះ! សូមថ្វាយសិរីល្អដល់ព្រះអម្ចាស់!

សេចក្តីប្រកាសពីបទទំនាយ
ទូលបង្គំមានព្រះវិញ្ញាណបរិសុទ្ធ គង់នៅក្នុងខ្លួនទូលបង្គំ ហើយតាមរយៈទ្រង់ ទូលបង្គំអាចធ្វើគ្រប់កិច្ចការទាំងអស់ ។ សេចក្តីអំណរ និងសេចក្តីស្ងៀមត្រង់គឺជាផ្នែកនៃ ឌីអិនអេ របស់ទូលបង្គំ ហើយទូលបង្គំ នឹងស្រែកសរសើរដល់ព្រះអម្ចាស់ ។ ហាលេលូយ៉ា! អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ ព្រះអង្គ ជាកន្លែងសុវត្ថិភាព និងជាកម្លាំងរបស់ទូលបង្គំ ។ ពេលដែលទូលបង្គំមានអារម្មណ៍ភ័យខ្លាច ឬព្រួយបារម្ភ សូមជួយទូលបង្គំចាំថា ទ្រង់តែងតែនៅទីនោះដើម្បីជួយ និងការពារទូលបង្គំ ។ សូមអរព្រះគុណដែលស្រលាញ់ទូលបង្គំខ្លាំង ។ អាម៉ែន ។

ការសិក្សាបន្ថែម
1 យ៉ូហាន 4:17, ទំនុកដំកើង 47:1



ថ្ងៃសៅរ៍ ទី13 ខែធ្នូ

ចូរសរសើរដំកើងព្រះអម្ចាស់

ទំនុកដំកើង 146:1-2 (ពគប)
[1]ចូរសរសើរដល់ព្រះយេហូវ៉ា នែ ព្រលឹងអញអើយ ចូរសរសើរដល់ព្រះយេហូវ៉ាចុះ [2]កាលខ្ញុំកំពុងរស់នៅឡើយ នោះខ្ញុំនឹងសរសើរដល់ព្រះយេហូវ៉ា ខ្ញុំនឹងច្រៀងសរសើរដល់ព្រះនៃខ្ញុំ ក្នុងកាលដែលនៅមានជីវិតតទៅ។

នៅក្នុងទំនុកតម្កើង 146 យើងយល់ពីសារៈសំខាន់ នៃការសរសើរតម្កើងព្រះអម្ចាស់ដោយអស់ពីចិត្ត។ គម្ពីរនិយាយថា «ខ្ញុំនឹងច្រៀងសរសើរដល់ព្រះនៃខ្ញុំ ក្នុងកាលដែលនៅមានជីវិតតទៅ!»

កូនៗអើយ អ្នកក៏អាចរស់នៅបានពេញ ដោយការសរសើរដែរ! រាល់របស់ល្អដែលអ្នកមាន ដូចជាគ្រួសាររបស់អ្នក សុខភាពរបស់អ្នក និងគំនិតប្រកបដោយសេចក្តីសុខសាន្ត របស់អ្នកគឺមកពីព្រះ។

ដូច្នេះ សូមធ្វើការជ្រើសរើសនៅថ្ងៃនេះ ដើម្បីអរព្រះគុណ និងសរសើរតម្កើងព្រះអម្ចាស់ ជារៀងរាល់ថ្ងៃ។ ចូរអរព្រះគុណទ្រង់សម្រាប់ការចាត់ ព្រះយេស៊ូវមកសង្គ្រោះអ្នក និងសម្រាប់ព្រះពរទាំងអស់ ដែលទ្រង់ប្រទានឱ្យអ្នក។ សូមឱ្យជីវិតរបស់អ្នកពេញដោយអំណរ និងអរព្រះគុណដល់ព្រះអម្ចាស់!

សេចក្តីប្រកាសពីបទទំនាយ
ខ្ញុំនឹងសរសើរតម្កើង ព្រះអម្ចាស់អស់ពីចិត្ត ហើយមិនភ្លេចអ្វីដែលព្រះអង្គ បានធ្វើសម្រាប់ទូលបង្គំឡើយ។ ហាលេលូយ៉ា។ សូមថ្វាយសិរីល្អដល់ព្រះអម្ចាស់។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ សូមអរព្រះគុណទ្រង់ ដែលតែងតែសក្តិសម សម្រាប់ការសរសើរបុស់ទូលបង្គំ។ សូមជួយទូលបង្គំសរសើរទ្រង់ ដោយអស់ពីចិត្តជារៀងរាល់ថ្ងៃ ហើយទុកចិត្តលើទ្រង់ជារៀងរហូត។ អាម៉ែន។

ការសិក្សាបន្ថែម
ទំនុកដំកើង 34:1



ថ្ងៃអាទិត្យ ទី14 ខែធ្នូ

ជាអ្នកធ្វើតាមព្រះបន្ទូលព្រះ

លោកុប្បត្តិ 6:22 (ពគប)
ណូអេក៏ធ្វើដូច្នោះ តាមគ្រប់ទាំងសេចក្តីដែលព្រះបានបង្គាប់ គាត់ធ្វើការនោះសំរេចទាំងអស់ ។


តើអ្នកធ្លាប់ឮរឿងទូកលោកតាណូអេរទេ? កាលពីយូរយារណាស់មកហើយ ព្រះបានមានបន្ទូលប្រាប់បុរសម្នាក់ឈ្មោះណូអេឲ្យសង់ទូកធំមួយ ដោយសារទឹកជំនន់ដ៏ខ្លាំង ដែលទ្រង់កំពុងតែនាំមកផែនដី ដើម្បីបំផ្លាញផែនដី ។ ព្រះគម្ពីរចែងថា ៖ «នេះជាពង្សាវតារបស់ណូអេ គាត់ជាអ្នកសុចរិត ហើយគ្រប់លក្ខណ៍នៅក្នុងដំណរវង្សខ្លួន គាត់ក៏ដើរជាមួយនឹងព្រះ» ។ (លោកុប្បត្តិ 6:9) ។

ទូកធំមួយមិនធ្លាប់សាងសង់ពីមុនមកទេ ប៉ុន្តែលោកតាណូអេបានធ្វើអ្វីគ្រប់យ៉ាងដែលព្រះបានបង្គាប់គាត់ ។ ទំនងជាគាត់ភ័យខ្លាច ថែមទាំងឈឺចាប់ ដោយសារបាយការណ៍អវិជ្ជមាន របស់អ្នកដែលនៅជុំវិញគាត់ ដែលមិនជឿថាទឹកជំនន់ដ៏ធំនឹងមកដល់ ។ ទោះបីជាយ៉ាងណាក៏ដោយ លោកតាណូអេបានជឿដល់ព្រះ ហើយធ្វើតាមព្រះបន្ទូលរបស់ព្រះ ។ អ្នកដឹងថាចុងបញ្ចប់នៃរឿងនេះទេ លោកតាណូអេ និងក្រុមគ្រួសាររបស់គាត់ ត្រូវបានសង្គ្រោះ! កូនៗអើយ ចូរធ្វើជាអ្នកធ្វើតាម ព្រះបន្ទូលរបស់ព្រះ ។ ហាលេលូយ៉ា!

សេចក្តីប្រកាសពីបទពិសោធ
ឱព្រះអម្ចាស់អើយ សូមអរព្រះគុណទ្រង់ សម្រាប់ព្រះគុណទ្រង់ ដែលអោយទូលបង្គំក្លាយជាអ្នកធ្វើតាមព្រះបន្ទូល ។ ទូលបង្គំបង្ហាញសេចក្តីជំនឿ ដោយស្នាដៃរបស់ទូលបង្គំ ហើយទូលបង្គំប្រាកដជានឹងត្រឡប់មកវិញ ដោយមានទីបន្ទាល់ ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ សូមអរព្រះគុណទ្រង់ សម្រាប់ព្រះគុណ ដែលទ្រង់ធ្វើតាមព្រះបន្ទូល ។ ទូលបង្គំបង្ហាញសេចក្តីជំនឿដោយស្នាដៃរបស់ទូលបង្គំ ហើយទូលបង្គំប្រាកដជា នឹងត្រឡប់មកវិញដោយមានទីបន្ទាល់ ។ អាម៉ែន ។

ការសិក្សាបន្ថែម
យ៉ាកុប 1:22-25



ថ្ងៃចន្ទ ទី15 ខែធ្នូ

ការអធិស្ឋានក្នុងវិញ្ញាណ

រ៉ូម 8:26 (ពគប)
ព្រះវិញ្ញាណទ្រង់ក៏ជួយសេចក្ដីកំសោយរបស់យើងបែបដូច្នោះដែរ ដ្បិតយើងមិនដឹងជាគួរអធិស្ឋានសូមអ្វីទេ តែព្រះវិញ្ញាណទ្រង់ជួយអង្វរជំនួសយើង ដោយដង្ហូរដែលរកថ្លែងពុំបានវិញ ។

ស្រមៃមើលថា មាននរណាម្នាក់ដែលជួយអ្នក និយាយជាមួយព្រះ តាមរបៀបដ៏ល្អឥតខ្ចោះ អ្នកដែលមិន ដែលធ្វើខុស ហើយតែងតែនិយាយអ្វីដែលត្រឹមត្រូវ ។ ហើយអ្នកស្ទាបមើលថាដូចម្តេចដែរ? អ្នកមិនចាំបាច់ស្រមៃទេ ព្រោះអ្នកមានជំនួយការ ដែលរស់នៅខាងក្នុងអ្នករួចហើយ!

ទ្រង់ជាព្រះវិញ្ញាណបរិសុទ្ធ ហើយទ្រង់ជាព្រះវិញ្ញាណនៃព្រះ ។ ព្រះគម្ពីរប្រាប់យើងថា ព្រះវិញ្ញាណបរិសុទ្ធជួយយើង ពេលយើងអធិស្ឋាន ដូច្នេះមុននឹងអ្នកនិយាយជាមួយព្រះ ចូរទូលសូមព្រះវិញ្ញាណបរិសុទ្ធឲ្យជួយអ្នកអធិស្ឋាន ។ ការអធិស្ឋានរបស់ទ្រង់ តែងតែល្អឥតខ្ចោះ ហើយព្រះតែងតែស្តាប់!

សេចក្តីប្រកាសពីបទទំនាយ
សូមអរព្រះគុណព្រះអម្ចាស់ ចំពោះព្រះវិញ្ញាណបរិសុទ្ធ ដែលអ្នកដ៏ជាជំនួយរបស់ទូលបង្គំ តាមរយៈទ្រង់ ទូលបង្គំនឹងអធិស្ឋានជានិច្ច កាលដែលទ្រង់ណែនាំដល់ទូលបង្គំ ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ សូមអរព្រះគុណដែលតែងតែជួយទូលបង្គំ ជាពិសេសនៅពេលទូលបង្គំមិនដឹងថា ត្រូវអធិស្ឋានអ្វី ។ សូមចាត់ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គមកដឹកនាំទូលបង្គំ ហើយប្រទានព្រះបន្ទូលមកទូលបង្គំ ។ អាម៉ែន ។

ការសិក្សាបន្ថែម
រ៉ូម 8:26-28



ថ្ងៃអង្គារ ទី16 ខែធ្នូ

សូមបង្រៀនទូលបង្គំព្រះវិញ្ញាណបរិសុទ្ធ

យ៉ូហាន 14:26 (ពគប)
តែព្រះដ៏ជាជំនួយ គឺជាព្រះវិញ្ញាណបរិសុទ្ធ ដែលព្រះវរបិតានឹងចាត់មក ដោយនូវឈ្មោះខ្ញុំ ទ្រង់នឹងបង្រៀនអ្នករាល់គ្នា ពីគ្រប់សេចក្ដីទាំងអស់ ក៏នឹងរំឭកពីគ្រប់ទាំងសេចក្ដី ដែលខ្ញុំបានប្រាប់ដល់អ្នករាល់គ្នាដែរ ។


កូនៗ ចូរស្រមៃមើលថា អ្នកកំពុងរៀននៅសាលា ហើយគ្រូសួរអ្នកមួយសំណួរ តែអ្នកមិនដឹងចម្លើយ? ប្រហែលជារឿងនេះបានកើតឡើង ចំពោះអ្នកពីមុនមក ។ ឥឡូវចូរស្រមៃមើលថា មាននរណាម្នាក់អង្គុយក្បែរអ្នក ដែលខ្សឹបប្រាប់ចម្លើយអ្នក! ក្នុងនាមជាកូនព្រះ អ្នកមិនចាំបាច់ស្រមៃមើលនោះទេ គឺមាននរណាម្នាក់ជួយអ្នកតែងតែជួយអ្នកជានិច្ច ។ អ្នកមានព្រះវិញ្ញាណបរិសុទ្ធ នៅក្នុងអ្នក ហើយព្រះគម្ពីរបាននិយាយថា ទ្រង់នឹងបង្រៀនអ្នកនូវអ្វីៗទាំងអស់ ។

អ្នកមិនអាចអន់ចិត្តឡើយ ព្រោះព្រះវិញ្ញាណបរិសុទ្ធ នឹងបង្រៀនអ្នកគ្រប់យ៉ាង! សូមសរសើរដំកើងព្រះអម្ចាស់! សូមព្រះវិញ្ញាណបរិសុទ្ធ បង្រៀនអ្នកចាប់ពីថ្ងៃនេះតទៅ ។

សេចក្ដីប្រកាសពីបទទំនាយ
ឱព្រះអម្ចាស់អើយ សូមអរព្រះគុណទ្រង់ ដែលទូលបង្គំនឹងមានអ្វីៗគ្រប់យ៉ាង ដែលទូលបង្គំត្រូវការជានិច្ច ។ សូមអរគុណចំពោះការប្រទាន ព្រះវិញ្ញាណបរិសុទ្ធមកជួយទូលបង្គំ ។ ទ្រង់គឺជាគ្រូរបស់ទូលបង្គំ ហើយទ្រង់បង្ហាញទូលបង្គំ ពីអ្វីដែលត្រូវធ្វើ ។ សូមអរគុណព្រះវរបិតា សម្រាប់អំណោយទានដ៏អស្ចារ្យនេះ! អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ សូមអរព្រះគុណទ្រង់ ដែលទូលបង្គំនឹងមានអ្វីៗគ្រប់យ៉ាង ដែលទូលបង្គំត្រូវការជានិច្ច ។ សូមអរព្រះគុណចំពោះការប្រទាន ព្រះវិញ្ញាណបរិសុទ្ធមកជួយទូលបង្គំ ។ ទ្រង់គឺជាគ្រូរបស់ទូលបង្គំ ហើយទ្រង់បង្ហាញទូលបង្គំពីអ្វីដែលត្រូវធ្វើ ។ សូមអរព្រះគុណព្រះវរបិតា សម្រាប់អំណោយដ៏អស្ចារ្យនេះ! អាម៉ែន ។

ការសិក្សាបន្ថែម
យ៉ូហាន 14:25-26



ថ្ងៃពុធ ទី17 ខែធ្នូ

សេចក្តីជំនឿក្នុងសកម្មភាព

លោកុប្បត្តិ 12:4 (ពគប)
អាប់រ៉ាមក៏ចេញទៅ ដូចជាព្រះយេហូវ៉ាបានបង្គាប់ ឡុតក៏ទៅជាមួយដែរ កាលអាប់រ៉ាមចេញពីខារ៉ានទៅ នោះគាត់អាយុបាន៧៥ឆ្នាំហើយ ។

ចូរស្រមៃមើលថា តើព្រះបានប្រាប់អ្នកឱ្យចាកចេញ ពីអ្វីគ្រប់យ៉ាងដែលអ្នកដឹងផ្ទះរបស់អ្នក មិត្តភក្តិរបស់អ្នក និងទីក្រុងរបស់អ្នក ហើយទៅកន្លែងមួយដែលទ្រង់នឹងបង្ហាញអ្នកនៅពេលក្រោយ ។ នោះហើយជាអ្វីដែលបានកើតឡើង ចំពោះលោកតាអ័ប្រាហាំ ។ តាំងពីយូរយារណាស់មកហើយ ព្រះបានប្រាប់លោកតាអ័ប្រាហាំ ឲ្យចាកចេញពីផ្ទះរបស់គាត់នៅហារ៉ាន ហើយទៅស្រុកថ្មី ។ លោកតាអ័ប្រាហាំបានស្តាប់ហើយធ្វើតាម ។ គាត់បានបង្ហាញសេចក្តីជំនឿរបស់គាត់ដោយធ្វើតាមអ្វីដែលព្រះបានមានបន្ទូល ។

កូនៗអើយ សេចក្តីជំនឿមិនមែនគ្រាន់តែ និយាយថាអ្នកជឿនោះទេ ។ នៅពេលអ្នកធ្វើសកម្មភាព វាបង្ហាញថ្លា អ្នកពិតជាទុកចិត្តលើព្រះ ។ ដូច្នេះតើអ្នកកំពុងរង់ចាំអ្វី? អនុវត្តសេចក្តីជំនឿរបស់អ្នកនៅថ្ងៃនេះ! ចូរជឿដល់ព្រះ ហើយធ្វើអ្វីដែលទ្រង់ប្រាប់អ្នកឲ្យធ្វើ!

សេចក្តីប្រកាសពីបទទំនាយ
ឱព្រះអម្ចាស់អើយ នៅក្នុងឆ្នាំនេះ ប្រហែលជាជិតអស់ហើយ ប៉ុន្តែទូលបង្គំនៅតែអនុវត្ត សេចក្តីជំនឿរបស់ទូលបង្គំ ។ ទូលបង្គំដឹងថា នេះប្រាកដជានឹងនាំមកនូវលទ្ធផល ។ ហាលេលូយ៉ា ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ ឆ្នាំនេះនឹងជិតអស់ហើយ ប៉ុន្តែទូលបង្គំនៅតែអនុវត្តសេចក្តីជំនឿរបស់ទូលបង្គំ ។ ទូលបង្គំដឹងថា នេះប្រាកដជានឹងនាំមកនូវលទ្ធផល ។ ហាលេលូយ៉ា ។ អាម៉ែន ។

ការសិក្សាបន្ថែម
លោកុប្បត្តិ 12:1-4



ថ្ងៃព្រហស្បតិ៍ ទី18 ខែធ្នូ

សូមថ្វាយសិរីល្អដល់ព្រះអម្ចាស់

ទំនុកតម្កើង 68:35 (ពគប)
ឱព្រះអង្គ ទ្រង់គួរស្ញែងខ្លាចនៅក្នុងទីបរិសុទ្ធរបស់ទ្រង់ ព្រះនៃសាសន៍អ៊ីស្រាអែល ទ្រង់ប្រទានកំឡាំង និងអំណាចដល់រាស្ត្រទ្រង់ សូមឲ្យព្រះបានប្រកបដោយព្រះពរចុះ!

ជើងដ៏ល្បីល្បាញបំផុតមួយ ក្នុងព្រះគម្ពីរដែលនិយាយអំពីដាវីឌ និងកូលីយ៉ាត។ ប៉ុន្តែតើអ្នកដឹងទេថា ដាវីឌ ក៏ជាតន្ត្រីករ និងជាអ្នកនិពន្ធបទចម្រៀងផងដែរ។ គាត់បាននិពន្ធបទចម្រៀងជាច្រើន ដើម្បីថ្វាយបង្គំព្រះ ហើយបទខ្លះមានក្នុងគម្ពីរទំនុកដកើង។

ការសរសើរតម្កើង ព្រះអម្ចាស់មានន័យថា ដាក់ទ្រង់ជាទីក្នុងជីវិតរបស់អ្នក។ វានិយាយអំពីការ និយាយល្អ អំពីព្រះជានរណា ហើយតើទ្រង់អស្ចារ្យប៉ុណ្ណា។ ពេលយើងសរសើរតម្កើងព្រះ វាផ្តល់សិរីល្អដល់ទ្រង់!


នៅក្នុងបទចម្រៀងមួយរបស់គាត់ ដាវីឌបាននិយាយថា «ព្រះអម្ចាស់ ទ្រង់អស្ចារ្យណាស់ក្នុងព្រះវិហាររបស់ទ្រង់»។ កូនៗ នៅពេលអ្នកសរសើរតម្កើងព្រះអម្ចាស់ ចូរធ្វើវាឱ្យមានលក្ខណៈផ្ទាល់ខ្លួន។ ចូរនិយាយទៅកាន់ទ្រង់ថា «ព្រះទ្រង់មានព្រះហឫទ័យសប្បុរស ទ្រង់មានកំឡាំង ទ្រង់ជាជំនួយរបស់ខ្ញុំ!» និយាយអ្វីដែលអ្នកមានអារម្មណ៍នៅក្នុងចិត្ត។

នៅពេលអ្នកសរសើរ ចូរព្យាយាមរួសមែមើលព្រះ ហើយគិតអំពីថា តើទ្រង់ស្រឡាញ់អ្នកប៉ុណ្ណា។ អ្នកមានជីវិតរបស់ព្រះយេស៊ូវនៅក្នុងអ្នក។ ទ្រង់ស្គាល់អ្នកយ៉ាងល្អិតល្អន់ ហើយអ្នកអាចស្គាល់ទ្រង់ផងដែរ ពីព្រោះអ្នកគឺជាកូនរបស់ទ្រង់។ ដូច្នេះ ចូរបើកមាត់ ហើយសរសើរទ្រង់នៅថ្ងៃនេះ! ចូរនិយាយអ្វីដែលពិសេសដល់ព្រះ ហើយឲ្យចិត្តអ្នកពោរពេញដោយអំណរ។ ហាលេលូយ៉ា!

សេចក្តីប្រកាសពីបទទំនាយ
ព្រះអម្ចាស់អើយ ព្រះអង្គពិតជាអស្ចារ្យមែន! អ្វីគ្រប់យ៉ាងដែលអ្នកធ្វើ គឺល្អឥតខ្ចោះ ហើយទូលបង្គំ នឹងបន្តច្រៀងសរសើរទ្រង់។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ ព្រះអង្គពិតជាអស្ចារ្យមែន! អ្វីគ្រប់យ៉ាងដែលទ្រង់ធ្វើគឺល្អឥតខ្ចោះ ហើយទូលបង្គំនឹងបន្ត ច្រៀងសរសើរដំកើងទ្រង់ជានិច្ច។ អាម៉ែន។

ការសិក្សាបន្ថែម
ទំនុកដំកើង 72:18



ថ្ងៃសុក្រ ទី19 ខែធ្នូ

ការបន្ទាបខ្លួន

ភីលីព 2:5-6 (ICB)
[5]ត្រូវតែមានគំនិតគិតដូចជាព្រះគ្រីស្ទយេស៊ូវវិញ [6]ដែលទោះបើទ្រង់មានរូបអង្គជាព្រះក៏ដោយ គង្វតែមិនបានរាប់សេចក្តីដែលស្មើនឹងព្រះនោះ ទុកជាសេចក្តីដែលគួរកាន់ខ្ជាប់ឡើយ ។

ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះរាជបុត្រានៃព្រះ ហើយដូចជាព្រះនៅក្នុងគ្រប់មធ្យោបាយ ទ្រង់មានអំណាច គ្រប់លក្ខណ៍ និងពេញដោយសេចក្តីស្រឡាញ់ ។ ប៉ុន្តែ ទោះជាទ្រង់មានអំណាចទាំងអស់នោះក៏ដោយ ក៏ព្រះយេស៊ូមិនអួត ឬធ្វើដូចទ្រង់ល្អជាងអ្នកដទៃដែរ ។ ទ្រង់បានជ្រើសរើសរស់នៅ ដោយការបន្ទាបខ្លួន ហើយបម្រើមនុស្សដោយសេចក្តីសប្បុរស និងសេចក្តីស្រឡាញ់ ។


ព្រះយេស៊ូវបានជួយអ្នកជំងឺ ផ្តល់អាហារដល់អ្នកស្រេកឃ្លាន ហើយថែមទាំងលាងជើងមិត្តភក្តិទ្រង់ផង ។ ទ្រង់បានប្រទានពេលវេលា និងសេចក្តីស្រឡាញ់របស់ទ្រង់ ដល់មនុស្សគ្រប់គ្នា ហើយទ្រង់ថែមទាំងបានប្រទានជីវិតរបស់ទ្រង់ សម្រាប់យើងទៀតផង ។ នោះហើយជារបៀប ដែលទ្រង់យកចិត្តទុកដាក់!

ព្រះគម្ពីរប្រាប់យើងឲ្យគិត និងធ្វើដូចព្រះយេស៊ូវ ។ នោះមានន័យថា យើងគួរតែមានសេចក្តីស្រឡាញ់ សេចក្តីសប្បុរស ពេញដោយការជួយ និងបន្ទាបខ្លួន ។ ពេលយើងធ្វើតាមគំរូ របស់ព្រះយេស៊ូវ យើងកាន់តែដូចជាទ្រង់ ហើយនោះធ្វើឲ្យមាន ការផ្លាស់ប្តូរដ៏ធំមួយ ក្នុងពិភពលោក!

សេចក្តីប្រកាសពីបទទំនាយ
ឱព្រះអម្ចាស់អើយ សូមអរព្រះគុណទ្រង់ ដែលបានប្រទានឱ្យទូលបង្គំ មានគំនិតដូចគ្នានឹងព្រះគ្រីស្ទ ។ ដូចព្រះយេស៊ូវ ទូលបង្គំជ្រើសរើសការបន្ទាបខ្លួន បម្រើអ្នកដទៃ ហើយមានចិត្តសប្បុរស ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ សូមអរព្រះគុណទ្រង់ ដែលបានប្រទានឱ្យទូលបង្គំ មានគំនិតដូចគ្នានឹងព្រះគ្រីស្ទ ។ ដូចព្រះយេស៊ូវ ទូលបង្គំជ្រើសរើសបន្ទាបខ្លួន បម្រើអ្នកដទៃ ហើយមានចិត្តសប្បុរស ។ អាម៉ែន ។

ការសិក្សាបន្ថែម
សុភាសិត 22:4



ថ្ងៃសៅរ៍ ទី20 ខែធ្នូ

ក្តាហានដូចកាលែប

ជនគណនា 13:30 (ពគប)
ឯកាលែប លោកឲ្យបណ្តាជននៅស្ងៀមចំពោះមុខម៉ូសេ រួចនិយាយថា ចូរយើងឡើងទៅចាប់យកស្រុកនោះជាប្រាជ្ញាប់កុំខាន ដ្បិតយើងអាចនឹងយកបានដោយស្រួល ។

សូមមើលពី កាលែប ជាឧទាហរណ៍មួយ នៃមនុស្សម្នាក់ដែលបានដើរ ដោយសេចក្តីជំនឿក្នុងបទគម្ពីរសព្វថ្ងៃ ។


កាលែបគឺជាអ្នកស៊ើបការណ៍ម្នាក់ ដែលបានបញ្ជូនទៅពិនិត្យមើលទឹកដី ដែលព្រះបានសន្យាថា នឹងប្រទានឲ្យរាស្ត្ររបស់ទ្រង់ ។ ខណៈដែលអ្នកខ្លះទ្បែតភ័យខ្លាច ហើយគិតថាមិនអាចយកដីបាននោះ កាលែបពេញដោយសេចក្តីជំនឿ! គាត់បាននិយាយយ៉ាងក្លាហានថា កូនចៅអ៊ីស្រាអែលអាចយកទឹកដីបានដោយសារព្រះនៅជាមួយពួកគេ ។

កូនៗកុំខ្លាចអី! ចូរជឿលើព្រះ និងព្រះបន្ទូលរបស់ទ្រង់ នោះអ្នកនឹងឃើញរឿងដ៏អស្ចារ្យ កើតឡើងនៅក្នុងជីវិតរបស់អ្នក ។ បន្តដើរដោយសេចក្តីជំនឿ នោះអ្នកនឹងមានទីបន្ទាល់ផ្ទាល់ខ្លួនរបស់អ្នក ដើម្បីចែកចាយ!

សេចក្តីប្រកាសពីបទគំនាយ
ព្រះបានប្រទានទឹកដីសន្យា ដល់ទូលបង្គំរួចហើយ ។ ទូលបង្គំកំពុងធ្វើតាមព្រះបន្ទូល ហើយទូលបង្គំនឹងឃើញទីបន្ទាល់របស់ទូលបង្គំ នៅក្នុងព្រះនាមព្រះយេស៊ូវ ដ៏មានគ្រប់ព្រះចេស្តា ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ សូមអរព្រះគុណព្រះអង្គ ដែលបានប្រទានឱ្យទូលបង្គំ មានភាពក្លាហានដូចកាលែប ។ សូមជួយទូលបង្គំឲ្យជឿទុកចិត្តទ្រង់ ហើយក្លាហានដោយដឹងថាទ្រង់នៅជាមួយទូលបង្គំជានិច្ច ។ អាម៉ែន ។

ការសិក្សាបន្ថែម
ជនគណនា 13:27-30



ថ្ងៃអាទិត្យ ទី21 ខែធ្នូ

ការសរសើរតែជាអាវុធ

2 របាក្សត្រ 20:21 (ពគប)
រួចកាលទ្រង់បានពិគ្រោះនឹងបណ្តាជនហើយ នោះទ្រង់ក៏ដំរូវឲ្យមានពួកអ្នក ដែលត្រូវច្រៀងថ្វាយព្រះយេហូវ៉ា ហើយពោលសរសើរ ដោយស្លៀកពាក់ជា ប្រដាប់បរិសុទ្ធ ក្នុងកាលដែលគេនាំមុខពួកទ័ពចេញទៅ ដោយពោលថា ចូរអរ ព្រះគុណដល់ព្រះយេហូវ៉ាចុះ ឱ្យតសេចក្តីសប្បុរសទ្រង់នៅជាប់អស់កល្បជានិច្ច ។

កាលពីយូរយារណាស់មកហើយ មានស្តេចយូដាមួយអង្គ ហៅស្តេចយ៉ូសាផាត ដែលមានបញ្ហាធំ ។ ទ្រង់មានខ្មាំងសត្រូវ ចង់ប្រយុទ្ធដើម្បីទឹកដី និងប្រជាជន ។ ក្នុងនាមជាស្តេចដ៏សុចរិត ស្តេចយ៉ូសាផាតបានទំនាក់ទំនង នឹងព្រះអម្ចាស់ ក្នុងការសម្រេចចិត្តរបស់ព្រះអង្គ ។ ទ្រង់ដាក់មនុស្សដែលសរសើរតម្កើងព្រះអម្ចាស់ នៅមុខកងទ័ព ។ ព្រះបានសន្យាថា រាស្ត្ររបស់ទ្រង់ នឹងមានជ័យជំនះលើ ខ្មាំងសត្រូវ ។

កូនៗនេះគួរឱ្យកត់សម្គាល់! ជាជាងយំ ហើយអង្គុយដោយបាក់ទឹកចិត្ត ស្តេចយ៉ូសាផាត និងយូដាបានសរសើរតម្កើងព្រះអម្ចាស់ នៅកណ្តាលខ្មាំងសត្រូវ ហើយ ទាយថាអ្វីដែលពួកគេឈ្នះ ។ សូមថ្វាយសិរីល្អដល់ព្រះអម្ចាស់! នៅពេលដែល បញ្ហាប្រឈម មកដល់ផ្ទះរបស់អ្នក ចូរដឹងថាការសរសើរតម្កើងព្រះ នៅក្នុងបញ្ហា គឺជាអាវុធសម្ងាត់របស់អ្នក!

សេចក្តីប្រកាសពីបទទំនាយ
ឱព្រះអម្ចាស់អើយ នៅពេលដែលទូលបង្គំឃើញខ្លួនឯង ស្ថិតក្នុងស្ថានភាពលំបាក ទូលបង្គំនឹងមិនឈប់សរសើរព្រះអង្គឡើយ ។ អ្នកគឺបរិសុទ្ធនឹងអស្ចារ្យ សេចក្តី ស្រឡាញ់របស់អ្នក ស្ថិតស្ថេរជារៀងរហូត! អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ នៅពេលដែលទូលបង្គំ ឃើញខ្លួនឯងស្ថិតក្នុងស្ថានភាពលំបាក ទូលបង្គំនឹងមិនឈប់សរសើរព្រះអង្គឡើយ ។ ទ្រង់គឺបរិសុទ្ធ នឹងអស្ចារ្យ, សេចក្តី ស្រឡាញ់របស់ទ្រង់ គឺស្ថិតស្ថេរជារៀងរហូត! អាម៉ែន ។

ការសិក្សាបន្ថែម
ទំនុកដំកើង 8:2



ថ្ងៃចន្ទ ទី22 ខែធ្នូ

មិនមានផែនការទី2ទេ

នាងអេសធើរ 4:16 (ពគប)
សូមទៅប្រមូលពួកសាសន៍យូដា ដែលនៅក្រុងស៊ូសានឲ្យប្រជុំគ្នាតមអត់ឲ្យខ្ញុំ ក៏ឲ្យបរិភោគអ្វីទាំងយប់ទាំងថ្ងៃអស់រវាង៣ថ្ងៃ ឯខ្ញុំ នឹងពួកស្ត្រីបំរើរបស់ខ្ញុំ ក៏នឹងតមដូច្នោះដែរ យ៉ាងនោះ ខ្ញុំនឹងចូលទៅគាល់ស្តេច ដែលជាការខុសច្បាប់ ហើយបើខ្ញុំត្រូវស្លាប់ ក៏ស្លាប់ទៅចុះ ។

ពេលអ្នកដើរដោយសេចក្តីជំនឿ គ្មានផែនការទី2! តាំងពីយូរយារណាស់មកហើយ មានស្ត្រីម្នាក់ ឈ្មោះម្ចាស់ក្សត្រី អេសធើរ ដែលបានសម្រេចចិត្ត ប្រថុយជីវិតដើម្បី ជួយសង្គ្រោះជនជាតិយូដា ។ នាងបានបង្ហាញពីសេចក្តីជំនឿរបស់នាង នៅក្នុងការជួយសង្គ្រោះប្រជាជនរបស់នាង ពីផែនការអាក្រក់របស់ហាម៉ាន ដោយប្រកាសយ៉ាងក្លាហានថា «ប្រសិនបើខ្ញុំត្រូវវិនាស ខ្ញុំនឹងត្រូវវិនាសទៅចុះ!»

កូនៗ យើងបានឃើញសេចក្តីជំនឿដ៏អស្ចារ្យ ក្នុងសកម្មភាពក្នុងសប្តាហ៍នេះ ហើយដំណើរផ្សងព្រេងនៃសេចក្តីជំនឿថ្ងៃនេះ ក៏មិនខ្វះសគ្គាដែរ ។ សេចក្តីជំនឿប្រកាសយ៉ាងក្លាហានថា «ខ្ញុំគ្មានផែនការទី2ទេ» ហើយអ្នកចាត់វិធានការ ដើម្បីបម្រុងទុកពាក្យនោះ ។ ទីបន្ទាល់របស់អ្នកគឺប្រាកដ នៅក្នុងឆ្នាំនេះអ្នកបំបែកច្រវាក់នេះ ។ ធ្វើដាក់ព្រះបន្ទូលរបស់ព្រះឲ្យដំណើរការ ហើយយើងនឹងឃើញថា វាដំណើរការក្នុងជីវិតរបស់អ្នក! អាម៉ែន!

សេចក្តីប្រកាសពីបទពិសោធ
ដូចម្ចាស់ក្សត្រីអេសធើរ ខ្ញុំប្រកាសយ៉ាងក្លាហានថា ខ្ញុំគ្មានផែនការទី2ទេ គ្មានផែនការបម្រុងទុក! ខ្ញុំនឹងមិនត្រូវអាម៉ាស់ឡើយ ពេលខ្ញុំដាក់ព្រះបន្ទូលរបស់ព្រះឲ្យដំណើរការ ។ មានទីបន្ទាល់ហើយមានទីបន្ទាល់ទៀតជារបស់ខ្ញុំ ។ ហាលេលូយ៉ា! សូមថ្វាយសិរីល្អដល់ព្រះអម្ចាស់!

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ សូមប្រទានឱ្យទូលបង្គំមានចិត្តក្លាហាន ធ្វើអ្វីដែលត្រឹមត្រូវ និងជឿជាក់លើព្រះអង្គ ទោះមានអ្វីកើតឡើងក៏ដោយ ។ សូមជួយទូលបង្គំឲ្យមានចិត្តក្លាហានដូចនាងអេសធើរ ហើយដឹងថាអ្នកនៅជាមួយទូលបង្គំជានិច្ច ។ អាម៉ែន ។

ការសិក្សាបន្ថែម
នាងអេសធើរ 7:1-10



ថ្ងៃអង្គារ ទី23 ខែធ្នូ

ប្រទានពរច្រើនឥតគណនា

លូកា 1:28 (ពគប)
ទេវតាក៏ចូលមកឯនាងពោលថា ជំរាបសួរនាង ឱនាងដែលប្រកបដោយព្រះគុណអើយ ព្រះអម្ចាស់ទ្រង់គង់នៅជាមួយនឹងនាង ក្នុងបណ្តាពួកស្ត្រីៗ នាងជាស្ត្រីមានពរពិត ។

ថ្ងៃមួយ ទេវតាពិសេសមួយបានមករក នារីវ័យក្មេងម្នាក់ឈ្មោះម៉ារា ។ ទេវតាប្រាប់នាងថា ៖ «ព្រះអម្ចាស់បានប្រទានពរអ្នក ហើយគង់នៅជាមួយអ្នក» ។ នោះជារឿងធំណាស់ ដែលត្រូវនិយាយ! អ្នកឃើញទេ ម៉ារា ន្នឹងក្លាយជាមាតារបស់ព្រះយេស៊ូវ ជាព្រះរាជបុត្រានៃព្រះ ។ ប៉ុន្តែមុននឹងនាងដឹងនោះ ទេវតាបានរំឭកនាងថា ព្រះគង់នៅជាមួយនាង ហើយព្រះបានប្រទានពរដល់នាង ។

ដូចជាម៉ារាដែរ ព្រះក៏គង់នៅជាមួយអ្នកដែរ! ព្រះទ្រង់ស្រឡាញ់អ្នក ហើយតែងតែនៅទីនោះសម្រាប់អ្នក ។ នៅពេលអ្នកមានអារម្មណ៍រីករាយ សោកសៅ ឬសូម្បីតែភ័យខ្លាច ចូរចាំថាព្រះអម្ចាស់គង់នៅក្បែរអ្នក ។ ទ្រង់ក៏បានប្រទានពរដល់អ្នក នូវអំពើល្អជាច្រើនផងដែរ ។ គិតអំពីមនុស្សដែលអ្នកស្រលាញ់ ភាពរីករាយដែលអ្នកបានធ្វើ និងសេចក្តីរីករាយនៅក្នុងចិត្តរបស់អ្នក ។ ទាំងនោះសុទ្ធតែជាព្រះពរមកពីព្រះ!

សេចក្តីប្រកាសពីបទទំនាយ
ឱព្រះអម្ចាស់អើយ ទូលបង្គំមានពរច្រើនឥតគណនា ដោយបានទទួលបុណ្យជ្រមុជទឹក ក្នុងព្រះគ្រីស្ទ និងជាមនុស្សថ្មីនៅក្នុងទ្រង់ ។ ព្រះវិញ្ញាណបរិសុទ្ធគង់នៅក្នុងខ្ញុំ ហើយខ្ញុំមិនអាចខូចចិត្តបានឡើយ ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ ទូលបង្គំមានពរលើសពីការរំពឹងទុក ដោយបានទទួលបុណ្យជ្រមុជក្នុងព្រះគ្រីស្ទ និងជាមនុស្សថ្មីនៅក្នុងទ្រង់ ។ ព្រះវិញ្ញាណបរិសុទ្ធគង់នៅក្នុងទូលបង្គំ ហើយទូលបង្គំមិនអាចខូចចិត្តបានឡើយ ។ អាម៉ែន ។

ការសិក្សាបន្ថែម
អេភេសូរ 1:3



ថ្ងៃពុធ ទី24 ខែធ្នូ

ព្រះគុណដ៏លើសលប់

លូកា 1:30 (ពគប)
តែទេវតានិយាយថា កុំខ្លាចអី ម៉ារាអើយ ដ្បិតព្រះបានប្រោសមេត្តាដល់នាងហើយ ។

នៅពេលដែលទេវតាបានមករកនាងម៉ារា ហើយបានប្រាប់នាងថា នាងពិតជាពិសេស ហើយបានទទួលការពេញចិត្តចំពោះព្រះ នាងមានការភ្ញាក់ផ្អើល និងសូម្បីតែភ័យខ្លាចបន្តិចក៏គ្មានដែរ ។ នាងមិនយល់ថាតើវាអាចពិតយ៉ាងណា ។


ប៉ុន្តែនេះគឺជាអ្វីដែលអស្ចារ្យ៖ ប្រសិនបើអ្នកជាកូនរបស់ព្រះ នោះព្រះក៏ស្រឡាញ់អ្នកដែរ ហើយទ្រង់ចង់ប្រើអ្នក ដើម្បីអនុវត្តកិច្ចការរបស់ទ្រង់ នៅលើផែនដី! ទ្រង់បានទទួលយកអ្នក ហើយស្រឡាញ់អ្នកខ្លាំងណាស់ ។ អ្នកបានទទួលការពេញចិត្តនឹងទ្រង់ ដោយសារព្រះយេស៊ូវ ។ នេះគេហៅថាព្រះគុណ ជាអំណោយទាន ដ៏ពិសេសដែលយើងមិនត្រូវរក ។

ដូច្នេះកុំខ្លាចក្នុងការនិយាយជាមួយព្រះ ។ ទ្រង់ជាព្រះវរបិតា ដ៏ជាទីស្រឡាញ់របស់អ្នក ហើយទ្រង់ពេញចិត្តនឹងអ្នក ។ សូមរីករាយចំណាយពេលជាមួយទ្រង់ ទ្រង់ស្រឡាញ់នៅជាមួយអ្នក!

សេចក្តីប្រកាសពីបទទំនាយ
សូមអរព្រះគុណព្រះអម្ចាស់ សម្រាប់ការពេញចិត្ត ព្រះគុណ និងសេចក្តីមេត្តាករុណា ដែលទ្រង់បានបង្ហាញទូលបង្គំ ក្នុងជីវិតរបស់ទូលបង្គំ ។ ទូលបង្គំដឹងថាទ្រង់សព្វព្រះហឫទ័យ និងទូលបង្គំ ពីព្រោះទ្រង់សព្វព្រះហឫទ័យនឹងព្រះគ្រីស្ទដែលគង់នៅក្នុងទូលបង្គំ ។ សូមថ្វាយសិរីល្អដល់ព្រះអម្ចាស់!

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ សូមអរព្រះគុណព្រះអង្គសម្រាប់ការស្រឡាញ់ទូលបង្គំ ហើយជ្រើសរើសទូលបង្គំសម្រាប់របស់ពិសេសៗ ។ សូមជួយទូលបង្គំឲ្យក្លាហាន ហើយស្តាប់ទ្រង់ជារៀងរាល់ថ្ងៃ ។ អាម៉ែន ។

ការសិក្សាបន្ថែម
អេភេសូរ 1:6



ថ្ងៃព្រហស្បតិ៍ ទី25 ខែធ្នូ

សង់បន្ទប់

លូកា 2:7 (ពគប)
ហើយនាងប្រសូតបានបុត្រាជាចំបងមក រួចរុំនឹងសំពត់ផ្តេកក្នុងស្នូក ពីព្រោះក្នុងផ្ទះសំណាក់គ្មានកន្លែងណានៅទេ ។

តាំងពីយូរយារណាស់មកហើយ មានរឿងដ៏អស្ចារ្យមួយ បានកើតឡើង ព្រះយេស៊ូវគ្រីស្ទ បានប្រសូតមក!

ម៉ារា និងយ៉ូសែប នៅក្នុងក្រុងមួយឈ្មោះបេថ្លេហិម ប៉ុន្តែបន្ទប់ទាំងអស់ក្នុងផ្ទះសំណាក់ (ដូចជាសណ្ឋាគារ) គឺពេញ ។ មិនមានកន្លែងពិសេស សម្រាប់ពួកគេស្នាក់នៅទេ ។ ដូច្នេះនៅពេលដែលទារកព្រះយេស៊ូវបានប្រសូតមក ម៉ារាបានរុំទ្រូងដោយក្រណាត់ទន់ ហើយដាក់ទ្រូងថ្មមៗនៅក្នុងស្នូកមួយ ដែលជាប្រអប់មួយដែលសត្វ សុីអាហាររបស់ពួកគេ!


ទោះជាព្រះយេស៊ូវ ជាព្រះរាជបុត្រានៃព្រះក៏ដោយ ក៏ទ្រង់បានប្រសូត ក្នុងទីស្ងាត់និងរាបទាប ។ ព្រះមិនបានជ្រើសរើសមាន ដំប្រណិតសម្រាប់ព្រះយេស៊ូវនៅទី ទ្រង់បានជ្រើសរើស ក្រោលដ៏សាមញ្ញមួយ ។ នោះបង្ហាញយើងនូវអ្វី ដែលសំខាន់ ; ព្រះស្រឡាញ់មនុស្សគ្រប់គ្នា មិនថាពួកគេជានរណា ឬមកពីណានោះទេ ។ ជាការរំលឹកដ៏មានអានុភាព និងដ៏ជ្រាលជ្រៅ អំពីការចាប់ផ្តើមដ៏រាបទាបរបស់ព្រះយេស៊ូវគ្រីស្ទ និងអត្ថន័យពិតនៃបុណ្យណូអែល ។

ចំពេលការប្រារព្ធពិធីទាំងអស់ វាជាក្តារង្វាយស្រួលក្នុងការភ្លេចថា បុណ្យណូអែលគឺអំពីទ្រង់ ។ ការចំណាយពេលបន្តិច ដើម្បីឆ្លុះបញ្ចាំងពីកំណើតរបស់ទ្រង់ និងសារៈសំខាន់ប្រសិទ្ធ នៅក្នុង ជីវិតរបស់យើង បន្ថែមអត្ថន័យដល់សេចក្តីអំណរ នៃរដូវកាលនេះ ។ ដំណឹងល្អ និងជូនពរ បុណ្យណូអែល ដល់អ្នកទាំងអស់គ្នា!

សេចក្តីប្រកាសពីបទទំនាយ
ក្នុងរដូវបុណ្យណូអែលនេះ ខ្ញុំប្រើកចិត្តដើម្បីអបអរ និងទទួលស្គាល់ ពីការប្រសូតរបស់ព្រះយេស៊ូវគ្រីស្ទ ។ សូមសរសើរតម្កើងព្រះអម្ចាស់! អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់ដ៏ធំ ក្នុងរដូវបុណ្យណូអែលនេះ ទូលបង្គំបើកចិត្តរបស់ទូលបង្គំ ដើម្បីអបអរសាទរ និងទទួលស្គាល់ការប្រសូតរបស់ព្រះយេស៊ូវគ្រីស្ទ ។ សូមសរសើរតម្កើងព្រះអម្ចាស់! អាម៉ែន ។

ការសិក្សាបន្ថែម
លូកា 2:1-7



ថ្ងៃសុក្រ ទី26 ខែធ្នូ

បទទំនាយបានសម្រេច

លូកា 2:21 (ពគប)
លុះដល់គំរប់៨ថ្ងៃ កាលត្រូវកាត់ស្បែកព្រះឱរស នោះគេថ្វាយព្រះនាមថា «យេស៊ូវ» ជានាមដែលទេវតាបានប្រាប់ មុនដែលទ្រង់មកចាប់ទំផ្ទៃ ។


នៅពេលដែលទារកព្រះយេស៊ូវ មានព្រះជន្មបានប្រាំបីថ្ងៃ មានអ្វីពិសេសបានកើតឡើង ទ្រង់ត្រូវបានគេដាក់ព្រះនាមទ្រង់! ទេវតាបានប្រាប់ម៉ារា សូម្បីតែមុននាងមានផ្ទៃពោះថា ទារកនោះឈ្មោះយេស៊ូវ ។

ហេតុអ្វីបានជាវាសំខាន់ម្ល៉េះ? ដោយសារព្រះនាមយេស៊ូវ មានន័យថា «ព្រះនៃសង្គ្រោះ» ។ ព្រះយេស៊ូវបានយាងមក ដើម្បីសង្គ្រោះយើងពីអំពើបាប ហើយនាំយើងទៅជិតព្រះ ។ ព្រះនាមទ្រង់រំឭកយើង អំពី ទ្រង់ជានរណា ហើយហេតុអ្វីបានជាទ្រង់យាងមក ដើម្បីបង្ហាញយើងនូវសេចក្តីស្រឡាញ់របស់ព្រះ និងជ្វាព្រះអង្គសង្គ្រោះរបស់យើង ។ សូម្បីតែព្រះនាមទ្រង់ ក៏ជាផ្នែកមួយនៃផែនការដ៏ធំរបស់ព្រះ!

សេចក្តីប្រកាសពីបទទំនាយ
ឱព្រះអម្ចាស់អើយ សូមអរគុណចំពោះព្រះនាមព្រះយេស៊ូវ ។ សូមអរព្រះគុណទ្រង់ ដែលទ្រង់យាងមកសង្គ្រោះទូលបង្គំ ហើយបង្ហាញសេចក្តីស្រឡាញ់របស់ទ្រង់ដល់ទូលបង្គំ ។ សូមជួយខ្ញុំឲ្យចងចាំជានិច្ចថាតើព្រះនាមរបស់ព្រះយេស៊ូវគឺពិសេសប៉ុណ្ណា ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ សូមអរគុណចំពោះព្រះនាមព្រះយេស៊ូវ ។ សូមអរព្រះគុណទ្រង់ដែលទ្រង់យាងមកសង្គ្រោះទូលបង្គំ ហើយបង្ហាញ សេចក្តីស្រឡាញ់របស់ទ្រង់ដល់ទូលបង្គំ ។ សូមជួយទូលបង្គំឲ្យចងចាំជានិច្ចថា តើព្រះនាមរបស់ព្រះយេស៊ូវគឺពិសេសប៉ុណ្ណា ។ អាម៉ែន ។

ការសិក្សាបន្ថែម
2 ពេត្រុស 1:19



ថ្ងៃសៅរ៍ ទី27 ខែធ្នូ

ក្នុងការភ្ញាក់ផ្អើល

លូកា 2:17 (ពគប)
កាលបានឃើញហើយ នោះគេក៏រ៉ាយរ៉ាប់រឿង ពីសេចក្ដីដែលទេវតាបានប្រាប់ពីព្រះឱរស។

តើអ្នកធ្លាប់បានអ្វីដែលថ្មី ដូចជារបស់ក្មេងលេង ឬសម្លៀកបំពាក់ ហើយអ្នករំភើបខ្លាំង ដែលអ្នកមិនអាចរង់ចាំប្រាប់មិត្តភក្តិនៅសាលា ឬព្រះវិហារទេ? អ្នកសប្បាយចិត្តណាស់ គ្រាន់តែចែករំលែកព័ត៌មាន!

នោះហើយជារឿប ដែលអ្នកគង្វាលមានអារម្មណ៍ នៅពេលដែលពួកគេបានឮថា ព្រះយេស៊ូវជាស្តេចបានប្រសូតមក។ ព្រះគម្ពីរចែងថា ពួកគេបានទៅប្រាប់អ្នករាល់គ្នា អំពីអ្វីដែលទេវតាបាននិយាយអំពីព្រះយេស៊ូវ។ មហាជនដែលបានឮដំណឹងនេះភ្ញាក់ផ្អើល!

កូនៗ កុំរក្សាដំណឹងល្អរបស់ព្រះយេស៊ូវ ចំពោះខ្លួនអ្នកឡើយ។ ចូរចែករំលែកវាជាមួយអ្នកដទៃ! អ្នកមិនដែលដឹងទេ ពាក្យរបស់អ្នកអាចជួយផ្លាស់ប្តូរ ជីវិតរបស់នរណាម្នាក់ជារៀងរហូត!

សេចក្តីប្រកាសពីបទទំនាយ
ដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ជាសារដែលខ្ញុំមិនខ្ទះខ្ទាយឡើយ។ វាគឺជាសារនៃម៉ោង ហើយវានឹងផ្លាស់ប្តូរជីវិត អ្នកណាម្នាក់តាមរយៈខ្ញុំ ក្នុងព្រះនាមព្រះយេស៊ូវដ៏មានគ្រប់ព្រះចេស្តា! អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ សូមអរព្រះគុណទ្រង់សម្រាប់ដំណឹងដ៏អស្ចារ្យរបស់ព្រះយេស៊ូវ។ សូមជួយទូលបង្គំឲ្យចែកចាយសេចក្តីស្រឡាញ់ និងសេចក្តីអំណរបស់ទ្រង់ ដល់អ្នករាល់គ្នាដែលនៅជុំវិញទូលបង្គំ។ អាម៉ែន។

ការសិក្សាបន្ថែម
លូកា 2:17-18



ថ្ងៃអាទិត្យ ទី28 ខែកញ្ញា

មាត្រដ្ឋានតុល្យភាព

លូកា 2:19 (ពគប)
តែម៉ារា នាងរក្សាទុកឃ្បឿងទាំងនោះ ដោយរំពឹងគិតតែក្នុងចិត្ត ។

កូនៗ ចូរអ្នកគិតមើលថា តើវាគួរឲ្យរំភើបចិត្តប៉ុណ្ណា ពេលព្រះយេស៊ូវប្រសូត ។ ម៉ារា ដែលជាម្តាយរបស់ទ្រង់ ច្បាស់ជ្លាមានអារម្មណ៍ថា មានឃ្បឿងជាច្រើនសប្បាយ អស្ចារ្យ សូម្បីតែមានការភ្ញាក់ផ្អើល! ព្រះគម្ពីរប្រាប់យើងថា នាងបានរក្សាគំនិត ទាំងអស់នេះក្នុងចិត្ត ហើយគិតអំពីវាជាញឹកញាប់ ។

កូនៗ ក្នុងអំឡុងពេលដ៏រីករាយ និងរំភើបនៃបុណ្យណូអែល សូមចំណាយពេលដ៏សប់ស្ងាត់មួយ ដើម្បីគិតអំពីថា តើព្រះមានគុណចំពោះអ្នកកម្រិតណា ។ អរគុណទ្រង់សម្រាប់សេចក្តីស្រឡាញ់ និងការយកចិត្តទុកដាក់របស់ទ្រង់ ហើយចងចាំពីរបៀបដែលទ្រង់ ស្មោះត្រង់ពេញមួយឆ្នាំ ។ នៅក្នុងរដូវកាលនេះ វាគឺជាពេលវេលាដើម្បីឆ្លុះបញ្ចាំង ពីកំណើតរបស់ព្រះយេស៊ូគ្រីស្ទ និងសេចក្តីអំណរ សេចក្តីស្រឡាញ់ និងសេចក្តីសុខសាន្ត ដែលទ្រង់បាននាំមកក្នុងជីវិតរបស់យើង ។

សេចក្តីប្រកាសពីបទទំនាយ
ខ្ញុំដូចជាពន្លឺភ្លឺនៅលើភ្នំ ដែលមនុស្សគ្រប់គ្នាអាចមើលឃើញ! ពន្លឺរបស់ទ្រង់បំភ្លឺខ្ញុំ ហើយខ្ញុំមិនអាចលាក់បាំងបានទេ ។ ព្រះបន្ទូលរបស់ទ្រង់ កំពុងជួយខ្ញុំឲ្យរីកចម្រើន និងភ្លឺជាងមុន ។ សូមអរព្រះគុណ ចំពោះការចាត់ព្រះយេស៊ូវ ជាពន្លឺនៃពិភពលោក បុណ្យណូអែលនេះ ។ អាម៉ែន!

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ សូមអរព្រះគុណទ្រង់ សម្រាប់ឃ្បឿងដ៏អស្ចារ្យដែលទូលបង្គំឃើញ និងឃ្បេនអំពីទ្រង់ជាឃ្បេងរាល់ថ្ងៃ ។ សូមជួយទូលបង្គំក្នុងការចងចាំ និងទុកវាទុកក្នុងចិត្តទូលបង្គំ អាម៉ែន ។

ការសិក្សាបន្ថែម
ទំនុកដំកើង 77:12



ថ្ងៃចន្ទ ទី29 ខែធ្នូ

ដំណឹងល្អ

លូកា 2:10 (ពគប)
តែទេវតាប្រាប់ថា កុំខ្លាចអី មើល ខ្ញុំមកប្រាប់ដំណឹងល្អដល់អ្នករាល់គ្នា ពីសេចក្តីអំណរយ៉ាងអស្ចារ្យ ដែលសំរាប់បណ្តាជនទាំងអស់គ្នា ។

ជាច្រើនឆ្នាំកន្លងទៅហើយ គ្រាន់តែក្រោយពីព្រះយេស៊ូវប្រសូតមក ទេវតាមួយអង្គបានលេចមកឲ្យអ្នកគង្វាល នៅវាលស្រែប្រាប់ថា កុំឲ្យភ័យខ្លាច ។ ទេវតាបានចែកចាយដំណឹងល្អ៖ ព្រះអង្គសង្គ្រោះបានប្រសូតមក នាំមកនូវសេចក្តីអំណរ ជាខ្លាំងដល់អ្នករាល់គ្នា! តើពេលវេលាដ៏រភើបយ៉ាងណា ។

កូនៗទាំងឡាយ ចូរចាំថា ដំណឹងដ៏អស្ចារ្យនេះ ពិតជាអស្ចារ្យណាស់ ដែលមិនអាចរក្សាទុកចំពោះខ្លួនអ្នកបាន ។ បុណ្យណូអែលគឺជាពេលវេលាដ៏ល្អឥតខ្ចោះដើម្បីចែករំលែកព្រះយេស៊ូវជាមួយក្រុមគ្រួសារ និងមិត្តភក្តិរបស់អ្នក ។ ចូរយើងផ្សព្វផ្សាយអំណោយដ៏ពិត នៃបុណ្យណូអែល ដែលជាដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ហើយនាំអ្នកដទៃមករកទ្រង់!

សេចក្តីប្រកាសពីបទទំនាយ
ឱព្រះអម្ចាស់អើយ បុណ្យណូអែលនេះ គឺជាពេលវេលា ដ៏ល្អឥតខ្ចោះ ដើម្បីចែកចាយដំណឹងល្អ នៃព្រះយេស៊ូវគ្រីស្ទ ជាមួយនរណាម្នាក់ ។ ខ្ញុំមានប្រាជ្ញា ព្រោះខ្ញុំឈោងចាប់ព្រលឹង ហើយខ្ញុំកំពុងនាំសេចក្តីអំណរ ដល់អ្នកណាម្នាក់នៅថ្ងៃនេះ ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ បុណ្យណូអែលនេះ គឺជាពេលវេលាដ៏ល្អឥតខ្ចោះ ដើម្បីចែកចាយដំណឹងល្អ នៃព្រះយេស៊ូវគ្រីស្ទ ជាមួយនឹងនរណាម្នាក់ ។ ទូលបង្គំមានប្រាជ្ញា ព្រោះទូលបង្គំឈោងចាប់ព្រលឹង ហើយទូលបង្គំកំពុងនាំសេចក្តីអំណរដល់អ្នកណាម្នាក់នៅថ្ងៃនេះ ។ អាម៉ែន ។

ការសិក្សាបន្ថែម
លូកា 2:10-11



ថ្ងៃអង្គារ ទី30 ខែធ្នូ

ចូរអរព្រះគុណដល់ទ្រង់

ទំនុកដំកើង 92:1-2 (ពគប)
[1]នេះជាការល្អហើយ គឺដែលនឹងអរព្រះគុណដល់ព្រះយេហូវ៉ា ហើយច្រៀងសរសើរដល់ព្រះនាមនៃទ្រង់ ជាព្រះដ៏ខ្ពស់បំផុត [2]ព្រមទាំងសំដែងពីសេចក្ដីសប្បុរសនៃទ្រង់នៅពេលព្រឹក ហើយពីសេចក្ដីស្មោះត្រង់របស់ទ្រង់រាល់តែយប់ ។

កូនៗនិយាយអ្វីពេលមិត្តម្នាក់ ជូនកាដូថ្ងៃខួបកំណើត? ត្រូវហើយ អ្នកនិយាយថា «អរគុណ!» វាគឺដូចគ្នាជាមួយនឹងព្រះ ។ នៅពេលអ្នកគិតអំពីអ្វីគ្រប់យ៉ាង ដែលព្រះបានធ្វើសម្រាប់អ្នកនៅឆ្នាំនេះ វាគ្រាន់តែជាការត្រឹមត្រូវ ក្នុងការនិយាយអរព្រះគុណ ចំពោះទ្រង់ផងដែរ!


ព្រះគម្ពីរប្រាប់ថា វាជាការល្អក្នុងការសរសើរព្រះ ហើយច្រៀងថ្វាយទ្រង់ ។ អ្នកអាចចាប់ផ្តើម ជាមួយរាល់ថ្ងៃ ដោយអរព្រះគុណទ្រង់ សម្រាប់សេចក្តីស្រឡាញ់របស់ទ្រង់ ហើយនៅពេលយប់ ចូរចងចាំគ្រប់វិធី ដែលទ្រង់បានជួយអ្នក ។

លើកដៃឡើង ច្រៀងចម្រៀង ឬអធិស្ឋានអ្វីក៏ដោយ ធ្វើដោយចិត្តដឹងគុណ ។ ព្រះទ្រង់ល្អណាស់ចំពោះអ្នកកាលពីឆ្នាំមុន ។ កុំបណ្តោយឱ្យថ្ងៃនេះកន្លងផុតទៅ ដោយនិយាយថា «សូមអរព្រះគុណព្រះអម្ចាស់!» ហាលេលូយ៉ា!

សេចក្តីប្រកាសពីបទទំនាយ
ឱព្រះអម្ចាស់អើយ ខ្ញុំច្រៀងសរសើរព្រះអង្គ ។ ទូលបង្គំប្រកាសសេចក្តីសប្បុរសរបស់ព្រះអង្គនៅពេលព្រឹក ហើយទូលបង្គំនិយាយអំពីសេចក្តីស្មោះត្រង់ របស់ព្រះអង្គនៅពេលយប់ ។ ទ្រង់ស្មោះត្រង់ណាស់ ហើយខ្ញុំទទួលស្គាល់សេចក្តីសប្បុរស របស់ទ្រង់នៅក្នុងជីវិតរបស់ខ្ញុំ ។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ ទូលបង្គំច្រៀងសរសើរព្រះអង្គ ។ ទូលបង្គំប្រកាសសេចក្តីសប្បុរសរបស់ព្រះអង្គ នៅពេលព្រឹក ហើយទូលបង្គំនិយាយអំពីសេចក្តីស្មោះត្រង់ របស់ព្រះអង្គនៅពេលយប់ ។ ទ្រង់ស្មោះត្រង់ណាស់ ហើយទូលបង្គំទទួលស្គាល់សេចក្តីសប្បុរសរបស់ទ្រង់ នៅក្នុងជីវិតរបស់ទូលបង្គំជានិច្ច ។ អាម៉ែន ។

ការសិក្សាបន្ថែម
ទំនុកដំកើង 92:1-5



ថ្ងៃពុធ ទី31 ខែធ្នូ

ចូរថ្វាយបង្គំទ្រង់

ទំនុកដំកើង 95:6 (ពគប)
មកចុះ ចូរយើងឱនកាយថ្វាយបង្គំទាំងអស់គ្នា ចូរយើងលុតជង្គង់នៅចំពោះព្រះយេហូវ៉ា ជាព្រះដ៏បង្កើតយើងខ្ញុំ។

វាជាថ្ងៃចូលឆ្នាំសកលកូនៗ។ នៅតែប៉ុន្មានម៉ោងទៀតវានឹងដល់ឆ្នាំ 2026! តើមានព្រះពរអ្វីខ្លះ! ព្រះអម្ចាស់បានស្មោះត្រង់ខ្លាំងណាស់ក្នុងឆ្នាំនេះ ហើយវាជាឱកាសដ៏ល្អបំផុត ដើម្បីអរព្រះគុណទ្រង់ ចំពោះសេចក្តីសប្បុរសរបស់ទ្រង់ ក្នុងជីវិតរបស់អ្នក។ នៅក្នុងឆ្នាំនៃអ្នកបំបែកច្រវាក់នេះ ខ្ញុំមិនមានការងឿងឆ្ងល់ទេថា អ្នកបានបំបែកច្រវាក់ នៅក្នុងព្រះនាមព្រះយេស៊ូវ។

នៅក្នុងព្រះគម្ពីរថ្ងៃនេះ យើងត្រូវបានប្រាប់ឱ្យក្រាបថ្វាយបង្គំទ្រង់។ លុតជង្គង់នៅចំពោះព្រះអម្ចាស់ដែលបានបង្កើតយើង។ តើវិធីណាដែលល្អជាង ដើម្បីបញ្ចប់មួយឆ្នាំ នៅពេលយើងចូលឆ្នាំថ្មី។ ព្រះអម្ចាស់សក្តិសម នឹងគេគោរពប្រណិបត្តន៍ណាកូនៗ ដោយសារទ្រង់ជាព្រះអម្ចាស់។ សូមយកបទគម្ពីរនេះទៅអនុវត្ត ហើយចំណាយពេលមួយភ្លែត ក្នុងការថ្វាយបង្គំថ្ងៃនេះ!

សេចក្តីប្រកាសពីបទទំនាយ
ឱព្រះអម្ចាស់អើយ កាលដែលខ្ញុំលុតជង្គង់ ទូលបង្គំសូមអរព្រះគុណទ្រង់ ចំពោះសេចក្តីមេត្រី និងសេចក្តីសប្បុរស របស់ទ្រង់នៅក្នុងជីវិតរបស់ខ្ញុំ។ ទ្រង់បានធ្វើឱ្យខ្ញុំពិសេស និងអស្ចារ្យ ហើយខ្ញុំចង់ថ្វាយបង្គំទ្រង់ ដោយអស់ពីចិត្ត។ អាម៉ែន

ការអធិស្ឋានសម្រាប់ថ្ងៃនេះ
ឱព្រះអម្ចាស់អើយ នៅពេលទូលបង្គំលុតជង្គង់ ទូលបង្គំសូមអរព្រះគុណទ្រង់ ចំពោះសេចក្តីមេត្រី និងសេចក្តីសប្បុរសរបស់ទ្រង់នៅក្នុងជីវិតរបស់ទូលបង្គំ។ ទ្រង់បានធ្វើឱ្យទូលបង្គំពិសេស និងអស្ចារ្យ ហើយទូលបង្គំចង់ថ្វាយបង្គំទ្រង់ដោយអស់ពីចិត្ត។ អាម៉ែន។

ការសិក្សាបន្ថែម
ទំនុកដំកើង 95:6-7

ទិនានុប្បវត្តិនៃសេចក្តីប្រកាស

សៀវភៅអនុស្សរកម្មសម្រាប់កុមារ ធ្វើឡើងដើម្បីដាក់ពណ៌ សរសេរ និងរីកចម្រើននៅក្នុងព្រះបន្ទូលរបស់ព្រះ!





ដោយ ហោរា យូ ប៊ើក អេនជល / Ubert Angel

www.goodnewsdailydevotionalkids.com

ហោរា យូយើត អេនជល / Uebert Angel

ប្រភពធនធានដំណឹងល្អ

ការរីកចម្រើនជាមួយនឹងព្រះបន្ទូលរបស់ព្រះ





ប្រភពធនធានដំណឹងល្អ សម្រាប់កុមារ របស់យើង ដែលត្រូវបានបំផុសគំនិត ដោយ ហោរា យូយើត អេនជល / Uebert Angel ត្រូវបានចនាឡើង ដើម្បីជួយកុមារ ឲ្យរីកចម្រើនក្នុងសេចក្តី ជំនឿ មានសេចក្តីស្រឡាញ់ លើ ព្រះបន្ទូលរបស់ព្រះ និងរស់នៅដោយ រីករាយជារៀងរាល់ថ្ងៃ។ តាមរយៈ សៀវភៅ សកម្មភាព ទំនានុបវត្តិ និង អ្វីៗជាច្រើនទៀត យើងធ្វើឱ្យការរៀន អំពី ព្រះយេស៊ូវគ្រីស្ទមានភាពសប្បាយ រីករាយ និងគួរឱ្យរំភើប!

www.goodnewsdailydevotionalkids.com

ហោរា យូប៊ើត អេនជល / Uebert Angel

អ្នករុករកព័ត៌មានដំណឹងល្អ

ដំណើរផ្សងព្រេងក្នុងដួងសេចក្តីជំនឿ ភាពសប្បាយរីករាយ
និងការរកឃើញ!







ការប្រមូលអ្នករុករកព័ត៌មានដំណឹងល្អ
អញ្ជើញកុមារឱ្យធ្វើដំណើរ ដ៏គួរឱ្យរំភើប
នៃសេចក្តីជំនឿ ភាពសប្បាយរីករាយ
និងការរកឃើញ! ត្រូវបានបំផុសគំនិត
ដោយការបង្រៀនរបស់ ហោរា យូប៊ើត
អេនជល / Uebert Angel ស្មៀវភៅ
នីមួយៗ ជួយឱ្យដួងចិត្តយុវវ័យ រីករួត
លាស់នៅក្នុងព្រះបន្ទូលនៃព្រះ ប្រៀន
មេរៀនដ៏មានតម្លៃ និងទស្សនៈលើភាព
អស្ចារ្យ នៃការរស់នៅពេញដោយ
ដំណឹងល្អ។

www.goodnewsdailydevotionalkids.com

ក្តីបកុមារ ដំណឹងល្អ

បទពិសោធន៍ដ៏រីករាយពោរពេញដោយសេចក្តីជំនឿ!



គេហទំព័រ GoodNews Daily Kids គឺជាវេទិកាអនឡាញដ៏គួរឱ្យរំភើបដែលត្រូវបានរចនាឡើងដើម្បីនាំយកព្រះបន្ទូលរបស់ព្រះ ទៅកាន់ជីវិតសម្រាប់កុមារតាមរបៀបរីករាយ និងទាក់ទាញ! ជាមួយនឹងសិទ្ធិពេញលេញទៅកាន់កម្មវិធី GoodNews Daily Kids Show សន្និដ្ឋានកិច្ចការអន្តរកម្ម កម្រងសំណួរ និងខ្ទឹមសារកសាងសេចក្តីជំនឿ គេហទំព័រនេះជួយកុមារ ឱ្យរីកចម្រើនក្នុងការយល់ដឹងអំពីព្រះគម្ពីរ និងទំនាក់ទំនងរបស់ពួកគេ ជាមួយព្រះអម្ចាស់យេស៊ូវគ្រីស្ទរបស់យើង។ ដែលបង្កើតឡើង ក្រោមការជាក់ស្តែងរបស់ ហោរា យូបើត អេនជល / Uebert Angel វាជាកន្លែងដ៏ល្អឥតខ្ចោះ សម្រាប់អ្នកជឿវ័យក្មេង ក្នុងការស្វែងរកព័ត៌មាន ដ៏ល្អតាមរបៀបដែលគួរឱ្យរំភើប ប្រកបដោយការអប់រំ និងការបង្កើនខាងវិញ្ញាណ!

ដោយហោរា យូបើត អេនជល / Ubert Angel

For more visit:
www.goodnewsdailydevotionalkids.com

ដំណើរផ្សងព្រេងនៅផ្ទះបាយ

ការធ្វើម្ហូបធ្វើឡើងដ៏រីករាយ និងដំណឹងល្អ!



ដំណើរផ្សងព្រេងនៅផ្ទះបាយ គឺជាកម្មវិធីធ្វើម្ហូបរបស់កុមារ ដ៏រីករាយរបស់យើង ដែលមេចុងភៅវ័យក្មេងស្វែងយល់ពីសេចក្តីរីករាយ នៃការបង្កើតអាហារ ខណៈពេលដែលរៀនអំពី សេចក្តីស្រឡាញ់ និងសេចក្តីសប្បុរសរបស់ព្រះ។ នៅពេលពួកគេលាយ ដុតនំ និងចែករំលែកក្នុងផ្ទះបាយ អ្នកនឹងឃើញពីរបៀប ដែលគ្រាប្រចាំថ្ងៃសូម្បីតែនៅក្នុងផ្ទះបាយ អាចបង្រៀនពួកគេអំពីព្រះ ការថ្វាយប្រឌិត និងការយកចិត្តទុកដាក់របស់ព្រះ។



ដោយ ហោរា យូ ប៊ើត អេនជល / Ubert Angel

www.goodnewsdailydevotionalkids.com

គ្រាប់បែក
BULDOZER



ការរៀនព្រះគម្ពីរ និង
ការបង្រៀនព្រះគម្ពីរ

The Bulldozer BLAST (ការរៀនព្រះគម្ពីរ និង ការបង្រៀនគម្ពីរ) គឺជា
កម្មវិធីរបស់កុមារនៅ Spirit
ស្ថានទូត ព្រះវិហារដំណឹងល្អ ដែលធ្វើឲ្យការរៀនព្រះបន្ទូលរបស់ព្រះមានភាព
រីករាយ និងទាក់ទាញ។ ជាមួយ
សកម្មភាពអន្តរកម្ម រឿង និងមេរៀនប្រកបដោយភាពច្នៃប្រឌិត យើងកំពុង
បង្រៀនកុមារឱ្យបង្កើត
គ្រឹះដ៏រឹងមាំនៃជំនឿ។ Bulldozer តំណាងឱ្យវិធីសាស្ត្រដ៏ស្វាហាប់របស់យើង
ការបំបែក
ចុះរបាំង និងធ្វើឱ្យខគម្ពីរងាយស្រួលយល់។ នាំកូនរបស់អ្នកឱ្យចូលរួមនៅថ្ងៃនេះ
ហើយមើលពួកគេរីកចម្រើននៅក្នុងសេចក្តីអំណរ និងចំណេះដឹងនៃព្រះបន្ទូល
របស់ព្រះ!

ដោយ ព្យាការី UEBERT ANGEL



វគ្គពង្រីកបន្តផ្ទាល់រៀងរាល់សប្តាហ៍

Follow: @bulldozerblastofficial



www.goodnewsdailydevotionalkids.com

ព្រះអម្ចាស់យេស៊ូវគ្រីស្ទនៃយើងខ្ញុំ - ជាព្រះអម្ចាស់នៃសេចក្តីស្រឡាញ់ និងសេចក្តីសង្គ្រោះរបស់យើងខ្ញុំ!



ព្រះយេស៊ូវគ្រីស្ទ ទ្រង់ជាព្រះរាជបុត្រានៃព្រះ និងជាព្រះអង្គសង្គ្រោះរបស់យើង! ទ្រង់បានយាងមកផែនដីដើម្បីបង្ហាញយើងថាតើព្រះទ្រង់ស្រឡាញ់យើងប៉ុណ្ណា។ ទ្រង់មានព្រះហឫទ័យសប្បុរសចំពោះអ្នករាល់គ្នា បានប្រោសអ្នកជំងឺ ផ្តល់អាហារដល់អ្នកស្រេកឃ្លាន ហើយថែមទាំងធ្វើឲ្យសមុទ្រមានខ្យល់ព្យុះស្ងប់ទៀតផង! ទ្រង់បានបង្រៀនយើងឲ្យស្រឡាញ់ព្រះ ហើយស្រឡាញ់អ្នកដទៃឲ្យអស់អំពីចិត្ត។ ប៉ុន្តែអ្វីដែលអស្ចារ្យបំផុតដែលទ្រង់បានធ្វើ គឺសុគតនៅលើឈើឆ្កាងសម្រាប់អំពើបាបរបស់យើង ដូច្នេះយើងអាចត្រូវបានអត់ទោសបាប ហើយមានជីវិតអស់កល្បជាមួយទ្រង់។ ប៉ុន្តែរឿងមិនទាន់ចប់ទេ នៅថ្ងៃទីបី ទ្រង់មានព្រះជន្មរស់ឡើងវិញ! ព្រះយេស៊ូវគ្រីស្ទមានព្រះជន្មរស់ ហើយទ្រង់តែងតែនៅជាមួយយើង ជួយយើង ណែនាំយើង និងការពារយើង ។ ទ្រង់ចង់ធ្វើជាមិត្តដ៏ល្អបំផុតរបស់យើង ហើយតែងតែត្រៀមខ្លួនស្តាប់ នៅពេលយើង អធិស្ឋាន។ ទោះមានរឿងអ្វីកើតឡើងក៏ដោយ យើងអាចជឿជាក់លើព្រះយេស៊ូវ ដោយសារទ្រង់ស្រឡាញ់យើងលើសពីអ្វីដែលយើងនឹកស្មានដល់!

«តែឯព្រះ ទ្រង់សំដែងសេចក្តីស្រឡាញ់របស់ទ្រង់ ដល់យើងរាល់គ្នាឲ្យឃើញច្បាស់ ដោយព្រះគ្រីស្ទបានសុគតជំនួសយើងរាល់គ្នា នោះគឺក្នុងកាលដែលយើងនៅមានបាបនៅឡើយផង»។ រ៉ូម 5:8

ដោយហោរា យូបើត អេនជល



តើអ្នកបានទទួលព្រះយេស៊ូវគ្រីស្ទហើយឬនៅ?

យើងខ្ញុំសូមអញ្ជើញអ្នកអញ្ជើញព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់នៃជីវិតរបស់អ្នកដោយ ការអធិស្ឋានបែបនេះ

"ឱព្រះអម្ចាស់អើយ ទូលបង្គំមករកទ្រង់ នៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។ ទូលបង្គំជឿដោយអស់ពីចិត្តលើព្រះយេស៊ូវគ្រីស្ទថាទ្រង់ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់។ ទូលបង្គំជឿថាទ្រង់បានសុគតជំនួសទូលបង្គំ ហើយព្រះអម្ចាស់បានប្រោសទ្រង់ពីសុគតឡើងវិញ។ ទូលបង្គំជឿថាទ្រង់មានព្រះជន្មរស់ដល់សព្វថ្ងៃនេះ។ ខ្ញុំថ្លែងបញ្ជាក់ដោយមាត់ថា ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់នៃជីវិតរបស់ខ្ញុំចាប់ពីថ្ងៃនេះតទៅ។ តាមរយៈទ្រង់ និងក្នុងព្រះនាមទ្រង់ ខ្ញុំមានជីវិតអស់កល្បជានិច្ច។ ខ្ញុំបានកើតជាថ្មី។ សូមអរព្រះគុណ ព្រះអម្ចាស់ ដែលបានសង្គ្រោះព្រលឹងទូលបង្គំ! ឥឡូវនេះទូលបង្គំជាកូនរបស់ព្រះ។ ហាលេលូយ៉ា!"

អបអរសាទរ! ឥឡូវនេះ អ្នកគឺជាកូនរបស់ព្រះ។

— ការអធិស្ឋាន —

ព្រឹក

អរុណសួស្តី ព្រះវិញ្ញាណបរិសុទ្ធ។ ចូរយើងអធិស្ឋានជាមួយគ្នា៖
ក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង សូមអរព្រះគុណ
ទ្រង់ចំពោះអំណោយទានដ៏មានតម្លៃនៃជីវិតនេះ។
សូមអរគុណសម្រាប់ថ្ងៃដ៏អស្ចារ្យនេះ និងពរជ័យទាំងអស់នៅក្នុងនោះ។
សូមអរគុណចំពោះ ខ្ញុំ
គ្រួសារ និងក្តីស្រលាញ់ទាំងអស់ដែលយើងចែករំលែក។ កាលដែលខ្ញុំ
ឆ្លងកាត់ថ្ងៃនេះ ជួយស្តាប់ផង
ចូរមានចិត្តសប្បុរសចំពោះ អ្នកឯទៀត ហើយ រីករាយ គ្រប់ទីកន្លែង
ដែល ខ្ញុំទៅ។ ព្រះវរបិតាសួគ៌ តើខ្ញុំអាចរកឃើញ
សូមអនុគ្រោះជាមួយអ្នក និងអ្នកគ្រប់គ្នាដែលខ្ញុំបានជួបនៅថ្ងៃនេះ។ នៅ
ក្នុងព្រះនាមព្រះយេស៊ូវ។ អាម៉ែន។

ល្ងាច

រាត្រីសួស្តី ព្រះវិញ្ញាណបរិសុទ្ធ។ ចូរយើងអធិស្ឋានជាមួយគ្នា៖
ក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង នៅពេលថ្ងៃរបស់
ខ្ញុំបានមកដល់ទីបញ្ចប់ ខ្ញុំចង់អរគុណ
អ្នកសម្រាប់ពរជ័យទាំងអស់នៅក្នុងជីវិតរបស់ខ្ញុំនិងសម្រាប់ការនៅ
ជាមួយខ្ញុំជានិច្ច។ ពេលខ្ញុំចូលគេង
សូមជួយឱ្យខ្ញុំសម្រាកដោយសន្តិភាព។ ថែរក្សាខ្ញុំ និងការពារខ្ញុំតាមរយៈ
យប់។ សូមអរព្រះគុណចំពោះសេចក្តីស្រឡាញ់ និងការយកចិត្តទុកដាក់
និងការណែនាំរបស់អ្នក ក្នុងព្រះនាមដ៏ឧត្តុង្គឧត្តមរបស់ព្រះយេស៊ូវ។
អាម៉ែន។





For further information on how to grow as a Christian, please get in touch with us at:

UK: +44 3333 448 612
USA +1 240 781 6942
RSA +27 51 004 0209
ZWE +263 773 195 955

gnd@goodnewsworld.com
goodnewsdailydevotional.com

SCAN FOR YOUR FREE DOWNLOAD